អដ្ឋកថា ព្រះសុត្តន្តបិដក

ជាតកដ្ឋកថា ទសមភាគ

បឋមភាគ

ភាគ ៦១

ពុទ្ធសករាជ ២៥៦៧

អដ្ឋកថា ព្រះសុត្តន្តបិដក

ខុទ្ទកនិកាយ

ជាតកដ្ឋកថា ទសមភាគ

បឋមភាគ

លេខ ៦១

ពុទ្ធសករាជ ២៥៦៧

អធិប្បាយ

បញ្ញាសនិចាត

អដ្ឋកថា ខុទ្ទកនិកាយ

ជាតកដ្ឋកថា

ភាគ ៦១

ទសមភាគ

បឋមភាគ

សរុបក្នុងនិចាតនេះ មាន ៤និចាត

១. បញ្ញាសនិចាត មាន ០៣ អដ្ឋកថា

សរុប ០៣ អដ្ឋកថា

ស:ទ៉ីសម្ព័យ

Signes et accents.

ខ្មែរ Cambodgien	᧠	᧡	᧢	᧣		᧤	᧥	᧦	᧧
ឡាតាំ Romain	*a*	*ā*	*i*	*ī*	*u*	*ū*	*e*	*o*	
សៀម Siamois	ๆ	ๆ	ๆ	ๆ		ๆ	ๆ	ๆ	ๆ
លាវ Laotien	ๆ	ๆ	ๆ	ๆ		ๆ	ๆ	ๆ	ๆ
លង្កា Cinghalais	ๆ	ๆ	ๆ	ๆ	ๆ	ๆ	ๆ	ๆ	ๆ
ភូមា Birman	ๆ	ๆ	ๆ	ๆ		ๆ	ๆ	ๆ	ๆ

ស្រៈពេញតួ
Voyelles.

ខ្មែរ Cambodgien	អ	អា	ឥ	ឦ	ឧ	ឩ	ឯ	ឱ
១ជ្ជ Romain	a	ā	i	ī	u	ū	e	o
សៀម Siamois	อ	อา	อิ	อี	อุ	อู	เอ	ไอ
លាវ Laotien	ອ	ອາ	ອິ	ອີ	ອຸ	ອູ	ເອ	ໄອ
លង្កា Cinghalais	අ	ආ	ඉ	ඊ	උ	ඌ	එ	ඔ
ភ្លីម Birman	အ	အာ	အိ	အီ	အု	အူ	အေ	ဩ

ព្យញ្ជនៈ

Consonnes:

ខ្មែរ Cambodgien	ក	ខ	គ	ឃ	ង
១០២ Romain	k	kh	g	gh	ṅ
សៀម Siamois	ก	ข	ค	ฆ	ง
លាវ Laotien	ກ	ຂ	ຄ	ຂ	ງ
លង្កា Cinghalais	ක	ඛ	ග	ඝ	ඞ
ភ្នែក Birman	‌	‌	‌	‌	‌

ខ្មែរ Cambodgien	ច	ឆ	ជ	ឈ	ញ
ជ្រៃ Romain	c	ch	j	jh	ñ
សៀម Siamois	จ	ฉ	ช	ฌ	ญ
ឡាវ Laotien	ຈ	ສ	ຊ	ຌ	ຍ
សង្ហ Cinghalais	ච	ඡ	ජ	ඣ	ඤ
ភូមា Birman	စ	ဆ	ဇ	ဈ	ဉ

ខ្មែរ Cambodgien	ដ	ឌ	ឍ	ណ	ន
១ក្ខ Romain	ṭ	ṭh	ḍ	ḍh	ṇ
១ក្ខ Siamois	ฏ	ฐ	ฑ	ฒ	ณ
១ក្ខ Laotien	ຏ	ຐ	ດ	ທ	ນ
១ក្ខ Cinghalais	ට	ඨ	ඩ	ඪ	ණ
១ក្ខ Birman	ဋ	ဌ	ဍ	ဎ	ဏ

ខ្មែរ Cambodgien	ត	ថ	ទ	ធ	ន
ទេវ Devanâgarî	t	th	d	dh	n
សៀម Siamois	ฏ	ฐ	ฑ	ฒ	ณ
លាវ Laotien	ຕ	ຖ	ດ	ທ	ນ
សង្ហាឡ Cinghalais	ට	ඨ	ඩ	ඪ	ණ
ភូមា Birmans	တ	သ	ဒ	ဓ	၊

ខ្មែរ Cambodgien	ប	ផ	ព	ភ	ម
ឡាតាំ Romain	*p*	*ph*	*b*	*bh*	*m*
សៀម Siamois	ป	ผ	พ	ภ	ม
លាវ Laotien	ປ	ຜ	ພ	ภ	ມ
សិង្ហាឡ Cinghalais	ප	ඵ	බ	භ	ම
ភីមាន Birman	ပ	ဖ	ဗ	ဘ	မ

ខ្មែរ Cambodgien	យ រ ល វ ស ហ ឡ ំ ។
១០០ Romain	y r l v s h ḷ ṃ ।.
សៀម Siamois	ย ร ล ว ส ห ฬ ํ ฯ
ឡាវ Laotien	ຍ ຣ ລ ວ ສ ຫ ຬ ໍ ໆ
លង្កា Cinghalais	ය ර ල ව ස හ ළ ං ෴
ភ្លីម Birman	ယ ရ လ ဝ သ ဟ ဠ ် ။

ពាក្យផ្តើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធជាម្ចាស់ មានអង្គ ៩ គឺ ៖

សុត្តៈ បានដល់ ឧកតោវិកង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេងៗ មានមង្គលសូត្រជាដើម ។

គេយ្យៈ បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

វេយ្យាករណៈ គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

គាថា គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធៗ ដែលមិនមានឈ្មោះ ពោលដល់ព្រះសូត្រក្នុងសុត្តនិបាត ។

ឧទាន គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងដោយសោមនស្សញ្ញាណ ។

ឥតិវុត្តកៈ គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្តើមឡើងដោយពាក្យថា សេចក្តីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

ជាតក គឺ ជាការសម្តែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

អព្ភូតធម៌ គឺ ព្រះសូត្រដែលបជិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

វេទល្ល: គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបានទទួលសេចក្តី

រីកវាយ និងសាកសួរជាបន្តិចៗ ។ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាមឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែលបណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេងៗ ដែលទ្រង់ឧបមាទុកដូចជាផ្ការីកយ៉ាង ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្វាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រតិបត្តិ ។

ព្រះមានព្រះភាគទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឈ្វាសក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្សយរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថាការបានស្តាប់នូវពុទ្ធាវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលពួកខ្លះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេងៗ គ្នា មានសីលនិងទិដ្ឋិផ្សេងៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយព្រមទាំងអត្ថ និងព្យញ្ជនៈ ព្រោះការសិក្សាចាំស្តាត់តគ្នាមកតាមលំដាប់ មានធនូ: និងមានឧស្សាហៈដ៏ខ្លាំងក្លា បានអធិ-ប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក ចំពោះសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់ក្នុងគម្ពីរព្រះពុទ្ធសាសនាខាងក្រោយមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ អាចរិយវាទ វាទៈរបស់អាចារ្យផ្សេងៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុញ្ញាចារ្យជំនាន់ក្រោយៗ ។

៤ អត្តនោមតិ ការគិតឃើញរបស់អ្នកពោល អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួនខ្ចប្ចូលគ្នានទុកជាមួយអត្តនោមតិ គឺ ទៅតាមមតិរបស់ខ្លួនឯងដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលជាគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើនទៅជាភាសាបាលី បុគ្គលដែលមានតន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអត្ថរាយច្រើន ព្រោះប្រកបដោយការយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់ជាមួយព្រះត្រៃបិដកពុទ្ធសាសនិកជនល្អប្រកាន់ថា ធ្វើមិនបានដូចគ្នា ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហាឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្ធ

សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់

ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមាន-ព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ ។ លុះព្រះពុទ្ធសាសនាកន្លងបាន ១០០ ឆ្នាំ ពួកភិក្ខុវជ្ជីបុត្រ សម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១. ភិក្ខុទុកជាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២. ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣. ភិក្ខុហាមកត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន មិនមែនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤. ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឆកម្ម គួរ ។

៥. ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦. ការបដិបត្តិដែលឧបជ្ឈាយ៍-អាចារ្យ ធ្លាប់ប្រព្រឹត្តមកខុសត្រូវយ៉ាងណា ប្រព្រឹត្តតាម គួរ ។

៧. ភិក្ខុហាមកត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨. ភិក្ខុផឹកស្រាខ្សោយៗ គួរ ។

៩. ភិក្ខុក្រាលសំពត់ទិសីទនៈដែលមិនមានជាយ គួរ ។

១០. ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកជាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា **កាកណ្ឌក:** បានស្តាប់វត្ថុ ១០ ប្រការនោះហើយ បានកាន់យកព្រះចៅអសោករាជដែលជាព្រះឱរសរបស់ព្រះបាទសុសុនាគ:ធ្វើជាសម្ងាញ់ ហើយជ្រើសរើសព្រះថេរ: ៧០០ អង្គ ក្នុងចំណោមភិក្ខុ ១.២០០.០០០ អង្គ គឺ (ដប់ពីរសែន) ញ៉ាំញ៉ីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកព្រះសរីរ: គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ តិះដៀលហើយ ទើបស្វែងរកពួកគណ: លុះបានពួកដែលជាទុព្វលវ:ដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្ងាត់ត្រកូលអាចារ្យថ្មី ឈ្មោះថា **មហាសង្ឆិក:** និង**ឯកពោហារិក:** ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឆិក:នោះ ។ ត្រកូលអាចារ្យ ២ ពួកដទៃទៀត គឺ **បញ្ញត្តិវាទ:** និង**ពហុលិយ:** ដែលមានឈ្មោះម្យ៉ាងទៀតថា **ពហុស្សុតិក:** ដែលបែកចេញមកពីនិកាយគោកុលិក: ។ អាចរិយវាទដទៃទៀត ឈ្មោះថា **ចេតិយវាទ** កើតឡើងហើយក្នុងរវាងនិកាយពហុលិយ:នោះ១ ឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឆិក: ដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឆិក:ដើមមួយ ក៏បានជា ៦ ត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសក: និងវជ្ជីបុត្តក:កើតឡើង ដែលបែកចេញមកអំពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយ: ១ ភទ្រយានិក: ១ ឆន្ទាគារិក: ១

សម្ថិតិយ: ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តក: ។ ក្នុងពុទ្ធសកាជ ២០០ ឆ្នាំនោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មុត្ត្ថិក:កើតឡើង ព្រោះការបែកចេញអំពីត្រកូលអាចារ្យមហិសាសក:ទៀត ។ កាលនិកាយកស្សបិក: ទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្ក្ដន្ដិក:ផ្សេងទៀតកើត ឡើង កាលនិកាយសង្ក្ដន្ដិក:ទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទ ក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញ មកអំពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមទាំងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសកាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទ និងនិកាយអាចរិយវាទ ៦ ដែល បែកចេញមកអំពីត្រកូលអាចារ្យមហាសង្ឆិក:ទាំងឡាយនោះ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយនោះឯង ។ ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញអំពីគ្នា, ចំណែកថេរវាទ បណ្ឌិត គប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

តារាងសម្តែងនិកាយសង្ឆក្នុងសតវត្សទី ៣



ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកជនៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

(ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ)

ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសគ្រូ ដែលយើងនិយមហៅថា **ព្រះពុទ្ធឃោសាចារ្យ** បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា របស់គម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ភិក្ខុមាននាមថា ពុទ្ធឃោស:ដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង (គម្ពីរអដ្ឋសាលិនី) ។ ទាំងនេះយើញថា នាមព្រះពុទ្ធឃោស:មានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោស: អារាធនាឲ្យព្រះពុទ្ធឃោស:តែងគម្ពីរនេះ ជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោស: ជាមង្គលដ៏អង្ហែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.000 ឆ្នាំ ។ កើតក្នុងត្រកូលព្រាហ្មណ៍ នាតំបន់ពុទ្ធគយាដែនមគធ: ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេងៗ ក្នុងជម្ពូទ្វីប បានធ្វើយបញ្ហាជាមួយសមណ: និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិ-បញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃៗ មិនអាចធ្វើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះពេញសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតអស់ទាំងសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្ទូ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះវេតត្ត្រ ដែលជាព្រះមហាទ្រីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វា-ធ្យាយហើយ ក៏ដឹងថា ជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានសេចក្តីសង្ស័យមិនយល់ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទា ក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដនាមថា **ព្រះពុទ្ធឃោសៈ** ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្តនាតំបន់ពុទ្ធគយានោះ លោកបានរចនាបកណ្ណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថាឈ្មោះ **អដ្ឋសាលិនី** ដែលជាអដ្ឋកថាគម្ពីរធម្មសង្គណីបកណ៍ និងគម្ពីរបវិត្តដ្ឋកថា គឺអដ្ឋកថាព្រះត្រៃបិដកចប្រាប់សង្ខេប ព្រះវេតមហាថេរៈបានឃើញអដ្ឋកថា ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃ-បិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែលង្កាទ្វីបនៅមានព្រោះព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចព្រះអគ្គសាវ៉ក) ជាដើម បានរចនាទុក និងតមក ព្រះមហិន្ទត្ថេរបានត្រួតពិនិត្យហើយ រចនាទុកជាកាសាសីហឡៈ

សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាកាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈក៏មានបីតិ-សោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឆ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរ ដែលបានទិមន្តជ្រួសផ្ទូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាកាសាមគធៈ ហើយធ្វើដំណើរតទៅ រហូតដល់កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រិយ៍លង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា (សិរិនិវាស) ១ៈ (សិរិកុថៈ) ១ៈ (សិរិកូដ្ត:) ១ៈ ក្នុងពុទ្ធសករាជ (៩៥២-៩៧៤) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឆក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្ភាក់របស់ព្រះសង្ឆបាលត្ថេរ ដែលជាព្រះសង្ឆរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្ភាក់មហាបធាន បានស្តាប់ទូវអដ្ឋកថាជាកាសាសីហឬ: និងថេរាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគដោយពិត ទើបបានសូមការអនុមតិអំពីសង្ឆដើម្បីបានវិកាសរចនាអដ្ឋកថាព្រះត្រៃបិដក ជាកាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឆលង្កា ដែលមានព្រះសង្ឆបាលត្ថេរជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថា ឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈ បានរចនាបកណ្ណ៍ឈ្មោះវិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឆលង្កា

ទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក ។ តាមប្រវត្តិបាននិយាយថា ដើម្បី នឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្ដាល ឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដងទៀត គម្រប់ ៣ ដង បន្ទាប់មក ក៏បានប្រគេនគម្ពីរដែលបានរចនាទាំងពីរលើកនោះវិញ រីឯនោះទើប បានគម្ពីរវិសុទ្ធិមគ្គជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះកិក្ខុសង្ឆ ព្រះកិក្ខុសង្ឆបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នា ទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយវេយ្យាទ ឬដោយព្រះបាលីទាំង ឡាយ ក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាច យ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឆប្រមាណ ១.000 អង្គ ប្រជុំគ្នាក្នុងមហាវិហារ បានឃើញសេចក្ដីអស្ចារ្យ ក៏នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះ ជាព្រះ មេត្តេយ្យពោធិសត្វដោយពិត នឹងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈ មកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះមហានាមក្សត្រិយ៍នៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់ លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឆ ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយឈ្មោះ **បធានយ** នាទិសទក្សិណានៃមហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ មកជាអដ្ឋកថាព្រះ

ត្រៃបិដកកាសាមគធ: ។

អដ្ឋកថាក្នុងកាសាសីហឬ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១. មហាអដ្ឋកថា

២. បច្ចរីយអដ្ឋកថា

៣. កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា ព្រះមហិន្ទត្ថេរនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាកាសាសីហឬ: ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ (ផ្ទះទ្រីក) ដែលក្នុងកាសាសីហឬ:ហៅថា បច្ចរីយ: ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឆទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

ភាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរភាទ** ។

គម្ពីរអដ្ឋកថាកាសាសីហឬ: ដែលព្រះពុទ្ធឃោស:បានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកកាសាមគធ: មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានវាយនាមព្រះគម្ពីរដូច្នេះ ៖

១. **សមន្តបា្ឋសាទិកា** អដ្ឋកថាព្រះវិន័យបិដក

២. **កង្ខាវិតរណី ឬមាតិកដ្ឋកថា** អដ្ឋកថាព្រះបាតិមោក្ខ

៣. **សុមង្គលវិលាសនី** អដ្ឋកថាទីឃនិកាយ

៤. **បបញ្ចសូទនី** អដ្ឋកថាមជ្ឈិមនិកាយ

៥. **សារត្ថប្បកាសិនី** អដ្ឋកថាសំយុត្តនិកាយ

៦. **មនោរថបូរណី** អដ្ឋកថាអង្គុត្តរនិកាយ

៧. **បរមត្ថជោតិកា** អដ្ឋកថាខុទ្ទកបាឋ: និងសុត្តនិបាត

៨. **ធម្មបទដ្ឋកថា** អដ្ឋកថាធម្មបទ

៩. **ជាតកដ្ឋកថា** អដ្ឋកថាជាតក

១០. **អដ្ឋសាលិនី** អដ្ឋកថាធម្មសង្គណីបករណ៍

១១. **សម្មោហវិនោទនី** អដ្ឋកថាវិភង្គបករណ៍

១២. **បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី** ជាព្រះអដ្ឋកថាព្រះអភិធម្ម ទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្ញត្តិ យមក និងបដ្ឋាន ។

១៣. **វិសុទ្ធិមគ្គ** បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤. **ញាណោទ័យ** តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥. **បវិត្តដ្ឋកថា** អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេងៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោស: អ្នកសិក្សាកាសាបាលីទូទៅបានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យដ៏សំខាន់ក្រៃលែងរបស់លោកយើងនេះ ។

រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្ហាត ហ៊ីន

ឧបាសក ឌុំ ទ្ធន

ឧបាសក ជឿម ជំនិត

ឧបាសក សន ម៉ារ៉ា

ឧបាសក អ៊ីមវ៉ៃយ៉ា

ឧបាសក សោម រតនៈ

ឧបាសក ម៉ៅ ផុន

ឧបាសិកា ថាប់ លៀម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ម៉ែន រមណី

ឧបាសក ណាក់ ម៉ៅ

ឧបាសក ហ៊ុក ស៊ីងហ្ងាត

ឧបាសក កើត ទិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ីត

ឧបាសក សំ ឌាយ

ឧបាសក ជា ស៊ីថាន

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្ផត្តិ

ឧបាសិកា ប៊ុត សេដាដ្ឋង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

រាយនាមអ្នកប្រែសម្រួល

ឧបាសក ហាយ ចំរើន

ឧបាសក ដឹម ជំនិត

ឧបាសក សន ម៉ារ៉ា

បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មកម្រប់ ៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ-

ឧទ្ទិសថ្វាយ និងគោរពជូន:

-ព្រះមហាវរក្សត្រិយ៍ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រិយ៍នៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឆរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុជាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រៃយ៉ភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

មាតិកាធម៌

ឈ្មោះរឿង ទំព័រ

ទសមភាគ

បញ្ញាសនិចាត

១-អដ្ឋកថា នឡិនិកាគជាតក	១
២-អដ្ឋកថា ឧម្មាទន្តីជាតក	៧៣
៣-អដ្ឋកថា មហាពោធិជាតក	១៥៩

ទសមភាគ

បរមត្ថទីបនី អដ្ឋកថាខុទ្ទកនិកាយ

ជាតកដ្ឋកថា

បញ្ញាសនិចាត

អដ្ឋកថា ឆឡិនិកាជាតកទី ១

(រឿងរាជធីតាឧម្មាយតប:របស់តាបស)

ព្រះសាស្តាកាលស្តេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បានប្រារព្ធការលួងលោមរបស់ភរិយាចាស់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា ***ឧទ្ធយ្ហតេ ជនបទោ “ជនបទក្តៅក្រហាយហើយ”*** *ដូច្នេះជាដើម ។*

ក៏ព្រះសាស្តាកាលនឹងត្រាស់ បានសួរភិក្ខុនោះថា “អ្នកត្រូវនរណាធ្វើឲ្យអផ្សុក?” កាលភិក្ខុនោះក្រាបទូលថា “ត្រូវភរិយាចាស់

ធ្វើឲ្យអផ្សុក” ទើបត្រាស់ថា “ម្នាលភិក្ខុ ស្រីម្នាក់នេះឯងជាអ្នកធ្វើនូវសេចក្តីវិនាសដល់អ្នក សូម្បីក្នុងកាលមុន អ្នកអាស្រ័យស្រីនេះ ហើយ ក៏វិនាសចាកឈាន ជាអ្នកដល់នូវសេចក្តីវិនាសយ៉ាងធំ” ហើយទ្រង់នាំអតីតនិទានមក ដូចតទៅនេះ ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជ្យសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វបានបដិសន្ធិក្នុងត្រកូលព្រាហ្មណ-មហាសាលឈ្មោះ **ខទ្ទិចៃ:** លុះចម្រើនវ័យហើយបានសិក្សាសិល្ប:ចប់សព្វគ្រប់ ក៏បួសជាឥសី ធ្វើឈាន និងអភិញ្ញាឲ្យកើតឡើង ហើយសម្រេចការនៅអាស្រ័យក្នុងព្រៃហិមពាន្ត ។ ព្រោះអាស្រ័យហេតុនោះ ដោយន័យដូចពោលហើយក្នុងអលម្ពុសាជាតក មេម្រ៉ីគមួយក្បាលទើបតាំងគភ៌ហើយកើតកូន ។ កូននោះបានឈ្មោះថា **ឥសិសិង្គោ** ។ តមក បិតាបានឲ្យគេដែលចម្រើនវ័យហើយបួស សិក្សាការបរិកម្មកសិណ ។ មិនយូរប៉ុន្មាន គេក៏ធ្វើឈាន

និងអកិញ្ចាឲ្យកើតឡើងបាន ទើបបានលេងដោយសេចក្តីសុខដែលកើតអំពីឈាន ជាអ្នកមានតប:ខ្ជាំងក្លា មានតប:យ៉ាងកំពូល មានឥន្ទ្រិយស្រស់ថ្លាដ៏ក្រៃលែង ។ ព្រោះតេជៈនៃសីលរបស់តាបសនោះ ភពរបស់ស្តេចសក្កទេវរាជទើបកម្រើក ។ ស្តេចសក្ក:ទ្រង់ពិចារណាក៏ជ្រាបនូវហេតុ គិតថា "យើងនឹងប្រើឧបាយទម្លាយនូវសីលរបស់តាបសនេះឲ្យបាន" ទើបហាមភ្លៀងមិនឲ្យធ្លាក់ក្នុងកា-សិករដ្ឋទាំងមូល ៣ ឆ្នាំ ។ ដែនដីប្រហែលដូចនឹងត្រូវភ្លើងឆេះ ។ កាលស្រូវអង្ករមិនសម្ផូរ ពួកមនុស្សត្រូវទុព្ភិក្ខភ័យបៀតបៀន ក៏ប្រជុំគ្នាត្រង់ព្រះលានហ្លួងយំរៀបរាប់ ។ លំដាប់នោះ ព្រះរាជាប្រថាប់ឈរនៅត្រង់ចន្ទោះទ្វារ ទ្រង់ត្រាស់សួរថា "ទុ:ខមានរឿងអ្វី?" ពួកមនុស្សដែលបានទទួលសេចក្តីទុក្ខក៏នាំគ្នាក្រាបទូលថា "បពិត្រមហារាជ កាលភ្លៀងមិនធ្លាក់អស់ ៣ ឆ្នាំ ដែនដីទាំងមូលក៏ក្តៅហែង ពួកមនុស្សក៏លំបាក បពិត្រព្រះសម្មតិទេព សូមព្រះអង្គចូរ

ឲ្យក្ងៀងធ្លាក់ចុះ” ។ ព្រះរាជាសូម្បីសមាទានសីល ចាំនៃបោសថ ក៏ទ្រង់មិនអាចនឹងឲ្យក្ងៀងធ្លាក់បាន ។ ក្នុងកាលនោះ ស្តេចសក្ក: ទ្រង់យាងចូលទៅកាន់បន្ទប់ ដែលប្រកបដោយព្រះសិរីរបស់ព្រះរាជាអង្គនោះ ក្នុងវេលាអធ្រាត្រ ទ្រង់ធ្វើពន្ធឲ្យភ្លឺហើយបានប្រថាប់ឈរត្រង់កណ្តាលវេហា ។ ព្រះរាជាទ្រង់ទតព្រះនេត្រឃើញស្តេចសក្ក: នោះហើយ ក៏ត្រាស់សួរថា “លោកជានរណា?” ស្តេចសក្ក:ត្រាស់តបថា “យើងជាសក្ក:ទេវរាជ” ។ ព្រះរាជាត្រាស់សួរថា “ព្រះអង្គស្តេចមកបំណងអ្វីឬ?” ស្តេចសក្ក:ត្រាស់ថា “មហារាជ ក្ងៀងក្នុងដែនរបស់ព្រះអង្គធ្លាក់ខ្ទះដែរឬ?” ព្រះរាជាត្រាស់ថា “មិនធ្លាក់ទេ” ស្តេចសក្ក:ត្រាស់សួរថា “ក៏ព្រះអង្គទ្រង់ជ្រាបហេតុដែលក្ងៀងមិនធ្លាក់ទេ?” ព្រះរាជាត្រាស់ថា “មិនជ្រាបទេ” ។ ស្តេចសក្ក:ទើបត្រាស់ប្រាប់ថា “មហារាជ ក្នុងហិមវន្តប្បទេស មានតាបសឈ្មោះឥសិសិង្ហ:អាស្រ័យនៅ តាបសនោះមានតប:ក្ងៀវក្លា មានឥន្ទ្រិយ

ស្រស់បស់ កាលក្ងៀងធ្លាក់ចុះមកជានិច្ច លោកក៏ក្រោធសម្ងឹងមើលទៅអាកាស ព្រោះដូច្នោះ ក្ងៀងទើបមិនធ្លាក់" ។ ព្រះរាជាត្រាស់សួរថា "ឥឡូវនេះ គប្បីធ្វើយ៉ាងណាក្នុងរឿងនេះ?" ស្តេចសក្ក:ត្រាស់ថា "កាលទម្លាយតប:របស់ព្រះតាបសនោះបាន ក្ងៀងនឹងធ្លាក់" ។ ព្រះរាជាត្រាស់សួរថា "ក៏នរណាអាចនឹងទម្លាយតប:របស់ព្រះតាបសនោះបាន?" ស្តេចសក្ក:ត្រាស់ប្រាប់ថា "មហារាជ ក៏ព្រះរាជធីតាព្រះនាមថា **ឧទ្ទាលិកា** របស់ព្រះអង្គជាអ្នកអាច ព្រះអង្គចូរឲ្យមនុស្សហៅនាងមកហើយបង្គាប់ថា កូនចូរទៅកាន់ទីឈ្នោះឯណោះ ហើយចូរទម្លាយតប:របស់ព្រះតាបសឲ្យបាន ដូច្នេះ ចូរបញ្ជូនទៅចុះ" ។ ស្តេចសក្កទេវរាជទូន្មានព្រះរាជាដូច្នេះហើយ ក៏ស្តេចទៅកាន់ទីនៅរបស់ព្រះអង្គវិញ ។ ស្ដ្រីកឡើង ព្រះរាជាទ្រង់ប្រឹក្សានឹងពួកអាមាត្ស ហើយត្រាស់បង្គាប់ឲ្យហៅព្រះរាជធីតាមកទ្រង់ត្រាស់ព្រះគាថាដំបូងថា

[១] ឧទ្ទយ្ហតេ ជនបទោ រដ្ឋញ្ចាបិ វិនស្សតិ

ឯហិ នទ្ធិនិកេ គচ្ছ តំ មេ ព្រាហ្មណមានយ ។

ជនបទក្តៅហែង សូម្បីរដ្ឋក៏ទីងវិនាស នែនទ្ធិនិកាកូន

មកនេះ កូនចូរទៅនាំព្រាហ្មណ៍ម្នាក់នោះមកឲ្យយើង ។

បណ្តាបទទាំងនោះ បទថា **តំ មេ** "**នាំព្រាហ្មណ៍ម្នាក់នោះ**

មកឲ្យយើង" សេចក្តីថា កូនចូរនាំព្រាហ្មណ៍ដែលធ្វើសេចក្តីវិនាស

ឲ្យដល់យើងនោះមកទុកក្នុងអំណាចរបស់ខ្លួន គឺ ចូរទម្លាយសីល

របស់តាបសនោះ ដោយវិធីឲ្យត្រេកអរក្នុងកិលេសចុះ ។

ព្រះរាជធីតាស្តាប់គាថានោះហើយ ទើបត្រាស់គាថាទីពីរថា

[២] នាហំ ទុក្ខក្ខមា រាជ នាហំ អទ្ធានកោវិទា

កថំ អហំ គមិស្សামិ វនំ កុញ្ជរសេវិតំ ។

បពិត្រព្រះរាជបិតា ខ្ញុំម្លាស់ទ្រាំទីងសេចក្តីលំបាកមិនបាន

ទេ ទាំងមិនស្គាល់ផ្លូវ ទីងទៅកាន់ព្រៃដែលជំរីអាស្រ័យនៅ

បានដូចម្តេច ព្រះអង្គ ។

បណ្តាបទទាំងនោះ បទថា **ទុក្ខក្ខមា** *"ទ្រាំនឹងសេចក្តីលំបាក" សេចក្តីថា បពិត្រមហារាជ ខ្ញុំម្ចាស់ជាអ្នកអត់ទ្រាំដល់សេចក្តីទុក្ខ មិនបានទេ ទាំងខ្ញុំម្ចាស់ក៏មិនស្គាល់ផ្លូវ ខ្ញុំម្ចាស់នោះនឹងទៅបានដូចម្តេច ព្រះអង្គ ។*

លំដាប់នោះ ព្រះរាជាទើបបានត្រាស់ ២ គាថាថា

[៣] *ផីតំ ជនបទំ គន្ត្វា ហត្ថិនា ច រថេន ច*
ទារុសង្ឆាជយានេន ឯវំ គচ্ছ នឡិនិកេ ។
ហត្ថី អស្សា រថា បត្តី គচ্ছ ភាទាយ ខត្តិយ
តវេវ វណ្ណរូបេន វសំ ឥមានយិស្សសិ ។

ម្នាលនឡិនិកាកូន កូនចូរទៅនៅជនបទដែលចម្រើនដោយដំរី ដោយសេះ ដោយយានដែលភ្ជាប់ដោយឈើ កូនចូរទៅដោយអាការយ៉ាងនេះចុះ កូនចូរនាំកងដំរី កងសេះ កងរថ

កងពលថ្មើជើងទៅហើយ នឹងនាំព្រាហ្មណ៍ម្នាក់នោះមកកាន់

អំណាចបានដោយពណ៌សម្ផ្ស និងរូបសម្ផត្តិរបស់ក្ងន ។

*បណ្តាបទទាំងនោះ បទថា **ទារុសង្ឆាជយានេន** "ដោយ**យានដែលក្ងាប់ដោយឈើ**" សេចក្តីថា ម្នាលនឡិនិកា ក្ងនមិនត្រូវ*ដើរទៅ តែថា ក្ងនទៅកាន់ជនបទដ៏ចម្រើន មានកិច្ចារកបានងាយ*ដ៏ក្សេមរបស់ខ្លួន ដោយពាហនៈដំរី ដោយពាហនៈរថទាំងឡាយ*ហើយ តអំពីទីនោះទៅ ក្ងនទីវាលស្រឡះចូរទៅដោយយានដែល*បិទបាំងហើយជាដើម ក្ងនផ្លូវទឹក ចូរទៅដោយទូក ឬក្ងន ដោយ*យានដែលក្ងាប់ដោយឈើចុះ ។ បទថា **វណ្ណរូបេន** "ដោយ**វណ្ណៈ និងរូបសម្ផត្តិ**" សេចក្តីថា ក្ងនមិនត្រូវលំបាកយ៉ាងនោះទេ ក្ងនទៅ*ហើយ ក៏នឹងនាំព្រាហ្មណ៍នោះមកកាន់អំណាចរបស់ខ្លួនបាន ដោយ*

វណ្ណៈ និងដោយរូបសម្ផត្តិរបស់ក្ងន ។

ព្រះរាជាអង្គនោះត្រាស់ព្រះតម្រាស់ដែលមិនគួរនឹងត្រាស់នឹង

ព្រះរាជធីតាដូច្នេះ ក៏ព្រោះបំណងនឹងរក្សាដែនដី ។ សូម្បីព្រះរាជ-ធីតានោះក៏ទូលទទួលថា "ព្រះករុណាព្រះអង្គ" ។ លំដាប់នោះ ព្រះរាជាទ្រង់បានព្រះរាជទានវត្ថុទាំងអស់ដល់ព្រះរាជធីតាហើយ ទ្រង់បញ្ជូនទៅជាមួយពួកអាមាត្យ ។ អាមាត្យទាំងឡាយនាំព្រះរាជធីតាទៅដល់បច្ចន្តជនបទ ឲ្យតាំងបន្ទាយស្នាក់នៅក្នុងជនបទនោះ ឲ្យលើកព្រះរាជធីតាឡើងហើយ ចូលទៅកាន់ហិមវន្តប្បទេសដោយផ្លូវដែលព្រានព្រៃចង្អុលប្រាប់ ក្នុងវេលាព្រឹក ក៏បានទៅដល់ទីជិតអាស្រមបទរបស់តាបសនោះ ។

ក្នុងខណៈនោះ ព្រះពោធិសត្វឲ្យបុត្តនៅចាំអាស្រមបទ ខ្លួនឯងចូលទៅកាន់ព្រៃដើម្បីផលាផល ។ ពួកព្រានព្រៃមិនទៅកាន់អាស្រមបទទេ តែឈរនៅក្នុងទីដែលមើលឃើញអាស្រមបទនោះ កាលនឹងសម្តែងអាស្រមបទនោះចំពោះព្រះនាងនទ្ទិនិកា ទើបបានពោល ២ គាថាថា

[៤] *កទលិទ្ធជបញ្ញាណោ អាកុដិបរិវារិតោ*[1]

ឯសោ បទិស្សតិ រម្មោ ឥសិសិង្គស្ស អស្សមោ ។

ឯសោ អគ្គិស្ស សង្ឆាតោ ឯសោ ធូមោ បទិស្សតិ

អាស្រមរបស់ឥសិសិង្គតាបសនោះ ប្រាកដដោយទង់ គឺ ដើមចេក ជុះព័ទ្ធដោយដើមស្នាច់ ជាទីមនោរម្យ ។

មញ្ញេ នោ អគ្គិ ហាបេតិ ឥសិសិង្គោ មហិទ្ធិកោ ។

ទុ:គឺ ពន្ធីភ្លើង ទុ:គឺ ផ្សែង ឃើញប្រាកដហើយ ឥសិ-សិង្គតាបសអ្នកមានឫទ្ធិច្រើន ដែលមិនធ្វើឲ្យភ្លើងវិនាស ។

*បណ្តាបទទាំងនោះ បទថា **កទលិធជបញ្ញាណោ**[2] "ប្រាកដដោយទង់ គឺ ដើមចេក" មានវិគ្រោះថា ឈ្មោះថា **កទលិធជ-ញ្ញាណ:** ព្រោះអត្ថថា មានទង់ គឺ ដើមចេកប្រាកដហើយ ។ បទ ថា **អាកុដិបរិវារិតោ** "ជុះព័ទ្ធដោយដើមស្នាច់" បានដល់ ហែហម*

១.ម. អាកុដិបរិវារិណោ ។ បិដក. កទលិទ្ធជបញ្ញាណោ ។

ដោយព្រៃស្ងាត់ ។ បទថា **សង្ខ្យាតោ "ពន្ធ"** សេចក្ដីថា នុ៎ះគឺ ពន្ធ ក្ងើង ដែលឈានរបស់ឥសិសិង្គតាបសនោះតាក់តែង កំពុងនៅនេះ ប្រចក្ស ។ បទថា **មញ្ញេ នោ អគ្គី**[1] **"ដែលមិនធ្វើក្ងើងឲ្យវិនាស"** សេចក្ដីថា យើងរមែងសម្គាល់ថា ឥសិសិង្គតាបសនឹងមិនធ្វើក្ងើងឲ្យវិនាស គឺ ឲ្យនេះដោយការបម្រើហើយ ។

ចំណែកពួកអាមាត្យនាំគ្នាទ្បាមព័ទ្ធអាស្រមនោះ ក្នុងវេលាដែលព្រះពោធិសត្វចូលទៅកាន់ព្រៃ រំពេចនោះក៏តាំងកងរក្ស ឲ្យព្រះរាជធីតាកាន់ភេទជាឥសី យកសំពត់សំបកឈើពណ៌ាមាសខ្ទះ ធ្វើជាសំពត់ស្បៃកដណ្ដប់ ប្រដាប់ដោយគ្រឿងសព្ទាលង្ការ ហើយឲ្យព្រះរាជធីតាកាន់យកកូនវូដ៏វិចិត្រចង់ដោយសរសៃអំបោះ បញ្ជូនចូលទៅកាន់អាស្រមបទ ពួកខ្ជួននាំគ្នាឈរការពារខាងក្រៅ ។ ព្រះរាជធីតានោះលេងកូនវូនោះ ក៏ក្ងន់ផុតផ្ទ្ববចង្ក្រម ។ ក្នុងខណៈនោះ

ឋិដក. ១. មញ្ញេ នោ អគ្គិ ។

ឥសិសិង្គតាបសកំពុងអង្គុយនៅលើផ្ទាំងថ្មជិតទ្វារបណ្ណសាលា ។ តាបសនោះក្រឡេកឃើញស្រីនោះកំពុងដើរមក ក៏តក់ស្លុត ក្រោកឡើងហើយចូលទៅកាន់បណ្ណសាលាឈប់ស្ងៀម ។ សូម្បីព្រះរាជធីតានោះ ក៏ទៅកាន់ទ្វារបណ្ណសាលារបស់តាបសនោះ ហើយក៏លេង (ក្ងន) តទៅទៀត ។

ក៏ព្រះសាស្តាកាលនឹងប្រកាសសេចក្តីនោះឲ្យកៃ្រលែងឡើងជាងនោះ ទើបបានត្រាស់ ៣ ព្រះគាថាថា[1]

[៥] តញ្ច ទិស្វាន អាយន្តឺ អាមុត្តមណិកុណ្ឌលឺ
ឥសិសិង្គោ ចារិសិ ភីតោ អស្សមំ បណ្ណចាទនំ ។

ឥសិសិង្គតាបសឃើញព្រះរាជធីតាដែលពាក់ដោយកុណ្ឌ-លកៃ្រមណីស្តេចមកហើយ ក៏ភិតភ័យ ចូលទៅកាន់អាស្រមដែលប្រក់ដោយស្លឹកឈើ ។

---

[1] តាមព្រះបាលីឃើញតែ ២ គាថា?

អស្សមស្ស ច សា ទ្វារេ គណ្ឌុកេនស្ស កីឬតិ

ទ្វិទ្ធំ សយន្ត្ថី អង្ហានិ គុយ្ហ បកាសិតានិ ច ។

ចំណែកព្រះរាជធីតាសម្ដែងអាយ៉ាងត្រង់ទីកំបាំង និងអាយ៉ាងដែលប្រាកដ លេងកូនវ៉ូដល់តាបស ត្រង់ទ្វារអាស្រមរបស់តាបសនោះ ។

[ខ] *តញ្ច ទិស្វាន កីឬន្ត្ថី បណ្ណសាលគតោ ជដី*

អស្សមា និក្ខមិត្វាន ឥទ្ធ វចនមព្រវិ ។

ចំណែកតាបសដែលនៅក្នុងបណ្ណសាលា ឃើញព្រះនាងកំពុងលេងកូនវ៉ូហើយ ទើបចេញចាកអាស្រម បានពោលពាក្យនេះ ។

បណ្ដាបទទាំងនោះ បទថា **គណ្ឌុកេនស្ស** *"កូនវ៉ូដល់តាបស" បានដល់ លេងកូនវ៉ូត្រង់ទ្វារអាស្រមរបស់ឥសិសិង្ហតាបសនោះ ។ បទថា* **ទ្ធ** *"សម្ដែង" បានដល់ សម្ដែងហើយ ។ បទថា*

*គុយ្ហំ បកាសិតានិ ច "អវយវ:ដែលកំពុង និងអវយវ:ដែលប្រាកដ" បានដល់ អវយវ:ដែលលាក់ពុង និងអវយវ:ដែលប្រាកដ មានផ្ទៃមុខ និងដៃជើងជាដើម ។ បទថា **អព្រវិ**[1] "**បានពោល**" សេចក្ដីថា តំណាលថា ព្រះតាបសនោះឈរនៅក្នុងបណ្ណសាលា ហើយគិតថា "បើថា បុគ្គលនេះនឹងជាយក្ខសោត ក៏គប្បីចូលមកកាន់បណ្ណសាលា ហើយនឹងហៅកសាច់យើងស៊ី បុគ្គលនេះដូចជាមិនមែនយក្ខ គង់ជាតាបសដោយពិត" ។*

ព្រោះដូច្នោះ បានឮថា ឥសិសិង្ហតាបសក៏ចេញចាកអាស្រម ហើយពោលពាក្យនេះថា

អម្ភោ កោ នាម សោ រុក្ខោ យស្ស ត្យ គតំ ផលំ

ទូរេបិ ខិត្តំ បត្ថេតិ ន តំ ឱហាយ គচ্ছតិ ។

នាងដ៏ចម្រើន ដើមឈើរបស់នាងមានផ្ទៃប្រព្រ័ត្តទៅយ៉ាង

---

១. ក្នុងបទថា ឥទំ វចនមព្រវិ ។

នេះ មានឈ្មោះថាអ្វី សូម្បីនាងបោះទៅធ្លាយក៏ត្រឡប់មក

មិនបានលះបង់នាងឡើយ ។

*បណ្តាបទទាំងនោះ បទថា **យស្ស តេវ គតំ** "ដែលមាន*

ផ្លែប្រព្រឹត្តទៅយ៉ាងនេះ" សេចក្តីថា ដើមឈើប្រកេទណារបស់

*នាង មានផ្លែដែលគួរឲ្យគាប់ចិត្តយ៉ាងនេះ ។ បទថា **កោ នាម***

***សោ រុក្ខោ** "ដើមឈើ... **មានឈ្មោះថាអ្វី**" បានដល់ តាបសសម្គាល់*

ថា "កូនវូនោះ ជាផ្ទៃនៃដើមឈើ" ព្រោះកូនវូដ៏វិចិត្រនោះខ្លួនមិន

ធ្លាប់បានឃើញមកក្នុងកាលមុន ទើបបានសួរយ៉ាងនេះ ។

លំដាប់នោះ ព្រះរាជធីតានោះកាលនឹងប្រាប់ ទើបបានត្រាស់

គាថានេះនឹងតាបសនោះថា

[៧] ***អស្សមស្ស** មម ព្រហ្មេ សមីបេ គន្ធមាទនេ*

ពហវោ តាទិសា រុក្ខា យស្ស តេវ គតំ ផលំ

*ទូរេបិ ១ ១ ១

បពិត្រព្រាហ្មណ៍ ដើមឈើដែលមានផ្លែប្រព្រឹត្តទៅយ៉ាងនេះ មានច្រើននៅត្រង់ក្នុំគន្ធមាទន៍ នៅជិតអាស្រមរបស់ខ្ញុំ ផ្លែឈើនោះ សូមីខ្ញុំចុះទៅឆ្ងាយក៏ត្រឡប់មក មិនលះបង់ខ្ញុំទៅឡើយ ។

បណ្តាបទទាំងនោះ បទថា ***សមីបេ គន្ធមាទនេ "ត្រង់ក្នុំគន្ធមាទន៍ នៅទីជិត"*** *បានដល់ នៅជិតអាស្រមរបស់ខ្ញុំត្រង់ក្នុំគន្ធ-មាទន៍ ។ បទថា* ***យស្ស តេវ គតំ "ដែលមានផ្លែប្រព្រឹត្តទៅយ៉ាងនេះ"*** *បានដល់ ដើមឈើដែលមានផ្លែយ៉ាងនេះ ។* ***ត*** *អក្សរ ជាការភ្ជាប់បទព្យញ្ជនៈ ។ ព្រះរាជធីតានោះបានពោលមុសាវាទដូច្នេះ ឯង ។*

ចំណែកតាបសវិញ ហើយ កាលនឹងធ្វើការក្រាកទទួលដោយ សម្គាល់ថា "អ្នកនេះជាព្រះតាបស" ទើបពោលគាថានេះថា

[៨] ***ឯតុ ករំ អស្សមិមំ អនេតុ***

បជ្ជញ្ហ ភក្ខញ្ហ បដិច្ឆ ទម្មិ

ឥទមាសនំ អត្រ ភវ និសីទតុ

ឥតោ ភវ មូលផលានិ ភុញ្ជតុ ។

សូមអ្នកជ័ចម្រើនចូលមកកាន់អាស្រមនេះ ចូរបរិភោគ ចូរទទួលប្រេង និងភក្សា យើងនឹងឲ្យ នេះអាសនៈ សូមអ្នកអង្គុយលើអាសនៈនេះ សូមបរិភោគមើមជំនួង និងផ្លែឈើ អំពីទីនេះចុះ ។

*បណ្តាបទទាំងនោះ បទថា **អស្សមិមំ** "កាន់អាស្រមនេះ" សេចក្តីថា សូមអ្នកជ័ចម្រើនចូលមកកាន់អាស្រមនេះចុះ ។ បទថា **អនុតុ** "**ចូរបរិភោគ**" បានដល់ សូមអ្នកបរិភោគអាហារតាមដែលយើងបានត្រៀមទុកហើយចុះ ។ បទថា **បជ្ជ** "**ប្រេង**" បានដល់ ប្រេងសម្រាប់លាបជើង ។ បទថា **ភក្ខ** "**ភក្សា**" បានដល់ ផ្លែឈើតូចធំដែលមានរសឆ្ងាញ់ ។ បទថា **បដិច្ឆ** "**ចូរទទួល**" បាន*

ដល់ ចូរកាន់យក ។ បទថា **ឥទមាសនំ "នេះអាសនៈ"** បានដល់ ព្រះតាបសពោលហើយយ៉ាងនោះ ក្នុងវេលាដែលព្រះរាជធីតាចូលទៅហើយ ។

ក្នុងពាក្យថា **នេះជាអ្វីរបស់អ្នក** មានអធិប្បាយថា កាលព្រះរាជធីតាអង្គនោះចូលទៅកាន់បណ្ណសាលា អង្គុយលើចន្ទោះឈើ កាលសំពត់សំបកឈើពណ៌មាសញ្ជែកត្រង់កណ្តាលជាពីរ សរីរៈដែលបិទបាំងក៏លេចឡើង ។ ព្រះតាបសលុះឃើញអវយវៈដែលកំបាំង ព្រោះខ្លួនមិនធ្លាប់ឃើញសរីរៈរបស់មាតុគ្រាមមកអំពីមុន ទើបសម្គាល់ថា "នោះជាដំបៅ" ដូច្នេះហើយ ទើបពោលយ៉ាងនេះ ថា

[៩] *កិន្តេ ឥទំ ខុ,ជ្ជនមន្ត,ស្មិ*
សុបិច្ឆិតំ កណ្ហវិវណ្ណ,ាសតិ
អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ

កោសេ នុ តេ ឧត្តមङ្គំ បវិដ្ឋំ ។

ត្រង់ចន្ទោះក្ងៀតទាំងពីររបស់អ្នក នេះជាអ្វីរបស់អ្នក មានសណ្ឋានរៀបរយល្អ ប្រាកដដោយពណ៌ខ្មៅ យើងសួរអ្នកហើយ សូមអ្នកចូរប្រាប់សេចក្ដីនោះដល់ខ្ញុំ អាយុ:ចំណែកវែងរបស់អ្នកចូលទៅនៅក្នុងស្រោមឬហ្ន៎ ។

*បណ្ដាបទទាំងនោះ បទថា **សុបិច្ឆិតំ** "**មានសណ្ឋានរៀបរយល្អ**" សេចក្ដីថា សណ្ឋានមាត់ដំបៅដែលមានសិល្ប: សម្ងួសគ្នាដោយល្អ ក្នុងវេលាក្ងៀតទាំងពីរខាងចូលជិតគ្នា ពិតហើយ ទីត្រង់នោះបានក្លាយជារណ្ដៅ ព្រោះមិនប្រកបដោយលក្ខណ:ដែលស្អាត និងមានសណ្ឋានជាមាត់ដំបៅ ដែលមានសិល្ប:កំពុងឡើងច្បាស់ ព្រោះប្រកបដោយលក្ខណ:ល្អស្អាត ។ បទថា **កណ្ហវិប្ផកាសតិ** "**ប្រាកដដោយពណ៌ខ្មៅ**" បានដល់ ប្រាកដដោយពណ៌ខ្មៅត្រង់ខាងទាំងពីរ ។ ដោយបទថា **កោសេ នុ តេ ឧត្តមङ្គំ បវិដ្ឋំ** "**អាយុ:**

ចំណែកវ៉ែងរបស់អ្នកចូលទៅនៅក្នុងស្រោមឬហ្ន៎?" បានដល់ ព្រះ

តាបសសួរថា "អាយុ:ចំណែកវ៉ែង គឺ សណ្ឋាននៃកេទរបស់អ្នក

រមែងមិនប្រាកដ ឯអាយុ:ចំណែកវ៉ែងចូលទៅនៅក្នុងស្រោម គឺ

សរីរ:របស់អ្នកឬហ្ន៎?" ។

លំដាប់នោះ ព្រះរាជធីតានោះកាលនឹងកុហកព្រះតាបសនោះ

ទើបត្រាស់ ២ គាថាថា

[១០] *អហំ វនេ មូលផលេសនំ ចរំ*

អសាទយី អច្ចំ សុយោវ្ជបំ

សោ មំ បតិត្វា សហសជ្ជបាត្ត

បនុជ្ជ មំ អពុហិ ឧត្តមង្គំ ។

ខ្ញុំត្រាច់ស្វែងរកមើមផលាហារក្នុងព្រៃ បានជួបខ្លាឃ្មុំមាន

រូបរាងគួរខ្លាចក្រៃលែង វាសុះមកជេញខ្ញុំ សង្ត្រាប់ដោយរហ័ស

ធ្វើឲ្យខ្ញុំដួលចុះ ខាំអាយុ:ចំណែកវ៉ែងរបស់ខ្ញុំទៅ ។

ស្វាយំ រណ្ណ ១ជ្ជតិ កណ្ហ្ការយតិ

សព្ពញ្ច កាលំ ន លភាមិ សាតំ

បហោ ភវ កណ្ហ្ការមិមំ រិនេតុំ

ភ្ជ្ជតំ ភវ យាចិតោ ព្រាហ្មណត្ថ ។

ជំហ៊ានោះក៏ជារង្វះ និងកើតវ័ណ្ណ១ទ្បើង ខ្ញុំមិនបានសេចក្ដីសប្បាយរហូតកាលទាំងពួង លោកគង់ទ្ធីងអាចកម្ចាត់សេចក្ដីរមាស់នេះបាន ខ្ញុំអង្ហ្ករហើយ សូមលោកមេត្ត្ការធ្ងីប្រយោជន៍ឲ្យដល់ខ្ញុំដែលជាព្រាហ្មណ៍ផងចុះ ។

*បណ្ដាបទទាំងនោះ បទថា **អសាទយ** "**បានជួប**" បានដល់ ប្រយុទ្ធគ្នានឹងខ្ជាឃ្ចុំដែលសង្ត្រាប់មក ទើបយកជ្ជុំដ៏ីគប់មាត់ វ ។ បទ ថា **ឋតិ** "**សង្ត្រាប់**" បានដល់ សង្ត្រាប់មក ។ បទថា **សហ-ជ្ជ**ប្ជ**ត្ត** "**មកទាន់សង្ត្រាប់ដោយរហ័ស**" បានដល់ ដល់ គ ឺ ទាន់ ១ុ្ជ ដោយរហ័ស ។ បទថា **ឋនុជ** "**ធ្ងីឲ្យ... ជ្ជ**ួ**លចុះ**ហ**ើ** យ" បាន*

ដល់ ពេលនោះធ្វើឲ្យខ្ញុំដួលចុះហើយ ។ បទថា **អញ្ញហិ**[1] **"ទ្ធាំ"** សេចក្តីថា វាប្រើមាត់ទ្ធាំអាយវ:ចំណែកវែងរបស់ខ្ញុំជាច់ហើយ ក៏រត់ចេញទៅ តាំងអំពីនោះមក ទីត្រង់នេះឯងទើបក្លាយជាដំបៅ ។ បទថា **ស្វាយំ "ដំបៅនោះ"** សេចក្តីថា តាំងអំពីនោះមក ដំបៅរបស់ខ្ញុំនេះទើបកើតជារង្វះ និងធ្វើឲ្យរមាស់ ព្រោះប្រការនោះជាបច្ច័យ ខ្ញុំទើបមិនបានទទួលសេចក្តីសុខទាំងផ្លូវកាយ និងផ្លូវចិត្ត អស់កាលទាំងពួង ។ បទថា **បហោ "គង់នឹងអាច"** បានដល់ ជាអ្នកអាច ។ បទថា **ព្រាហ្មណ្ត្ តំ "ប្រយោជន៍ឲ្យដល់ខ្ញុំដែលជាព្រាហ្មណ៍ចុះ"** សេចក្តីថា ព្រះរាជធីតាពោលថា "លោកដ៏ចម្រើន ខ្ញុំអង្វរហើយ ករុណាធ្វើនូវប្រយោជន៍នេះដល់ខ្ញុំដែលជាព្រាហ្មណ៍ចុះ គឺ សេចក្តីទុក្ខនេះនឹងមិនមានដល់ខ្ញុំ បានដល់ ចូរជួយនាំចេញទៅផងចុះ" ។

---

* បិដក. ១. អញ្ញហិ ។*

ព្រះតាបសនោះជឿពាក្យមុសាវាទរបស់ព្រះរាជធីតានោះថា "ជាការពិត" ដូច្នេះហើយទើបគិតថា "បើសេចក្តីសុខយ៉ាងនោះនឹងមានដល់អ្នកសោត ខ្ញុំក៏នឹងធ្វើឲ្យ" សម្ងឹងមើលចំណែកត្រង់នោះ ហើយ បានពោលគាថាបន្ទាប់ទៀតថា

[១១] គម្ភីរបោ តេ វណ្ណ សលោហិតោ
អបូតិកោ បន្ធគន្ធោ[1] មហា ច
ករោមិ តេ កិញ្ចិ ករណ្ឌយោគំ
យថា ករំ ឧរមសុវី ករេយ្យ ។

ជំហៅរបស់អ្នកជ្រៅ មានពណ៌ក្រហម មិនស្អុយ មានក្លិនខ្ទុះ និងជាជំហៅធំ យើងនឹងផ្ទុកថ្នាំបន្ទិចឲ្យអ្នកតាមដែលអ្នកនឹងគប្បីមានសេចក្តីសុខក្រៃលែង ។

បណ្តាបទទាំងនោះ បទថា **សលោហិតោ** "**មានពណ៌ក្រហម**"

១.ម. វណ្ណគន្ធោ, បក្ខគន្ធោតិ អដ្ឋកថាយំ ទិស្សតិ ។

បានដល់ មានសាច់ពណ៌ក្រហម ។ បទថា **អបូតិកោ** *"មិនស្អុយ"*

បានដល់ រៀរចាកសាច់ស្អុយ ។ បទថា **ឧក្ខគន្ធោ** *"មានក្លិនខ្មោះ"*

បានដល់ មានក្លិនខ្មោះតិចតួច ។ បទថា **កសាយយោគំ** *"ផ្សុំថ្នាំ"*

សេចក្តីថា ខ្ញុំនឹងកាន់យកទឹកចត់អំពីដើមឈើប្រភេទខ្លះ ហើយផ្ងើ

ទឹកចត់នោះផ្សុំជាថ្នាំលាបដំបៅដល់អ្នក ។

លំដាប់នោះ ព្រះនាងនន្ទិនិកាទើបត្រាស់គាថាថា

[១២] *ន មន្តយោគា ន កសាយយោគា*

ន ឱសធា ព្រហ្មចារី ករន្តិ

យំ ត្រ មុទ្ធ ត្រ អង្គ្គ ន ន ហិ ករណ្ដ[1]

*យថា អហំ ឧ ១ ១ ១

អង្គជាតិដ៏ទន់របស់លោក ត្រជុសកម្ចាត់សេចក្តីរមាស់តាមដែលខ្ញុំនឹងគប្បីមានសេចក្តីសុខក្រៃលែងចុះ ។

បណ្តាបទទាំងនោះ បទថា ***កមន្តិ “រមែងកែ (មិនបាន)”*** *សេចក្តីថា បពិត្រលោកដ៏ប្រសើរ ការប្រកបមន្តក្តី ការប្រកបថ្នាំក្តី ឱសថមានផ្លា និងផ្លែឈើជាដើមក្តី ជំងឺរបស់ខ្ញុំនេះរមែងកែមិនបានឡើយ គឺ ការប្រកបមន្តជាដើមនោះ សូម្បីនឹងធ្វើហើយច្រើនដង ក៏មិនបានសេចក្តីសប្បាយដល់ជំងឺខ្ញុំនោះឡើយ តែបើលោកប្រើអង្គជាតិដ៏ទន់របស់លោកនោះត្រជុសទៅមកប៉ុណ្ណោះ ក៏ជំងឺនោះនឹងមិនរមាស់ ព្រោះដូច្នោះ សូមលោកជួយយកអង្គជាតិនោះកម្ចាត់សេចក្តីរមាស់ឲ្យផងចុះ ។*

តាបសនោះកំណត់ថា “អ្នកនេះនិយាយពិត” មិនដឹងទេថា “សីលនឹងជាច់ ឈានឹងវិនាស ព្រោះមេជុនសំសគ្គ:” ដូច្នេះហើយ កាលព្រះរាជធីតានោះពោលថា “ឥសីកេសជ្ជ” ទើបសេពមេជុន

ព្រោះការមិនដឹងក្នុងមេជុនធម្ម ហេតុដែលខ្ជួនមិនធ្លាប់ឃើញមាតុ-
គ្រាមអំពីមុន ។ ក្នុងរំពេចនោះ សីលតាបសនោះក៏ជាប់ ឈានក៏
វិនាស ។ តាបសនោះធ្វើការរួមសង្វាស ២-៣ ដង ក៏នឿយហត់
ទើបចេញទៅ ចុះកាន់ស្រះផ្ទួតទឹក លុះរម្ងាប់សេចក្តីក្រវល់ក្រវាយ
ហើយ ត្រឡប់មកអង្គុយក្នុងបណ្ណសាលា សូម្បីដូច្នោះ ក៏នៅតែ
សម្គាល់នាងនោះទៀតថា "ជាតាបស" កាលនឹងសួរដល់ទីនៅ ទើប
ពោលគាថាថា

[១៣] ឥតោ នុ ភោតោ កតមេន អស្សមោ
កច្ចិ ភវំ អភិរមសិ អរញ្ញេ
កច្ចិ នុ តេ មូលផលំ ពហូតំ
កច្ចិ ភវន្តំ ន វិហីសន្តិ ភុជ្ជា ។

អាស្រមរបស់អ្នកនៅទិសណាអំពីទីនេះ អ្នកជ័ចម្រើនហ្ន៎
អ្នកជ័ចម្រើន អ្នករមែងរីករាយហើយក្នុងព្រៃដែរឬ មូលផ-

លាហារបស់អ្នកមានសមល្មមដែរឬ សត្វកាចមិនបៀតបៀន

អ្នកទេឬ ។

បណ្តាបទទាំងនោះ បទថា **កតមេន** "**នៅទិសណា**" បានដល់ អាស្រមរបស់អ្នកជ័ចម្រើននៅទិសខាងណាអំពីទីនេះ ។ បទ

ថា **ករ** "**អ្នកជ័ចម្រើន**" នេះ ជាអាលបន: ។

លំដាប់នោះ ព្រះនាងនឡិនិកាបានត្រាស់ ៤ គាថាថា

[១៤] **ឥតោ ឧជុं ឧត្តរយं ទិសាយं**

ទេមា នទី ហិមវន្តា បការ[1]

តស្ស្ យ តីរេ អស្ស្ រមោ មយ្ហ ១ម្ម

អហេ ករ អស្ស្ មं មយ្ហ ១ាសេ ។

ស្តីងណ្ហោះទេមា រមែងប្រាកដអំពីព្រៃហិមពាន្ត ក្នុងទិសខាងជើងត្រង់អំពីនេះទៅ អាស្រមដែលគួររីករាយរបស់ខ្ញុំនៅ

១.ម. ហិមវតា ១ការ ។

ត្រង់មាត់ស្ទឹងនោះ លោកគួរទៅមើលអាស្រមរបស់ខ្ញុំ ។

អម្ពា ច សាលា តិលកា[1] ច ជម្ពុយោ

ឧទ្ទាលកាបិ ជលិយោ ច ផុល្លា

សមន្ត្ដោ ក៏ បុរិសាកិតីតំ

អហោ ភវ៎ អស្សមំ មយ្ហ បាសៃ ។

ដើមស្វាយ ដើមរាំង ដើមទម្ងាប់ ដើមត្រើង ដើមរាជ-ព្រ៉ីក្ស ដើមច្រនៀង មានផ្ការីកស្គុសស្ពាយ លោកគួរទៅមើលអាស្រមរបស់ខ្ញុំ ។ ដែលមានកិន្នរ៉ៃស្រែកច្រៀងហើយដោយជុំវិញ ។

តាលា ច មូលា ច ផលា ច មេត្ត

រ៉ៃណ្ណ គន្ធេន ឧបេតរូបំ

តំ ភូមិភាគេបិ ឧបេតរូបំ

---

១. គិណ្ឌ្ដកាតិ អដ្ឋកថាយំ ទិស្សតិ ។

អហោ ភវ អស្សមំ មយ្ហ បស្ស ។

ដើមត្នោត ម៉ើមជ ំ ទ្ធ ូ ង ផ្ទៃ ណ ើ ត្រ ង ់ អ ា ស្រ ម ។ ប ស ់ ខ ្ ុ ំ ន ោ ះ
ម ា ន ផ ្ ទ ៃ ប ្ រ ក ប ដ ោ យ ព ណ ៌ និ ង ក ្ ិ ន ។ ល ោ ក គ ួ រ ទ ៅ ម ើ ល អ ា ស្ រ ម
ร ป ส ่ ข ุ ํ ฯ ฉ ล ป ร ก ป ด ว ย ก ู ม ิ ภ า ค ส ร ส ่ ส ว ย ง า ม น ะ ห ร ื อ ฯ

ผลา จ มูลา จ ปหูตเมตฺ
วณฺณน คนฺธน รเสนุปตา
อายนฺติ จ ลุทฺทกา ตํ ปเทสํ
มา เม ตโต มูลผลํ อหาสุํ ฯ

ផ្ទៃ ណ ើ ម ើ ម ណ ើ ត្រ ង ់ អ ា ស្ រ ម ป ส ่ ข ุ ํ ม ี ห ล ว ง ป ร ก ป
ด ว ย พ ณ ณ ์ ก ็ ด ี ก ล ิ ่ น ด ี ร ส ด ี พ ว ก พ ร า น ป ่ า ม ี ก ร ร ด ม า ก า ร ม า ก ป ร ะ เ ท ศ
น ะ ห ร ื อ ฯ ก ็ ม ิ ก ล ว ข ม ู ล ผ ล า ห า ร ท ี ่ อ า ศ ร ม ป ส ่ ข ุ ํ น ะ ห ร ื อ ฯ
ฉ ล ย ฯ

*ป ณ ฺ ณ า ป ท ท ั ง ้ ง น ะ ห ร ื อ ฯ ป ท ว า ** ขตฺตาย ** "ก ู ง ท ิ ส ข า ง ช ื ่ ง"*

*បានដល់ ផ្លូវទិសខាងជើង ។ បទថា **ខេមា** "**ខេមា**" បានដល់ ស្តីងដែលមានឈ្មោះយ៉ាងនោះ ។ បទថា **ហិមវន្តា បភាតិ** "**រមែងប្រាកដអំពីព្រៃហិមពាន្ត**" សេចក្តីថា រមែងហូរមកអំពីព្រៃហិម-ពាន្ត ។ បទថា **អហោ** "**ខ្ញុ**" ជានិបាត ប្រើក្នុងអត្ថនៃការអង្វរ ។ បទថា **ឧទ្ទាលកា**[1] "**ដើមរាជព្រ៉ីក្ស**" បានដល់ ដើមឈើដែលការពារខ្យល់ ។ បទថា **ឥ**[2]**ប្ជ**[2]**ិ**[2]**ាសាកិ**[2]**ីតំ**[2] "**ដែលមានកិន្នរស្រែកច្រៀងដោយជុំវិញ**" បានដល់ ដែលមានពួកកិន្នរនាំគ្នាចោមរោមដោយជុំវិញហើយ ស្រែកច្រៀងដោយសំឡេងដ៏ពីរោះ ។ បទថា **តាលា ច មូលា ច ផលា ច មេត្ត** "**ដើមត្នោត មើមដំឡូង ផ្លែឈើត្រង់អាស្រមរបស់យើងនោះ**" សេចក្តីថា ដើមត្នោតដែលគួរស្រឡាញ់ មើមដំឡូង ពោលគឺ មើមដំឡូង និងផ្លែឈើដែលសម្បូរដោយពណ៌ និងក្លិនជាដើមនៃដើមឈើទាំងនោះត្រង់អាស្រម

ឬ ២. ឥ

របស់យើងនោះ ។ បទថា **ឧហូតមេត្ត** "**ត្រង់អាស្រមរបស់ខ្ញុំមានច្រើន**" បានដល់ ផ្លែឈើច្រើនប្រភេទ រាស្មី និងមើមនៃដើមឈើមានច្រើនត្រង់អាស្រមរបស់ខ្ញុំនោះ ។ ដោយបទថា **មា មេ តតោ** "**កុំ (បានមកលួចមូលផលាហារ) ទៅអំពីអាស្រមរបស់ខ្ញុំឡើយ**" ព្រះរាជធីតាត្រាស់ថា "ពួកព្រានដ៏ច្រើនរមែងនាំគ្នាមកកាន់អាស្រមរបស់ខ្ញុំនោះ ក៏មូលផលាហារដែលមានរសឆ្ងាញ់ដ៏ច្រើន ដែលខ្ញុំនាំមកទុកក្នុងទីនោះ ក៏មានហើយ កាលខ្ញុំវាល់តែយឺតយូរ ពួកព្រានទាំងនោះក៏នឹងគប្បីលួចយកមូលផលាហារទៅ សូមពួកព្រានចូរកុំបានមកលួចមូលផលាហារបស់ខ្ញុំទៅអំពីទីនោះឡើយ ព្រោះហេតុនោះ បើលោកមានបំណងនឹងទៅជាមួយយើងក៏ចូរមក បើមិនមានបំណងនឹងទៅសោត យើងក៏នឹងទៅ" ។

តាបសបានស្តាប់ពាក្យនោះហើយ ដើម្បីនឹងឃាត់ព្រះរាជ-ធីតាទុករហូតបិតាខ្លួនមក ទើបពោលគាថាថា

[១៥] *បិតា មម មូលផលេសនំ គតោ*

ឥទានិ អាគច្ឆតិ សាយកាលេ

ឧភោ គច្ឆាមសេ អស្សមន្តំ

យាវ បិតា មូលផលតោ ឯតុ ។

បិតារបស់យើងទៅស្វែងរកមូលផលាហារ នឹងត្រឡប់មកក្នុងល្ងាចថ្ងៃនេះ យើងទាំង ២ នឹងទៅកាន់អាស្រមនោះបាន ក៏កាលបិតាត្រឡប់មកពីការស្វែងរកមូលផលាហារ ។

*បណ្តាបទទាំងនោះ បទថា **ឧភោ គច្ឆាមសេ** "**យើងទាំង ២ នឹងទៅ**" បានដល់ យើងទាំងពីរនាក់ ប្រាប់ឲ្យបិតាខ្ញុំបានជ្រាបហើយ ទើបនឹងទៅបាន ។*

លំដាប់នោះ ព្រះរាជធីតានោះគិតហើយថា "តាបសនេះ មិនដឹងថា យើងជាស្រី ព្រោះលោកចម្រើនធំធាត់មកក្នុងព្រៃប៉ុណ្ណោះ តែបិតារបស់តាបសនេះលុះឃើញយើង ក៏ដឹងមួយរំពេច គង់នឹង

សួរថា នាងមកធ្វើអ្វីក្នុងទីនេះ ហើយគង់នឹងយកចុងឈើច្រត់រាយ យើង សូម្បីសីស:របស់យើងក៏ត្រូវបែក យើងគួរនឹងទៅមុនក្នុងវេលាដែលបិតារបស់គេមិនទាន់មកល្អជាង ម្យ៉ាងទៀត នាទីក្នុងការមករបស់យើងក៏សម្រេចហើយ" ។ ព្រះរាជធីតានោះកាលនឹងប្រាប់ឧបាយនៃការដើរផ្ទូវដល់តាបសនោះ ទើបពោលគាថាក្រៅពីនេះថា

[១៦] *អញ្ញេ ពហូ ឥសយោ សាធុរូបា*
រាជីសយោ អនុមគ្គ វសន្តិ
តេយេវ បុច្ឆសិ មមស្សមន្តំ
តេ តំ នយិស្សន្តិ មមំ សកាសេ ។

ឥសី និងរាជឥសី អ្នកមានរូបល្អពួកជនៃទ្រង់ច្រើន រមែងនៅជិតផ្ទូវដោយលំដាប់ លោកគប្បីសួរដល់អាស្រមរបស់ខ្ញុំនឹងលោកពួកនោះចុះ លោកទាំងនោះនឹងនាំលោកទៅក្នុង

សម្ងាត់របស់ខ្ញុំ ។

*បណ្តាបទទាំងនោះ បទថា **រាជីសយោ “រាជឥសី”** សេចក្តីថា សម្ងាញ់អើយ យើងមិនអាចនៅយូរបាន ព្រោះពួកព្រាហ្មណ-ឥសី និងពួករាជឥសី អ្នកមានរូបស្អាតពួកដទៃ រមែងនៅជិតផ្ទូវដោយលំដាប់ គឺ នៅជិតផ្ទូវទៅអាស្រមរបស់យើង យើងនឹងប្រាប់គេទាំងនោះហើយនឹងទៅ លោកគប្បីសួរគេទាំងនោះចុះ គេទាំងនោះនឹងនាំលោកទៅកាន់សម្ងាត់យើងហើយ ។*

ព្រះរាជធីតានោះធ្វើឧបាយសម្រាប់ខ្លួននឹងគេចទៅយ៉ាងនេះហើយ ក៏ចេញចាកបណ្ណសាលា ពោលនឹងតាបសដែលកំពុងសម្ងឹងមើលនោះឯងថា “លោកត្រឡប់ទៅចុះ” ហើយបានទៅកាន់សម្ងាត់ពួកអាមាត្យ តាមផ្ទូវដែលមកនោះឯង ។ ពួកអាមាត្យទាំងនោះក៏បាននាំព្រះរាជធីតានោះទៅកាន់បន្ទាយហើយ ក៏ទៅដល់ក្រុងពារ-ណសីដោយលំដាប់ ។ ក្នុងថ្ងៃនោះឯង សូម្បីស្តេចសក្ក្ទេវរាជក៏

ទ្រង់សប្បាយចិត្ត ញ៉ាំងក្ងៀងឲ្យធ្លាក់ទូទៅទាំងដែន ។ តអំពីនោះ
មក ជនបទក៏មានកិក្ឃ្ជាសម្ជរ ។ ត្រាព្រះរាជធីតានោះត្រឡប់ទៅ
ហើយប៉ុណ្ណោះ សេចក្ដីក្ដៅក្រហាយក៏កើតឡើងក្នុងរាងកាយរបស់
ឥសិសិង្គតាបស ។ តាបសនោះញាប់ញ័រ ចូលទៅកាន់បណ្ណសាលា
យកសំពត់ដណ្ដប់រាងកាយ ដេកសោកសៅ ។

ក្នុងវេលាល្ងាច ព្រះពោធិសត្វត្រឡប់មកសម្ងីងរកមើលមិន
ឃើញបុត្ត ទើបគិតថា "គេទៅក្នុងទីណាហ្ន៎" ទើបដាក់សង្រ្ដែកចុះ
ចូលទៅកាន់បណ្ណសាលា ក៏ឃើញគេដេក សួរថា "កូនអើយ កូន
កើតអ្វី?" ស្ដាបខ្នងសួរដោយគាថា ៣ គាថាថា

[១៧] ន តេ កដ្ឋានិ ភិន្នានិ ន តេ ឧទកមាហតំ
អគ្គិបិ តេ ន ឌាសិតោ កិន្នុ មន្ទោ ឈាយសិ ។

អុសកូនក៏មិនពុះ ទឹកកូនក៏មិនជង់ជាក់ សូម្បីភ្លើងកូនក៏
មិនដុត កូនសោកសៅក្នុងរឿងអ្វីហ្ន៎ ។

ភិន្នានិ ភជ្ជានិ ហុតោ ច អគ្គិ

ឥមានីបិ តេ សមិតា សព្រហ្មចារី

ឧបឋ្ឋា មយ្ហំ ឧទកញ្ច ហោតិ

រមសិ តុវំ ព្រហ្មកូតោ ឧរត្ត ។

ម្នាលកូនអ្នកប្រព្រឹត្តដ៏ប្រសើរ កាលមុន អុសកូនក៏ពុះ ភ្លើងកូនក៏ដុត សូម្បីភ្លើងសម្រាប់អាស្រ័យកូនក៏ចាត់ចែងបាន តាំងកូនក៏រៀបចំ ទឹកក៏កូនជងទុកឲ្យយើង ។

អភិន្ទកជ្ជាសិ អានាកតោទកោ

អហាសិតគ្គីសិ អសិទ្ធកោជនោ[1]

ន មេ តុវំ អាលបសិ មមជ្ជ

ឧដ្ឋ ឧ ភ ី ចេតសិកញ្ច ទុក្ខំ ។

ថ្ងៃដទៃ កូនជាអ្នកប្រសើររុងរឿងល្អ ថ្ងៃនេះកូនមិនពុះអុស

១.ឍ. អហាបិតគ្គីសិ អសិទ្ធកោជនោ ។ ម. អហាបិតគ្គីបិ អសិជ្ជកោជនោ ។

មិនជងទឹក មិនជុតភ្លើង មិនចាត់ចែងគ្រឿងបរិភោគទុក មិនសាកសួរយើង អ្វីរបស់កូនវិនាសឬ ឬថា កូនមានទុក្ខអ្វីក្នុងចិត្ត ។

*បណ្តាបទទាំងនោះ បទថា **កិន្ន្ទានិ** "ពុះ" បានដល់ អុសដែលពុះនាំមកអំពីព្រៃ ។ បទថា **ន ហាសិតោ** "**ក៏មិនជុត**" បានដល់ មិនធ្វើឲ្យឆេះ ។ បទថា **កិន្ន្ទានិ** "**ក៏ពុះ**" សេចក្តីថា កាលមុន វេលាដែលយើងមក កូនក៏បានពុះឧសទុករៀបរយហើយ ។ បទថា **ហុតោ ច អគ្គិ** "**ភ្លើងកូនក៏មិនជុត**" សេចក្តីថា ភ្លើងសម្រាប់បូជាកូនក៏មិនជុត ។ បទថា **តបនី** "**ភ្លើងសម្រាប់អាស្រ័យ**" នយ៉ថា សូម្បីភ្ជក់ភ្លើង គឺ ភ្លើងសម្រាប់អាស្រ័យ កូនក៏ត្រៀមទុក ។ បទថា **ឋបិ** "**តាំង**" សេចក្តីថា ចំណែកតាំងប្រចាំសម្រាប់ទីនៅរបស់យើង កូនក៏បានចាត់ចែងទុកហើយដែរ ។ ពាក្យថា **ឧទកញ្ច** "**ទឹក**" សេចក្តីថា សូម្បីទឹកសម្រាប់លាងជើង កូនក៏តាំងទុកជូច*

គ្នា ។ បទថា **ព្រហ្មកូតោ** *"ជាអ្នកប្រសើរ"* សេចក្ដីថា ក្នុងថ្ងៃដទៃ អំពីថ្ងៃនេះ សូមឪ្យកូនជាអ្នកប្រសើររុងរឿងនៅក្នុងអាស្រមនេះ ។ បទថា **អកិន្ទ្ធកដ្ឋោសិ** *"មិនពុះឧស"* បានដល់ ឥឡូវនេះ ថ្ងៃនេះ កូនមិនពុះឧស ។ បទថា **អសិទ្ធកោជនោ** *"មិនចាត់ចែងនូវគ្រឿងបរិភោគទុក"* សេចក្ដីថា ត្រាវ ដំឡូង ឬស្ជ៊ីកឈើអ្វីៗ ដែលកូនចម្អិនទុកសម្រាប់យើងមិនមានឡើយ ។ បទថា **មមជ្ជ** *"ថ្ងៃនេះ"* សេចក្ដីថា កូនរបស់ពុកអើយ ថ្ងៃនេះកូនមិនបានសួរពុកឡើយ ។ ដោយបទថា **នជ្ជំ នុ ក៏** *"របស់អ្វីកូនវិនាសឬ"* នេះ ព្រះពោធិសត្ត សួរកូនថា "វត្ថុអ្វីរបស់កូនវិនាសឬ ឬថា កូនមានសេចក្ដីទុក្ខក្នុងចិត្តរឿងអ្វី ចូរប្រាប់នូវហេតុនៃការដេកសោកសៅឲ្យពុកបានជ្រាបផង?" ។

តាបសនោះស្ដាប់ពាក្យរបស់បិតាហើយ កាលនឹងពោលដល់ហេតុការណ៍នោះឲ្យជ្រាបទើបប្រាប់ថា

[១៨] ឥជ្ឌាគមា ជដិលោ ព្រហ្មចារី

សុទ្ទស្ស្ សនេយ្យ សុតនូ ១ នេតិ

នេវាតិទីឃោ ន ១ បនាតិរេស្ស

សុកណ្ហកណ្ហច្ឆ ១ នេហិ ១ ១ ១ ១ ១

ជដិលអ្នកប្រព្រឹត្តព្រហ្មចារ្យមកក្នុងអាស្រមនេះ មានរូប

ពាងគួរមិលមើល ចង្កេះតូច មិនខ្ពស់ពេក មិនខ្ទៅពេក រស្មី

ល្អស្អាត មានសីសៈគ្របដណ្ដប់ដោយសក់ដ៏ខ្ទៅស្រិល មិន

មានពុកមាត់ ។

អមស្ស្ជ្ជ ១ ១ ១ ១ ១ ១ ១ ១

អ ១ ១ ១ ១ ១ ១ ១ ១

ទ្ធ ១ ១ ១ ១ ១ ១ ១ ១

សុ ១ ១ ១ ១ ១ ១ ១ ១

បួសមិនយូរ មានគ្រឿងប្រដាប់ជារូបជើងចាត្រនៅត្រង់ក

មានពក ២ ក្ដីផ្ទៃកដូចផ្ទៃទម្ងាប់មាស កើតល្អហើយត្រង់ទ្រូង ។

មុខញ្ច តស្ស ភុសទស្សនេយ្យំ

ឧណ្ណាសុ លម្ពន្តិ ច ភុញ្ជិតគ្គា

តេ ជោតរេ ចរតោ មាណវស្ស

សុតញ្ច យំ សំយមានំ ជជានំ ។

ផ្ទៃមុខរបស់ជដិលនោះគួរមើលក្រែណាស់ មានប្រជាប់ព្យួរត្រង់ត្រចៀកទាំងសងខាង កាលជដិលនោះឯងដើរទៅមកគ្រឿងប្រជាប់ទាំងនោះរមែងក្ដីចិញ្ចាច ។ ខ្សែសយព័ន្ធជជាក៏ស្អាតចិញ្ចាចចិញ្ចែង ។

អញ្ញា ច តស្ស សំយមានិ ចតស្សោ

នីលា ចីតា លោហិតកា ច ឯតា

តា សំសរេ ចរតោ មាណវស្ស

ឥរិជិសង្ឆារិវ ចាវុសម្ហិ ។

គ្រឿងប្រដាប់ដទៃ ៤ យ៉ាងរបស់ជដិលនោះ មានពណ៌ ១២ លឿង ក្រហម ទ្រីងស កាលជដិលនោះដើរទៅមកគ្រឿងប្រដាប់ទាំងនោះរមែងបញ្ចេញសំឡេង ដូចហ្វូងសត្វមេភ្ជៀងយំ ក្នុងវេលាភ្ជៀងធ្លាក់ដូច្នោះ ។

ន មេឆលំ មុញ្ចមយំ ធារេតិ

ន សន្ធរេ ឆោ បន បញ្ចជស្ស

តា ជោតរេ ជង្ឃនន្ត្ថរេ វិលគ្គា

សតេរិតា វិជ្ជុរិវន្ត្ថលិក្ខេ ។

ជដិលនោះ មិនបានក្រវាត់គ្រឿងចងចង្កេះដែលធ្វើដោយស្នាយាប្ចង់ មិនបានស្ងៀកសំពត់ដែលធ្វើដោយសំបកឈើដូចរបស់ពួកយើងទេ សំពត់ទាំងនោះនៅត្រង់ចន្លោះនៃស្មង ភ្ជីផ្ទៃក ចែងចាំងដូចផ្ទៃកបន្ទោរក្នុងអាកាស ។

អ១ីលកានិ ច អវណ្ណកានិ

ហេដ្ឋា នក្យា កដិសមោហិតានិ

អយដ្ដិតា និចកីឡ្ដ កវេន្ដិ

ហន្ដ្ដាត ក៏ រុក្ខផលានិ តានិ ។

ជដិលនោះ មានផ្ទៃឈើមិនទុំ មិនមានទង ជាប់នៅត្រង់ចង្ហេះក្រោមនាគ៏ មិនប៉ះគ្នា ក៏ធ្វើជាលែ្ងងជានិច្ច បពិត្រលោកពុក ផ្ទៃឈើទាំងនោះឈ្មោះផ្ទៃអ្វី ។

ជដា ច ឥសៃ្ស ឥុសទ្ទសៃ្ស្ទនេយ្យា

ឧបេសតំ ដៃ្ជ្ជ ឥតគ្ដ្ដ ឥសុគន្ធ

ទ្ធ ជ សិ ដ ១ ១ ១

ផងចុះ ។

យទា ច សោ បកិរតិ តា ជដាយោ

រ៉ាណ្ណេ គន្ធេ ឧបេតរូបា

ទីលុប្ផលំ ឯ តសមេ តិ តំ

តថេ សំ ឯ យតិ ឯ ន ស្ស ្ យ ្ ម ្ ម ្ ។

ទ ិ ង ក ្ ន ង ព ្ (ណ ា ជ ដ ិ (ន ោ ះ (ំ (((

ពណ៌សម្បុរត្រង់កាយរបស់ខ្ញុំទេ សម្បុរកាយរបស់ជដិលនោះ ត្រូវខ្យល់បក់ប៉ះហើយ រមែងក្រអូបផ្សាយទៅ ដូចព្រៃឈើ ដែលមានផ្ការីកក្នុងរដូវក្តៅដូច្នោះ ។

និហន្ត្វ សោ រុក្ខផលំ ឧបាគ្យ
សុចិត្តរូបំ រុចិរំ ទស្សនេយ្យំ
ខិត្តញ្ច តស្ស ឧនរតិ ហត្ថំ
ហន្ត្វាត ភី រុក្ខផលំ នុ ខោ តំ ។

ជដិលនោះវាយផ្លែឈើដែលវិចិត្រល្អគួរមើលទៅលើផែនដី និងផ្លែឈើដែលជ្រុះទៅហើយ រមែងត្រឡប់មកកាន់ដៃរបស់គេវិញ ចាត់ត្រលោកពុក ផ្លែឈើនោះឈ្មោះផ្លែអ្វីហ្ន៎ ។

ទន្ត្វ ច តស្ស កុសទស្សនេយ្យា
សុទ្ធា សមា សង្ខវរូបបន្ត្ថា
មនោ ឧសាទេន្ត្ថ ១ រិយមានា

ន ហិ ន្ទូន សោ សាកមទាទិ តេហិ ។

មួយទៀត ធ្មេញរបស់ជដិលនោះគួរមើលក្រៃពេក សស្អាតរាបស្មើគ្នាដូចសង្ខ៖ដែលខាត់ល្អហើយ កាលជដិលបើកមាត់ហើយ រមែងញ្ចាំងចិត្តខ្ញុំឲ្យជ្រះថ្លា ជដិលនោះគង់មិនបានទំពាស៊ីបន្ទែដោយធ្មេញទាំងនោះដោយពិត ។

អកក្ខសំ អគ្គទ្ឍិតំ មុហុំ មុទុំ

ខជ្ជំ អនុទ្ធតំ អចបលមស្ស ភាសិតំ

រុទ្ធ មនុញ្ញ ករវីកសុស្សរ

ហទយង្គមំ រញ្ជយតេវ មេ មនោ ។

ពាក្យនិយាយរបស់គេមិនគ្រោតគ្រាត មិនក្ងាត់ ពីរោះទន់ភ្ងន់ ត្រង់ មិនរាយមាយ មិនកោកកាក សំឡេងរបស់គេជាគ្រឿងចងចិត្ត ចាប់ចិត្ត ដូចសំឡេងសត្វករវៀក នាំចិត្តរបស់ខ្ញុំឲ្យត្រេកអរខ្លាំងណាស់ ។

ពិន្ទុសរ្យេ នាតិវិសរ្យជ្ជាកេ្ស

ន ទូន សជ្ឌាយបតិបជ្ជយុត្តោ

ឥច្ឆាមិ ខោ តំ បុនទេវ ទដ្ឋុំ

មិត្តញ្ចិ មេ មាណវាហុ បុរត្ថា ។

សំឡេងរបស់គេមួល ជាពាក្យមិនកេ្ជាះកេ្ជាយ មិនប្រកប ដោយសំឡេងរង្ហ៉ូ ខ្ញុំប្រាថ្នានឹងបានឃើញគេទៀត ព្រោះជ-ដិលនោះជាមិត្តរបស់ខ្ញុំអំពីមុន ។

សុសន្ធិ សព្ពត្ត វិមដ្ឋិមំ រណំ

បុថុ សុជាតំ ខរបត្តសន្ធិកំ

តេនេវ មំ ខត្តិយាន មាណវោ

វិវរិយ ខ,ុ ជយនេន ជីឡយិ ។

ជំហៅត្រង់ចន្ទោះក្ងៀ រលើងស្អាតក្នុងទីទាំងពួង ធំ កើត ល្អហើយ ស្រដៀងនឹងត្រចកឈូក ជដិលនោះពោលពីលើខ្ញុំ

ដោយដំបៅនោះឯង ប្រើត្រគាកបើកក្ដៅហើយសង្ហត់ ហើយ

គាបដោយជើង ។

តបន្តិ អាកន្តិ វិរោចរេ ច

សតេរិតា វិជ្ជុរិវន្ត្ពលិក្ខេ

ពាហា មុទូ អញ្ជនលោមសទិសា

វិចិត្រវដ្ដង្គុលិកស្ស សោភរេ ។

ស្នើផ្ស្ងាយចេញអំពីកាយជដិលនោះ រមែងភ្លឺផ្ទេកុងរឿង

ចែងចាំងដូចផ្ទេកបន្ទោរក្នុងអាកាស ដូច្នោះ មួយទៀត ដៃ

ទាំងពីររបស់ជដិលនោះទន់ល្ងន់ មានរោមដូចរោមផ្ការអញ្ជ័ន

សូម្បីដៃទាំងពីររបស់ជដិលនោះ ក៏ប្រកបដោយម្រាមដ៏រៀវ

វិចិត្រល្អ ។

អកក្ខសង្ហោ ន ច ទីឃលោមោ

ន១ស្ស ទីឃា អបិ លោហិតគ្ហា

មុទូហិ ពាហាហិ បលិសេ្សជន្តោ

កល្យាណរូបោ រមយ[1] ឧបដ្ឋហិ ។

ជដិលនោះ មានអវយវៈមិនរដិបរដុប មានរោមមិនវែង ក្រចកវែង ចុងមានពណ៌ក្រហម ជដិលនោះមានរូបរាងស្អាត ឱបរឹតខ្ញុំដោយដៃទាំងពីរដ៏ទន់ បម្រើឲ្យរីករាយ ។

ទុមសេ្ស តូលូបនិកា បកសេ្សរា

សុវណ្ណកម្ពូតលវដ្ដសុច្ឆវី

ហត្ថា មុទូ តេហិ មំ សំផុសិត្វា

ឥតោ គតោ តេន មំ ទហន្តិ តាត ។

បពិត្រលោកពុក ដៃទាំងពីររបស់ជដិលនោះទន់ស្រេរជ្រៀងនឹងសំឡី ស្អាតភ្លឺផ្លេកផ្ទៃបាតដៃរលើបរលោងដូចសន្ទ្ធីកមាស ជដិលនោះសង្ហត់ខ្ញុំដោយដៃទាំងពីរនោះហើយ ក៏ចេញអំពីទី

១.ម. មយ្ហំ ។

នេះ រមែងធ្វើឲ្យខ្ញុំក្តៅដោយសម្ងួសៗនោះ ។

ន ទ្ទូន សោ ខារិវិធំ អហាសិ

ន ទ្ទូន សោ កដ្ឋានិ សយំ អកញ្ជិ

ន ទ្ទូន សោ ហន្តិ ទមេ កុហ៎ាយ

ន ចិ ស្ស ហត្ថេសុ ទ្ទិលានិ អត្ថិ ។

ជដិលនោះមិនបានន្ទាំសង្ត្រែកមក មិនបានកាច់ឧសខ្ជួនឯង មិនបានកាប់ដើមឈើដោយកាំបិត សូម្បីដៃទាំង ២ របស់ជដិលនោះក៏មិនក្រិន ។

អច្ឆ្ជ្ជ ទ្ទ ១ ១ ១

ខ្ញុំយ៉ុំបានទាំជដ៏លនោះឲ្យជាជំជ្ជ គេទើបពោលនឹងខ្ញុំថា សូមលោកជួយធ្វើឲ្យខ្ញុំមានសេចក្ដីសុខចុះ ខ្ញុំទើបជួយធ្វើឲ្យគេមានសេចក្ដីសុខ និងសេចក្ដីសុខក៏កើតមានដល់ខ្ញុំដោយការធ្វើនោះ បពិត្រលោកជាព្រហ្ម គេបានប្រាប់ខ្ញុំថា ខ្ញុំមានសេចក្ដីសុខហើយ ។

អយញ្ច តេ មាលុវបណ្ណសន្ថតា
វិកិណ្ណរូបាវ មយា ច តេន ច
កិលន្ត្ករូបា ឧទកេ រមិត្វា
ឧនប្ជ្ជនំ បណ្ណកុដី រជាម ។

ក៏ទីដែលក្រាលដោយស្លឹកឈើទាលរបស់លោកនេះ ពត់-ភយហើយ ព្រោះខ្ញុំ និងជ៏ដ៏លនោះ យើងទាំងពីរនៀយហត់ហើយ ក៏រីកភយនឹងគ្នាក្នុងទឹក ហើយចូលទៅកាន់កុដ៏ដែលប្រក់ជ៏ងដោយស្លឹកឈើរៀយៗ ។

ន មជ្ជ មន្ទ្រា បជិកន្ត្ថ តាត

ន អគ្គិហុត្តំ នបិ យញ្ញ តត្រ

ន ចាបិ ត្ថ មូលផលានិ ភុញ្ជ

យាវ ន បស្សាមិ តំ ព្រហ្មចារី ។

បពិត្រលោកពុក ថ្ងៃនេះ មន្ត្រទាំងឡាយរមែងមិនប្រាកដ ដល់ខ្ញុំទ្បើយ ការបូជាភ្លើងខ្ញុំមិនពេញចិត្តទ្បើយ សូម្បីការបូជាយញ្ញក្នុងទីនោះ ខ្ញុំក៏មិនពេញចិត្ត ដរាបណាដែលខ្ញុំនៅមិនបានឃើញជដិលអ្នកប្រព្រឹត្តព្រហ្មចារ្យ ខ្ញុំនឹងមិនបរិភោគមូលផលាហារបស់លោកពុកទ្បើយ ។

អន្ធា បជានាសិ តុវំបិ តាត

យស្សុ ទិសាយំ វសតេ ព្រហ្មចារី

តំ មំ ទិសំ ចាបយ តាត ទ្ធិប្ប

មា ត្ថ អហំ អមរិមស្ស្ដមម្ហិ ។

បពិត្រលោកពុក សូម្បីលោកពុករមែងដឹងដោយពិតថា ជដិលអ្នកប្រព្រឹត្តព្រហ្មចារ្យនៅទិសណា សូមលោកពុកនាំខ្ញុំទៅឲ្យដល់ទិសនោះដោយរហ័សចុះ ខ្ញុំកុំបានស្ងាប់ក្នុងអាស្រមរបស់ពុកឡើយ ។

វិចិត្រផុល្លញ្ចិ[1] វនំ សុតំ មយា
ទិជាកិយុដ្ឋំ ទិជសង្ឆ្យសេវិតំ
តំ មំ វនំ ១ាបយ តាត ១ិប្ប
បុ១ តេ ១ាណំ ១ិជហាមិ អស្សមេ ។

បពិត្រលោកពុក ខ្ញុំបានស្តាប់ដល់ព្រៃឈើដ៏វិចិត្រ មានផ្ការីក គ៉ីកកងទៅដោយសំឡេងសត្វយំ មានហ្វូងបក្សីអាស្រ័យនៅ សូមលោកពុកជួយនាំខ្ញុំទៅ ឲ្យដល់ព្រៃឈើនោះដោយរហ័សចុះ មុនទ១ងខ្ញុំត្រូវលះបង់ជីវិតក្នុងអាស្រមរបស់លោក

១.ម. វិចិត្រ១ុប្ផ ១ិ ។

ពុក ។

បណ្តាបទទាំងនោះ បទថា **ឥជាគមា** "**មកក្នុងអាស្រមនេះ**" បានដល់ បពិត្រលោកពុក ជដិលអ្នកប្រព្រឹត្តព្រហ្មចារ្យមកកាន់អាស្រមនេះ ។ បទថា **សុទស្សនេយ្យា** "**មានរូបរាងគួរមើល**" បានដល់ មានរូបរាងគួរគយគន់ ។ បទថា **សុតនូ** "**ចង្កេះរៀវតូច**" បានដល់ មានរូបរាងល្អ មិនស្គមពេក មិនធាត់ពេក ។ បទថា **វិនេតិ** "**រស្មីល្អស្អាត**" សេចក្តីថា រមែងញ៉ាំងអាស្រមឲ្យដល់ គឺឲ្យពេញទៅដោយរស្មីកាយរបស់ខ្លួន ហាក់ដូចជាអាស្រមមានតែរស្មីតែមួយ ។ បទថា **សុកណ្ហកណ្ហច្ឆទនេហិ ភោតោ** "**មានសីសៈគ្របដណ្តប់ដោយសក់ពណ៌ខ្មៅស្រិល**" សេចក្តីថា បពិត្រលោកពុក សីសៈរបស់អ្នកជ័ចម្រើននោះ មានពណ៌ខ្មៅស្រិល ដោយសរ-សៃសក់ដែលមានពណ៌ស្រដៀងនឹងសត្វកន្ទង់ ព្រោះដណ្តប់ដោយពណ៌ខ្មៅស្អាត រមែងប្រាកដដូចជាធ្វើដោយកែវមណីដែលខាត់ល្អ

ហើយ ។ បទថា **អមសារ្ជាតោ** "**មិនមានពុតមាត់**" បានដល់ ពុកមាត់របស់គេមិនប្រាកដ គឺ នៅកំលោះ ។ បទថា **អបុរាណវណ្ណី** "**បួសមិនយូរ**" បានដល់ បួសមិនទាន់យូរ ។ បទថា **អាធារូប-ញ្ចោ បនស្ស ករណ្ដ** "**មានគ្រឿងប្រដាប់ជារូបជើងបាត្រនៅត្រង់ក**" នេះ តាបសពោលសំដៅដល់កែវមុក្តាថា ក៏ជដិលនោះមានគ្រឿងប្រដាប់ស្រដៀងនឹងជើងបាត្រ សម្រាប់ប្រើដាក់ការជនៈកិច្ចារបស់ពួកយើងនៅត្រង់ក ។ ដោយបទថា **ឧរ** "**ពក**" នេះ តាបសពោលសំដៅដល់ដោះទាំងសងខាង ។ បទថា **ឧរេ សុជាតា** "**កើតល្អហើយត្រង់ទ្រូង**" បានដល់ កើតល្អហើយឦ្ជ ។ ចាប:ថា **ឧរតោ** ដូច្នេះក៏មាន ។ បទថា **បកស្សរ** "**ស្អាត**" បានដល់ ប-រិបូណ៌ដោយរស្មី ។ ចាប:ថា **បកាសរ** ដូច្នេះក៏មាន សេចក្ដីថារមែងភ្លឺស្វាង ។ បទថា **ឥសទ្ទ្ យ ន យ្យ ំ** "**គួរមើលក្រៃពេក**" គឺ គួរមើលក្រៃលែង ។ ដោយបទថា **ឥ ពា ត ត ្ គ ្ គ ា** "**ប្រដាប់ត្រចៀក**"

នេះ តាបសពោលសំដៅដល់ទង្គ្រៀក ។ បទថា **សុត្តញ្ច "ខ្សែ**
ចង" សេចក្ដីថា ខ្សែចងត្រង់ជជារបស់ជដិលនោះ រមែងក្លាយជាចង
ចាំង ។ ដោយបទថា **សំយមានិ ចតសេ្ស "គ្រឿងប្រដាប់ដទៃទៀត**
៤ យ៉ាង" នេះ លោកសម្ដែងដល់គ្រឿងប្រដាប់ ៤ យ៉ាងដែល
ធ្វើដោយកែវមណី មាស កែវប្រពាល និងប្រាក់ ។ បទថា **តា**
សំសារ "គ្រឿងប្រដាប់ទាំងនោះដូចជាបញ្ចេញនូវសំឡេង" នយ
ថា គ្រឿងប្រដាប់ទាំងនោះរមែងឮសំឡេង ដូចហ្វូងសត្វមេភ្ជៀង
យំក្នុងវេលាដែលភ្ជៀងធ្លាក់ ។ បទថា **មេខលំ "គ្រឿងចងចង្កេះ"**
បានដល់ ខ្សែចងចង្កេះសម្រាប់មនុស្សស្រី ចាប:ក៏ដូច្នេះដូចគ្នា ។
បទនេះលោកពោលសំដៅដល់សំពត់សំបកឈើប្រភេទខ្លះសម្រាប់
ស្លៀក ។ បទថា **ន សន្ត "មិនបានស្លៀក"** បានដល់ មិនប្រើ
សំពត់សំបកឈើ ។ មានពាក្យដែលលោកពោលអធិប្បាយទុកថា
បពិត្រលោកពុក ជដិលនោះមិនបានប្រើសំពត់ដែលធ្វើដោយស្នា

យាបូង ឬធ្វើដោយសំបកឈើ ដូចរបស់ពួកយើងឡើយ តែជដិលនោះប្រើសំពត់សរសៃឈើប្រភេទខ្លះពណ៌ាមាស ។ បទថា **អ១ិ-លកានិ**[1] **"មិនទុំ"** បានដល់ មិនទុំ មិនអាក្រក់ ។ បទថា **កដិ-សមោហិតានិ "ជាប់នៅខាងក្រោមចង្កេះ"** បានដល់ ចងជាប់នៅត្រង់ចង្កេះ ។ បទថា **និចូកីឡ្ យ កវេន្ត "ធ្វើនូវល្បែងជានិចូ"** គឺ សូម្បីមិនប៉ះគ្នា តែក៏នៅលេងជានិចូ ។ បទថា **ហន្ត្ថាត "បពិត្រលោកពុក"** បានដល់ បពិត្រលោកពុកដ៏ចម្រើន ។ ដោយបទថា **ក៏ រុក្ខ១ាលានិ "ផ្លែឈើទាំងនោះឈ្មោះផ្លែឈើអ្វី"** នេះ តាបសពោលសំដៅដល់ផ្លែវមណី និងសំពត់ភ្ជាប់ថា ផ្លែឈើទាំងនោះជាផ្លែឈើប្រភេទណា ដែលចងជាប់ខាងលើចង្កេះរបស់មាណពនោះ ។ បទថា **ជជា "ផ្ទួងសក់"** តាបសពោលសំដៅផ្ទួងសក់ដែលសៀតដោយរតនៈជារបៀបជុំវិញជជា ។ បទថា **រ១ិតគ្ត "មានចុងធ"**

ប៊ីដក. ១. អ១ីលកានិ ។

ជានដល់ មានចុងងទ្បើង ។ បទថា **ទ្ធជាសិរោ** "**មានសីសៈដែលញ្ជែកដោយណ្ណជាពីរចំណែក**" ជានដល់ សីសៈរបស់ជដិលនោះ មានជដាដែលចងជាពីរចំណែកដោយណ្ណ ។ បទថា **តថា** "**យ៉ាងនោះ**" សេចក្ដីថា តាបសបំណងថា "ជដារបស់ខ្ញុំ លោកពុកមិនជានចង់ឲ្យដូចជដារបស់មាណពនោះទ្បើយ ឱហ្ន៎ សូមឲ្យជដាសូម្បីរបស់ខ្ញុំចូរជាដូច្នោះចុះ" ដូច្នេះហើយ ទើបជានពោល ។ បទថា **ឧបេតរូបា** "**ដែលប្រកប**" ជានដល់ ក៏ជដាមានសភាពដែលប្រកបហើយ ។ បទថា **ភ្ជាតសមេវិតំវ** "**ដូច... ដែលត្រូវខ្សាស់ចាក់ប៉ះដូច្នោះ**" សេចក្ដីថា ក្ងិនក្រអូបរមែងផ្សាយទៅក្នុងអាស្រមនៃព្រៃសណ្ឋៈនេះ ដូចផ្ការខ្ជាលខ្ចៀវដែលត្រូវខ្សាស់ចាក់ប៉ះផ្សាយក្ងិនទៅដូច្នោះ ។ បទថា **នេតាទិសោ** "**មិនដូចគ្នា**" សេចក្ដីថា បពិត្រលោកពុក ពណ៌សម្បុរត្រង់សរីរៈរបស់ជដិលនោះទាំងគួរស្រឡាញ់ ទាំងមានក្ងិនក្រអូបផង មិនដូចពណ៌សម្បុរត្រង់កាយរបស់ខ្ញុំទេ ។

បទថា **អគ្គគិម្ហេ "ខាងចុងរដូវក្តៅ"** បានដល់ ក្នុងសម័យដើមនៃរដូវក្ដៀង ។ បទថា **ក៏ រុក្ខផលំ នុ ខោ តំ "ផ្លែឈើនោះឈ្មោះ ផ្លែអ្ហីហ្ន"** បានដល់ ផ្លែឈើនោះជាផ្លែនៃដើមឈើអ្ហីហ្ន ។ បទថា **សង្ខវរូបមន្ថ "សង្ខដែលខាត់ល្អហើយ"** បានដល់ មានចំណែកប្រៀបស្មើដោយសង្ខដែលខាត់ល្អហើយ ។ បទថា **ន នូន សោ សាកមទាទិ តេហិ[1] "ជដិលនោះ គង់មិនបានទំពាបន្ទែដោយធ្មេញទាំងនោះដោយពិត"** សេចក្ដីថា មាណពនោះ មិនបានទំពាស៊ីបន្ទែ និងផ្លែឈើដោយធ្មេញទាំងនោះ ដូចជាពួកយើងដោយពិត ។ ក៏តាបសនោះរមែងសម្ដែងថា "ព្រោះកាលពួកយើងនាំគ្នាទំពាស៊ីវត្ថុទាំងនោះ ធ្មេញទើបមានពណ៌ដូចកក់ជាប់ទៅដោយមន្ទិល" ។ បទថា **អកក្កសំ "មិនអាក្រក់"** សេចក្ដីថា បពិត្រលោកពុក ពាក្យសម្ដីរបស់តាបសនោះមិនគ្រោតគ្រាត មិនភ្ជាត់ សូម្បីនិយាយរឿយៗ

ឋិដក. ន ហិ នូន សោ សាកមទាទិ តេហិ ។

ក៏ពីរោះ ទន់ភ្ងន់ ព្រោះពីរោះផ្អែមល្ហែម ជាសម្ដីត្រង់ ព្រោះមិនកុហក ជាពាក្យមិនរោយរាយ ព្រោះមិនរាយមាយ ជាពាក្យមិនយ្យៀងយ្ងាត ព្រោះជាពាក្យហ្មត់ចត់គង់មានហេតុផល ។ បទថា **រុទំ "សំឡេងរបស់គេ"** សេចក្ដីថា សូម្បីសំឡេងគេដែលនិយាយហើយ រមែងចាប់ចិត្ត ជាសំឡេងល្អ ពីរោះស្រទន់ ដូចសំឡេងសត្វកវរ៉ាកដូច្នោះ ។ បទថា **រញ្ជយតេវ "នាំ... ឲ្យត្រេកអរក្រៃ-លែង"** សេចក្ដីថា ចិត្តរបស់ខ្ញុំរមែងត្រេកអរក្រៃលែង ។ បទថា **ពិន្ទុសរ្យេ "សំឡេងរបស់គេមិនក្ងាះក្ងាយ"** ចានដល់ សំឡេងរបស់គេមួយៗ ។ បទថា **មាណវាហុ "ជដិលនោះជា"** សេចក្ដីថា ព្រោះជដិលនោះចានជាមិត្តរបស់ខ្ញុំមុន ។

បទថា **សុសន្ធិ សពូត្ត វិមដ្ឋិមំ រណំ "ដំណៅដែលជិតស្ទ្ធ-យ៉ាងល្អ ហើយរលើងស្អាតក្នុងទីទាំងពួង"** សេចក្ដីថា បពិត្រលោកពុក ដំណៅមួយៗ ដែលមាននៅត្រង់ចន្ទោះក្ងៀរបស់មាណពនោះ

ដំបៅនោះមានស្នាមជិតស្និទ្ធល្អ សម្ងួសល្អ រលីងស្អាតក្នុងទីទាំងពួង គឺ រលីងដោយជុំវិញស្រដៀងនឹងដំបៅដែលមានសិលា: ។ បទថា **ឋុ** "ធំ" បានដល់ ធាត់ធំ ។ បទថា **សុជាតំ** "**កើតល្អ**" **ហើយ**" បានដល់ តាំងនៅសមគួរល្អ ។ បទថា **ទ្ធរបត្តសន្ទិកំ** "**ស្រដៀងត្រចកឈូក**" បានដល់ ស្រដៀងនឹងផ្ការ៉ាយ ។ បទ ថា **ឧត្តរិយាន** "**ទ្រោប**" បានដល់ ពោប គឺ សង្ហត់ចុះ ។ បទ ថា **ឋីឡយិ** "**សង្ហត់ចុះ**" បានដល់ សង្ហត់គាបទុក ។ បទថា **ត-ឋន្តិ** "**រស្មី**" សេចក្ដីថា រស្មីមានពណ៌ដូចមាសជះចេញអំពីសរីរៈ របស់មាណពនោះ រមែងចែងចាំងរុងរឿង ។ បទថា **ពាហា** "**ដៃ ទាំងពីរ**" បានដល់ សូម្បីដៃទាំងពីររបស់ជដិលនោះក៏ទន់ល្ងន់ ។ បទថា **អញ្ជនលោមសទិសា** "**មានរោមដូចរោមនៃផ្ការ៉ាអញ្ជ៉ន**" គឺ ប្រកបព្រមដោយរោមទាំងឡាយ ដូចរោមនៃផ្ការ៉ាអញ្ជ៉ន ។ បទថា **វិចិត្រវដ្ដង្គុលិកស្ស** សោភរេ "**សូម្បីដៃទាំងពីររបស់ជដិលនោះ**

ក៏ប្រកបដោយម្រាមដ៏រៀវវិចិត្រល្អស្អាត *" សេចក្ដីថា សូម្បីដៃទាំង*
ពីរខាងរបស់ជដិលនោះ ក៏ប្រកបដោយម្រាមដៃដ៏រៀវស្អាត មាន
លក្ខណៈដ៏វិចិត្រ ដូចជាពន្ធកផ្ការ ។ បទថា ***អកក្ខសង្ខោ "មាន***
អាយុវ:មិនរដិបរដុប *" បានដល់ មានអាយុវ:តូចធំប្រាសចាករោគ-*
ភ័យ មានរោគរមាស់ និងស្រែងជាដើម ។ បទថា ***រមយំ ឧបដ្ឋហិ***
"បម្រើឲ្យរីករាយ *" សេចក្ដីថា បម្រើឲ្យខ្ញុំរីករាយ ។ បទថា* ***តូ-***
លូបនិកា "ទន់ល្ងន់ដូចសំឡី *" បានដល់ ជាការឧបមាដល់សភាព*
ទន់ ។ បទថា ***សុវណ្ណកម្ពូតលវដ្ដសុច្ឆវី "ផ្ទៃបាតដៃរលើងស្អាតដូច***
បន្ទះមាស *" បានដល់ ផ្ទៃបាតដៃរលើង និងមានពណ៌ល្អស្រដៀង*
ផ្ទៃកញ្ចាក់មាស អធិប្បាយថា មានផ្ទៃរលើបរលោង និងមានពណ៌
សម្បុរស្អាត ។ បទថា ***សំផុសិត្វា "ប៉ះពាល់*** *" បានដល់ សម្ងួសរ*
ដោយល្អ គឺ ប្រើដៃទាំងពីររបស់គេប៉ះ ធ្វើឲ្យសរីរៈរបស់ខ្ញុំស្រើប-
ស្រាល ។ បទថា ***ឥតោ គតោ "ទៅអំពីទីនេះ*** *" បានដល់ ទាំង*

ដែលខ្ញុំសម្ងីតមើលហើយនោះឯង គេក៏ចេញអំពីទីនេះទៅហើយ ។ បទថា **តេន មំ ទហន្តិ** "**រមែងធ្វើឲ្យខ្ញុំក្តៅក្រហាយដោយសម្ងួសរ្ស នោះ**" សេចក្តីថា ដោយការប៉ះខ្ទប់នូវសម្ងួសរ្សដោយដៃនោះរបស់គេ ធ្វើឲ្យខ្ញុំក្តៅក្រហាយរហូតមកដល់ពេលនេះឯង ។ អធិប្បាយថា ក៏ផ្តើមតាំងពីវេលាដែលជដិលនោះចេញអំពីទីនេះទៅ សេចក្តីក្តៅក្រហាយក៏កើតឡើងក្នុងសរីរៈរបស់ខ្ញុំ ព្រោះហេតុនោះ ខ្ញុំទើបដល់នូវសេចក្តីទោមនស្សដេកដូច្នេះ ។

បទថា **ទារិវិធំ** "**សង្រែក**" សេចក្តីថា បពិត្របិតា មាណពនោះមិនបានកាន់យកសង្រែកត្រាច់ទៅក៏ពិត ។ បទថា **ទ្វីឡានិ**[1] "**សកាពរ៉ីង**" បានដល់ អស់សកាពរ៉ីង ។ មួយទៀត បាលីក៏ថា **ទ្ធ្ងាណិ** យ៉ាងនេះដូចគ្នា ។ បទថា **សុខុយ៉ំ**[2] "**សេចក្តីសុខ**" បានដល់ សុខ ។ បទថា **សន្ធ្ងតា** "**ដែលក្រាស**" បានដល់ ត្រៀម

ចិដក. ១. ទ្ធ្ងាណិ , ២. សុទ្ធ្ងិតំ ។

ក្រាល ។ បទថា **វិកិណ្ណរូបា ច**[1] **"ខ្ចាត់ខ្ចាយហើយ"** សេចក្ដីថា បពិត្រលោកពុក ក្នុងស្ថានទីដែលក្រាលដោយស្លឹកឈើទាលរបស់ពុកនោះ ក្លាយជាទីដ៏អាក្រក់ដោយអំណាចដែលខ្ញុំ និងជដិលនោះ ឱ្យរីតគ្នា ក្នុងថ្ងៃនេះក៏ភ្ជាត់ភ្ជាយ ដោយការដេកនៀលទៅមក ។ ដោយបទថា **បុនប្ឆ្ពុនំ បណ្ណកុដី** រជាម **"ចូលកាន់កុដីដែលប្រក់ជាំងដោយស្លឹកឈើរៀយៗ"** ជដិលនោះនិយាយថា "បពិត្រលោកពុក ខ្ញុំ និងជដិលនោះអកិរម្យនឹងគ្នាហើយក៏ហត់ទៀយ ចេញចាកបណ្ណសាលា នាំគ្នាទៅកាន់ស្ទឹងរីកវាយហើយ ល្ងមនឹងប្រាសចាកសេចក្ដីក្រវល់ក្រវាយហើយ ក៏ត្រឡប់ចូលក្នុងកុដីនេះឯងរៀយៗ ។ បទថា **មន្ត្តា "មន្ត្តទាំងឡាយ"** សេចក្ដីថា ថ្ងៃនេះ តាំងអំពីជដិលនោះចេញអំពីខ្ញុំទៅហើយ មន្ត្តទាំងឡាយរមែងមិនច្ជាស់ គឺ រមែងមិនប្រាកដ បានដល់ រមែងមិនពេញចិត្ដដល់ខ្ញុំឡើយ ។ បទថា

ចិដក. ១. វិកិណ្ណរូបាវ ។

ន អគ្គិហុត្តំ នបិ យញ្ញ តត្រ “ការបូជាភ្លើង ខ្ញុំមិនពេញចិត្តឡើយ សូម្បីការបូជាយញ្ញក្នុងទីនោះ ខ្ញុំក៏មិនពេញចិត្ត” *សេចក្ដីថា សូម្បីកិរិយារបស់យញ្ញមានការដុតភ្លើង ក្នុងការកម្សាជាដើមដែលគួរធ្វើដើម្បីត្រូវការអង្ករស្ដេចមហាព្រហ្ម រមែងមិនជាក់ច្បាស់ដល់ខ្ញុំ គឺមិនតាំងឡើង ខ្ញុំមិនពេញចិត្តឡើយ ។ បទថា* ***ន ចាបិ ឥត “ខ្ញុំនឹងមិន... របស់លោកពុកឡើយ”*** *សេចក្ដីថា ខ្ញុំមិនព្រមបរិភោគ សូម្បីនូវមូលផលាហារដែលពុកនាំមកហើយ ។ បទថា* ***យស្សុំ ទិសំ “ទិសណា”*** *បានដល់ ក្នុងទិសណា ។ បទថា* ***វនំ “ព្រៃឈើ”*** *បានដល់ ព្រៃឈើដែលជុះព័ទ្ធអាស្រមរបស់មាណពនោះ ។*

កាលតាបសនោះកំពុងរៀបរាប់នោះឯង ព្រះពោធិសត្វបានស្ដាប់ពាក្យរៀបរាប់នោះហើយ ក៏ជ្រាបថា “សីលរបស់តាបសនេះនឹងត្រូវស្រីម្នាក់នោះទម្លាយឲ្យដាច់ហើយដោយពិត” កាលនឹងពោលទូន្មានតាបសនោះ ទើបពោល ៦ គាថា សេចក្ដីថា

[១៨] ឥមស្មា ហិ ជោតិរសេ រនម្ហិ
គន្ធព្ពទេវច្ចរសង្ឆរសេវិតេ
ឥសីនមាវាសេ សនន្ទនម្ហិ
នេតាទិសំ អរតី ជាបុណេជ ។

យើងមិនគួរឲ្យអ្នកនៅក្នុងបែបនេះ ដល់នូវសេចក្តីអផ្សុក ក្នុងព្រៃដែលរុងរឿងដោយពន្លឺ មានពួកគន្ធព្ព និងទេពអប្សរ សេព ជាទីនៅអាស្រ័យនៃឥសីទាំងឡាយក្នុងកាលមុន ។

ភវន្តិ មិត្តានិ អថោ ន ហោន្តិ
ញាតីសុ មិត្តេសុ ភវន្តិ ភេទំ
អយញ្ច ជម្ម ភិសូ ទិវ[1] ន ទ្ធ
យោ នេវ ជានាតិ ភុតោម្ហិ អាគតោ ។

សត្វទាំងឡាយជាមិត្តខ្លះ មិនជាមិត្តខ្លះ ជនទាំងឡាយរមែង

១.ម. ភ ។

ធ្វើសេចក្ដីស្រឡាញ់ក្នុងពួកញាតិ និងពួកមិត្ត កុមារណាមិន រមែងដឹងថា យើងជាអ្នកមកអំពីណា កុមារនេះឯងជាបុគ្គលលាមក ត្រឡប់ជាទុកចិត្ត (ក្នុងមាតុគ្រាមថាជាមិត្ត) ព្រោះហេតុអ្វី ។

សំវាសេន ហិ មិត្តានិ សន្ធិយន្តិ បុនប្ប្ុនំ
ស្ទ្ធ មិត្តោ អសង្ខ្ជ អសំវាសេន ជីរតិ ។

មិត្តសម្ងាញ់រមែងស្ទិទ្ធស្ទ្ធាលគ្នារឿយៗ ព្រោះការនៅរួមគ្នា មិត្តនោះឯង រមែងវិនាសទៅ ព្រោះការមិននៅរួមគ្នារបស់បុរសដែលមិនសមាគម ។

សចេ តុ្ យ ទក្ខ្ជ ព្រហ្មចារ
សចេ តុ្ យ សល្ជ សព្រហ្មចារិនា
សម្ជ្ជ្ជ្ជ ១ ១ ១

បើកូនបានឃើញព្រហ្មចារី បាននិយាយជាមួយព្រហ្មចារី កូននឹងលះបង់នូវគុណ គឺ តបធម៌នេះយ៉ាងធាប់ ដូចសន្ទូងដែលបរិបូណ៌ហើយចេញទៅ ព្រោះទឹកច្រើនជ្រុះ ។

បុនបិ ចេ ទក្ខសិ ព្រហ្មចារី

បុនបិ ចេ សល្លបេ ព្រហ្មចារិនា

សម្ឆន្ទសស្សុំ មហោទកេន

ឧស្មាគតំ ទិប្ឍមិមំ បហស្សសិ ។

បើកូនបានឃើញព្រហ្មចារីនោះទៀត បាននិយាយជាមួយព្រហ្មចារីនោះទៀត កូននឹងលះបង់នូវសមណាតេជៈនេះដោយធាប់ ដូចសន្ទូងដែលបរិបូណ៌ហើយចេញទៅ ព្រោះទឹកច្រើនជ្រុះ ។

ភូតានិ ហោតានិ ចរន្តិ តាត

ទ្វិរូបរូបេន មនុស្សលោកេ

ន តានិ សេវេថ នរោ សបញ្ញោ

អាសជ្ជនំ ន សន្ត្ថតិ ព្រហ្មចារីតិ ។

កូនសម្ងាញ់ ពួកយក្ខនោះរមែងត្រាច់ទៅក្នុងមនុស្សលោក ដោយរូបប្លែកៗ នរជនអ្នកមានបញ្ញា មិនគប្បីគប់រកពួកយក្ខ នោះឡើយ ព្រហ្មចារីរមែងវិនាសទៅ ព្រោះការជាប់ជំពាក់ គ្នា ។

*បណ្តាបទទាំងនោះ បទថា **ឥមស្មា** "នេះ" បានដល់ **ឥមស្មិ** ប្រែថា ក្នុងព្រៃដែលមានពន្លឺរុងរឿងនេះ ។ បទថា **ហិ** ជានិបាត ។ បទថា **ជោតិរសេ** "**ភ្លឺរុងរឿង**" បានដល់ ដែលភ្លឺដោយរស្មីនៃការ ភ្លឺរបស់ភ្លើងដែលបូជាហើយ ។ បទថា **សនន្ត្ថនម្ហិ** "**ក្នុងកាលមុន**" បានដល់ ក្នុងគ្រាបុរាណ ។ បទថា **ចាបុណេថ** "**ដល់**" បានដល់ គួរឲ្យដល់ ។ មានពាក្យអធិប្បាយដែលលោកពោលទុកថា "កូន អើយ កុលបុត្តដែលជាបណ្ឌិតនៅក្នុងព្រៃបែបនេះ មិនគួរឲ្យកូន*

នៅក្នុងជូរច្នេះ ដល់នូវសេចក្ដីអផ្សុកឡើយ អធិប្បាយថា មិនគួរ
ឲ្យដល់ ។ បទថា **ភវន្តិ** "**ជា**" សេចក្ដីថា ព្រះមហាសត្វពោលនូវ
គាថានេះ ចំពោះបុគ្គលដែលនៅក្នុងអំណាចប៉ុណ្ណោះ ។ សេចក្ដី
ក្នុងគាថានោះ មានអធិប្បាយដូចតទៅនេះ ធម្មតាថា ពួកមិត្តរបស់
សត្វទាំងពួង រមែងធ្វើសេចក្ដីស្រឡាញ់ក្នុងពួកញាតិ និងពួកមិត្ត
របស់ខ្លួន ។ បទថា **អយញ្ច ជម្មោ** "**កុមារនេះជាបុគ្គលលាមក**"
បានដល់ (កុមារនេះ) ជាមិគសិង្ហៈដ៏លាមក ។ បទថា **កិស្ស
ទិវា និវិដ្ឋោ** "**នៅក្នុងកណ្ដាលថ្ងៃព្រោះហេតុអ្វី**" សេចក្ដីថា ជៀ
គេដោយសម្គាល់ថា ជាមិត្តក្នុងមាតុគ្រាមនោះព្រោះហេតុអ្វី ។ ព្រោះ
ខ្លួនកើតក្នុងផ្ទៃរបស់មេម្រីគហើយធំធាត់ក្នុងព្រៃ កុមារនោះទើបមិន
ដឹងទីដែលខ្លួនមកហើយថា **កុតោម្ហិ អាគតោ** "**យើងជាអ្នកមកអំពី
ណា**" នឹងចាំបាច់ពោលថ្វីដល់ពពួកញាតិ និងមិត្តហ្ន៎ ។ បទថា
មិត្តោ "**រឿយៗ**" សេចក្ដីថា មិត្តនោះៗ ឯងរមែងវិនាសទៅ គឺ

ចាត់បង់ទៅ ព្រោះការមិននៅរួមគ្នា ពោលគឺ ការមិនសមាគមនឹង
គ្នានោះ របស់បុរសអ្នកដែលមិនអាច គឺ របស់បុរសអ្នកមិនមក
រួមគ្នា ។ បទថា **សចេ** "**ប្រសិនបើ**" សេចក្តីថា ព្រោះដូច្នោះ បើ
កូនបានឃើញព្រហ្មចារីនោះទៀត ឬថា បាននិយាយជាមួយព្រហ្ម-
ចារី គ្រានោះកូនក៏នឹងលះ នឹងធ្វើឲ្យគុណ គឺ តបធម៌របស់ខ្លួននេះ
វិនាសទៅដោយឆាប់ ដូចសន្ទូងដែលឲ្យកើតផ្ទៃសម្ផ្ទ្ររហើយ ត្រូវ
វិនាសទៅព្រោះអន្ទង់ទឹកធំដូច្នោះ ។ បទថា **ឧស្មាគតំ** "**សមណ-
តេជៈ**" បានដល់ តេជៈនៃសមណៈ ។ បទថា **វិរូបរូបេន** "**ដោយ
រូបប្លែក**" បានដល់ ដោយបែបភាពនៃរូបប្លែកៗ ។ មានពាក្យដែល
លោកពោលអធិប្បាយទុកថា ព្រះពោធិសត្វពោលទូន្មានហើយនូវ
ឫត្តយ៉ាងនេះថា "កូនសម្ងាញ់ ក៏ភ្ជុត គឺ ពួកយក្ខទាំងនេះរមែង
ត្រាច់ទៅក្នុងមនុស្សលោក ដោយរូបរាងខ្លួនដែលបិទបាំងប្លែកៗ ក៏
ដើម្បីទំពាស៊ីពួកមនុស្សដែលធ្លាក់នៅក្នុងអំណាចរបស់ខ្លួន នរជន

អ្នកមានបញ្ញាមិនគប្បីគប់រកពួកកូត គឺ យក្ខទាំងនោះ ព្រោះដល់ នូវសេចក្តីជាប់ជំពាក់ដូច្នោះ ការប្រព្រឹត្តិព្រហ្មចរិយៈក៏វិនាសទៅ កូនត្រូវនាងយក្ខិនីនោះឃើញហើយ តែមិនបានទំពាស៊ី" ។

តាបសនោះបានស្តាប់ពាក្យរបស់បិតាហើយ កើតការតក់ស្លុតឡើងថា "ដើម្បីជ្រាបថា ស្រីនោះគឺជាយក្ខិនី" ទើបបានត្រឡប់ចិត្ត ហើយសូមខមាទោសបិតាថា "លោកពុក ខ្ញុំនឹងមិនសូមទៅកាន់ទីនោះទេ ពុកចូរលើកទោសឲ្យខ្ញុំចុះ" ។ សូម្បីព្រះពោធិសត្វនោះ លួងលោមចិត្តកូនឲ្យសប្បាយចិត្តហើយ ទើបប្រាប់ដល់វិធីការនៃការចម្រើនព្រហ្មវិហារថា "មាណពតូចអើយ កូនមកនេះ ចូរកូនចម្រើនមេត្តា ករុណា មុទិតា និងឧបេក្ខាចុះ" ។ តាបសនោះប-ដិបត្តិតាមយ៉ាងនោះហើយ ក៏ធ្វើឈាន និងអភិញ្ញាឲ្យកើតឡើងបានវិញ ។

ព្រះសាស្តាគ្រាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ក៏

ប្រកាសសច្ចៈទាំងឡាយ ហើយប្រជុំជាតក ។ ក្នុងគ្រាចប់សច្ចៈ ភិក្ខុអ្នកអផ្សុកក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះរាជធីតា ទន្ធិនិកាក្នុងគ្រានោះ បានមកជាភរិយាចាស់របស់ភិក្ខុនោះក្នុងគ្រានេះ ។ ឥសិសិង្គតាបសក្នុងគ្រានោះ បានមកជាភិក្ខុអ្នកអផ្សុកនេះឯង ចំណែកព្រះពោធិសត្វជាបិតាក្នុងគ្រានោះ គឺ **តថាគត ព្រះអរហន្តសម្មាសម្ពុទ្ធ** នេះឯង ។

ចប់អដ្ឋកថា ឆទ្ធិនិកាជាតកនី ១

អដ្ឋកថា ឧម្មាទន្តីជាតកទី ២

(រឿងសេនាបតីថ្វាយនាងឧម្មាទន្តីចំពោះព្រះរាជា)

ព្រះសាស្តាកាលស្តេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បានប្រារព្ធកិក្ខុអ្នកអផ្សុក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **និវេសនំ កស្ស នុទំ សុនន្ទ "ម្នាលសុនន្ទសារថី នេះជាផ្ទះរបស់នរណាហ្ន៎"** ដូច្នេះជាដើម ។

បានឮថា ថ្ងៃមួយ កិក្ខុរូបនោះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី បានឃើញស្ត្រីម្នាក់ដែលប្រជាប់តាក់តែងកាយ មានរូបរាងស្អាតក្រៃលែង ក៏កើតចិត្តប្រតិព័ទ្ធ មិនអាចនឹងហាមចិត្តបាន មកកាន់វត្តវិញ តាំងអំពីនោះមក ក៏ជាអ្នកទុព្វលព្រោះរោគ ដូចត្រូវសរមុតហើយ មានចំណែកប្រៀបដោយម្រ៉ីគដែលផ្ទើល ចុះស្គមរាងកាយលេចចេញសរសៃរាម ក្លាយជាមនុស្សស្គមលឿង មិនត្រេកអរ (ក្នុងព្រះសាសនា) កាលមិនបានសូម្បីសេចក្តីសប្បាយ

ក្នុងឥរិយាបថ ទើបលះបង់វត្តមានអាចរិយវត្ត និងឧបជ្ឈាយវត្តជាដើម ទម្លាក់ចោលការប្រកបសេចក្តីព្យាយាមក្នុងការរៀន ការសួរ និងកម្មដ្ឋាន ។ លោកត្រូវពួកមិត្តភិក្ខុសួរថា "អាវុសោ កាលមុន លោកមានឥន្ទ្រិយស្រស់បស់ មានមុខស្រស់ថ្លា តែឥឡូវនេះ មិនបានជាដូច្នោះ ព្រោះហេតុអ្វីហ្ន៎?" ទើបប្រាប់ថា "អាវុសោ ខ្ញុំមិនត្រេកអរ (ក្នុងព្រះសាសនា) ទេ" ។ លំដាប់នោះ ពួកមិត្តភិក្ខុទាំងនោះទើបពោលទូន្មានថា "អាវុសោ លោកចូរត្រេកអរ (ក្នុងព្រះសាសនា) នេះចុះ ធម្មតាថា ការឧប្បត្តិឡើងនៃព្រះពុទ្ធ ជាសភាវៈដែលបានដោយលំបាក ការបានស្តាប់ព្រះសទ្ធម្ម និងការបានអត្តភាពជាមនុស្ស ក៏ជាវត្ថុដែលបានដោយលំបាកដូចគ្នា លោកបានអត្តភាពជាមនុស្សហើយ កាលប្រាថ្នានឹងធ្វើនូវទីបំផុតនៃទុក្ខឲ្យបាន ទើបលះបង់បុគ្គលជាញាតិដែលមានទឹកភ្នែកហូរហើយ ចូលដោយសទ្ធា បែរជាធ្លាក់ក្នុងអំណាចនៃកិលេស ព្រោះហេតុអ្វីហ្ន៎

ដែលឈ្មោះថា កិលេសទាំងនោះមានឧបមាដូចផ្លែឈើ ដែលទូទៅ
ដល់បុគ្គលពាលគ្រប់ជំពូក តាំងអំពីសត្វមានជីវិតមានជនេ្ទនឡើង
ទៅ វត្ថុពួកណាជាទីតាំងនៃកិលេសទាំងនោះ វត្ថុសូម្បីទាំងនោះជា
កាម ដែលមានសេចក្តីត្រេកអរតិច មានទុក្ខច្រើន មានសេចក្តី
ចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងនោះមានប្រមាណក្រៃលែង
កាមទាំងឡាយប្រៀបដូចជារាងឆ្អឹង កាមទាំងឡាយប្រៀបដូចជា
រណ្ដៅរងើកភ្លើង កាមទាំងឡាយប្រៀបដូចជាការយល់សប្ដិ កាម
ទាំងឡាយប្រៀបដូចជារបស់ខ្ចីគេមក កាមទាំងឡាយប្រៀបដូចផ្លែ
នៃឈើដែលមានពិស កាមទាំងឡាយប្រៀបដូចជាដុំសាច់ កាម
ទាំងឡាយប្រៀបដូចលំពែង និងដែកស្រួច កាមទាំងឡាយប្រៀប
ដូចជាកញ្ជាលពស់ ធម្មតាថា លោកបួសហើយក្នុងព្រះសាសនាបែប
នេះ បើរជាធ្លាក់ក្នុងអំណាចរបស់ពួកកិលេស ដែលជាហេតុធ្វើនូវ
សេចក្តីវិនាសយ៉ាងនោះបាន" កាលមិនអាចឲ្យភិក្ខុនោះទទួលយក

ទូវពាក្យខ្លួនបាន ទើបនាំគ្នានាំទៅគាល់ព្រះសាស្តាក្នុងធម្មសភា គ្រាព្រះអង្គត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនាំភិក្ខុដែលមិនមានសេចក្តីប្រាថ្នាមកធ្វើអ្វី?" ទើបនាំគ្នាក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ជ្រាបថា ភិក្ខុនេះជាអ្នកនឿយណាយ ព្រះអង្គ" ។ ព្រះសាស្តាត្រាស់សួរថា "ភិក្ខុ ពិតឬ?" កាលភិក្ខុនោះក្រាបទូលថា "ជាការពិត ព្រះអង្គ" ទើបត្រាស់ថា បុរាណកបណ្ឌិតទាំងឡាយ សូម្បីនៅគ្រប់គ្រងរាជ្យសម្បត្តិហើយ ក៏មិនធ្លាក់ទៅក្នុងអំណាចនៃកិលេសដែលកើតឡើងឡើយ ហាមចិត្តបាន មិនព្រមធ្វើវត្ថុដែលមិនសមគួរ" ទើបទ្រង់នាំអតីតនិទានមកដូចតទៅនេះ ។

ក្នុងអតីតកាល ក្នុងដែនសីវី ព្រះរាជាទ្រង់ព្រះនាមថា **សីវី** ទ្រង់គ្រងរាជ្យសម្បត្តិក្នុងអរិដ្ឋបុរីនគរ ។ ព្រះពោធិសត្វបានកើតក្នុងព្រះគភ៌ព្រះអគ្គមហេសីរបស់ព្រះរាជាអង្គនោះ ។ ព្រះបរម-រាជ្ញានុរាជ្ញបាននាំគ្នាថ្វាយព្រះនាមព្រះឱរសនោះថា "**សីវិកុមារ**" ។

*សូម្បីបុត្តរបស់សេនាបតីក៏ប្រសូតហើយ ។ ពួកញាតិនាំគ្នាតាំងឈ្មោះក្មេងនោះថា "**អកិបារកៈ**" ។ ក្មេងទាំងពីរនោះជាសម្លាញ់ទ័ងគ្នា លុះចម្រើនវ័យបានអាយុ ១៦ ឆ្នាំ បានទៅកាន់ក្រុងតក្ក-សិលា លុះរៀនសិល្បៈចប់ហើយ ក៏នាំគ្នាត្រឡប់ ។ ព្រះរាជាទ្រង់បានប្រទានរាជ្យសម្បត្តិឲ្យព្រះរាជឱរសគ្រប់គ្រង ។ សូម្បីព្រះ-ជឱរសនោះ ក៏ទ្រង់តែងតាំងអកិបារកៈទុកក្នុងតំណែងជាសេនាបតី ទ្រង់គ្រប់គ្រងរាជ្យសម្បត្តិដោយធម៌ ។ ក្នុងព្រះនគរនោះឯង មានបុត្រីរបស់តិរិដ្ឋិវច្ឆសេដ្ឋី ដែលមានទ្រព្យសម្បត្តិប្រមាណ ៨០ កោដិ នាងមានរូបរាងស្អាតក្រៃលែង ប្រកបដោយលក្ខណៈដ៏ល្អស្អាត ។ ក្នុងថ្ងៃតាំងឈ្មោះ ពួកញាតិបានតាំងឈ្មោះនាងថា "**ឧម្មាទន្តី**" ។ ក្នុងវេលានាងបានអាយុ ១៦ ឆ្នាំ នាងមានពណ៌សម្បុរលើសពួកមនុស្ស ស្អាត គួរមិលមើល ដូចជាទេវធីតា ។ ពួកបុថុជ្ជនបានឃើញនាង គ្រប់ៗ គ្នា មិនអាចតាំងសតិបាន ជាអ្នកស្រវឹងហើយ*

ដោយសេចក្ដីស្រវឹង គឺ កិលេស ដូចស្រវឹងហើយដោយទឹកស្រវឹង ដូច្នោះ ឈ្មោះថា នឹងអាចតាំងសតិបាន មិនមាន ។ ត្រានោះ តិ-រិដិវច្ឆសេដ្ឋីជាបិតារបស់នាង ចូលទៅគាល់ព្រះរាជាក្រាបទូលថា "បពិត្រព្រះសម្មតិទេព ឥត្ថីរតន៍ដែលសមគួរចំពោះស្ដេចផែនដី បានកើតឡើងហើយក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ សូមព្រះអង្គប្រោសបញ្ជូនព្រាហ្មណ៍អ្នកទស្សន៍ទាយលក្ខណៈទាំងឡាយទៅ ឲ្យពិចារណានូវឥត្ថីរតន៍នោះហើយ ប្រោសចូរធ្វើតាមការពេញព្រះទ័យចុះ" ។ ព្រះរាជាទ្រង់ទទួលពាក្យហើយ ក៏បានបញ្ជូនព្រាហ្មណ៍ទាំងឡាយទៅ ។ ព្រាហ្មណ៍ទាំងនោះទៅកាន់ផ្ទះរបស់លោកសេដ្ឋីហើយ បានទទួលការបដិសណ្ឋារៈដោយសក្ការៈ និងសម្មាន ហើយនាំគ្នាបរិភោគនូវបាយបាយាស ។

ក្នុងខណៈនោះ នាងខម្មាទន្ដីបានប្រជាប់ដោយគ្រឿងសព្វ-លង្ការហើយ ក៏ទៅកាន់សម្ផាក់របស់ព្រាហ្មណ៍ទាំងនោះ ។ ព្រាហ្មណ៍

ទាំងនោះគ្រាន់តែឃើញនាងចូលទៅ ក៏មិនអាចតាំងសតិបាន បានជាអ្នកវង្វេង គឺ កិលេស មិនបានដឹងខ្លួនថា យើងនឹងកំពុងបរិ-ភោគឡើយ ។ ពួកខ្លះក៏ចាប់យកដុំបាយមកដាក់លើសីស:ដោយសម្គាល់ថា យើងនឹងបរិភោគ ។ ពួកខ្លះក៏ចាប់ដាក់ត្រង់ចន្ទោះនៃភ្ជៀក ពួកខ្លះក៏គប់ទៅជញ្ជាំងផ្ទះ ។ ពួកព្រាហ្មណ៍បានក្លាយទៅជាមនុស្សឆ្កួតសូម្បីទាំងអស់ ។ នាងឃើញព្រាហ្មណ៍ទាំងនោះដូច្នេះ ទើបពោលថា "ដំណឹងថា ពួកព្រាហ្មណ៍ទាំងនេះនឹងមកត្រួតមើលលក្ខណៈរបស់យើង អ្នកទាំងឡាយចូរអូសកពួកព្រាហ្មណ៍ទាំងនេះចេញឲ្យអស់ទៅ" ហើយឲ្យអ្នកបម្រើនាំព្រាហ្មណ៍ទាំងនោះចេញទៅ ។ ព្រាហ្មណ៍ទាំងនោះខ្ទាសអៀនបានទៅកាន់ព្រះរាជនិវេសន៍ ក្រោធចំពោះនាងឧម្មាទន្តី ទើបក្រាបទូលកុហកថា "ព្រះតេជះ ស្រីនោះ ជាស្រីកាឡកណ្ណី មិនសមគួរចំពោះព្រះអង្គឡើយ" ។ ព្រះរាជាទ្រង់ជ្រាបថា ស្រីនោះជាកាឡកណ្ណី ដូច្នេះហើយ ទ្រង់ទើប

មិនបានគ្រាស់បង្គាប់ឲ្យនាំស្រីនោះមក ។ នាងឧម្មាទន្តីបានជ្រាបរឿងនោះហើយ ទើបពាលថា "ព្រះរាជាទ្រង់មិនទទួលយើងដោយទ្រង់សម្គាល់ថា យើងជាមនុស្សកាឡកណ្ណី ដែលឈ្មោះថា ស្រីកាឡកណ្ណីរមែងមិនមានរូបរាងយ៉ាងនេះដោយពិត" ហើយក៏អាឃាតក្នុងព្រះរាជាអង្គនោះថា "ក៏ណ្ហើយចុះ បើយើងមិនបានចូលគាល់ព្រះរាជា ក៏ទីងជីងគ្នា" ។ ត្រាតមក បិតាបានប្រគល់នាងឲ្យដល់អភិបារកសេនាបតី ។ នាងបានជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អភិបារកសេនាបតី ។ សួរថា ក៏នាងបានរូបរាងស្អាតដូច្នេះ ព្រោះវិបាកនៃកម្មអ្វី? ឆ្លើយថា ដោយវិបាកនៃការថ្វាយសំពត់ ។

បានឮថា ក្នុងអតីតកាល នាងបានកើតក្នុងត្រកូលក្រខ្សត់មួយ ក្នុងក្រុងពារាណសី ក្នុងថ្ងៃមហោស្រព នាងឃើញស្រីទាំងឡាយអ្នកសម្បូរដោយបុណ្យ ជណ្តប់សំពត់ដែលជ្រលក់ដោយទឹកដកគាំ ប្រដាប់តាក់តែងដ៏ស្អាតកំពុងលេងជាមួយគ្នា នាងត្រូវការ

ដណ្តប់សំពត់ដូច្នោះលេងជាមួយគេ ទើបប្រាប់ឲ្យមាតាបិតាបានជ្រាប កាលមាតាបិតាពោលថា "កូនអើយ ពួកយើងជាមនុស្សក្រ ពួកយើងបានសំពត់ដូច្នោះអំពីណា?" ទើបពោលថា "បើដូច្នោះ សូមលោកអនុញ្ញាតឲ្យខ្ញុំបានធ្វើការបម្រើក្នុងត្រកូលស្តុកស្តម្ភណាមួយចុះ ពួកអ្នកម្ចាស់ទាំងនោះដឹងគុណខ្ញុំហើយ គង់នឹងឲ្យថ្លៃឈ្នួល" លុះបានទទួលការអនុញ្ញាតអំពីមាតាបិតាហើយ ទើបចូលទៅកាន់ត្រកូលមួយពោលថា "ខ្ញុំស្ម័គ្រមកធ្វើការបម្រើ ដើម្បីត្រូវការសំពត់ដែលជ្រលក់ដោយផ្ការដកគាំ" ។

លំដាប់នោះ ពួកអ្នកម្ចាស់ពោលនឹងនាងថា "កាលនាងធ្វើការគ្រប់ ៣ ឆ្នាំហើយ ពួកយើងនឹងដឹងគុណរបស់នាង ហើយនឹងឲ្យដោយពិត" ។ នាងទទួលពាក្យហើយក៏ផ្តើមធ្វើការងារ ។ ពួកអ្នកម្ចាស់ទាំងនោះដឹងគុណរបស់នាងហើយ ក្នុងកាលមិនទាន់គ្រប់ ៣ ឆ្នាំបរិបូណ៌ល្អនោះឯង ទើបបានប្រគល់សំពត់ប្រភេទដទៃដែល

ជ្រលក់ដោយផ្ការីកគាំប្រកេទសាច់ល្អិតជល់នាង ហើយបញ្ជូននាងថា "នាងចូរទៅងូតទឹកជាមួយសម្លាញ់របស់នាងស្រេចហើយ ចូរមកលសំពត់នេះមើល" ។ នាងទៅជាមួយពួកស្រីជាសម្លាញ់ ដាក់សំពត់ដែលជ្រលក់ហើយទុកលើគោក ទើបចុះងូតទឹក ។ ក្នុងខណៈនោះ ព្រះសាវ៕ករបស់ព្រះកស្សបទសពលមួយរូប ត្រូវចោរដណ្តើមចីវរទៅ ស្ងៀក និងជណ្តប់មែកឈើដែលកាច់មកបាន មកដល់ទីនោះ ។ នាងឃើញហើយគិតថា "លោកដ៏ចម្រើនរូបនេះ គង់ទ័ងត្រូវចោរដណ្តើមចីវរយកទៅ សំពត់ជណ្តប់របស់យើងរកបានមកដោយលំបាក ព្រោះមិនបានឲ្យទានទុកមកក្នុងកាលមុន យើងនឹងហែកសំពត់នេះជាពីរចំណែក ហើយថ្វាយមួយចំណែកចំពោះភិក្ខុអង្គនេះ" ទើបឡើងអំពីទឹក ហើយជណ្តប់សំពត់របស់ខ្លួនពោលថា "លោកម្ចាស់ និមន្តឈប់សិន" ចូលទៅសំពះព្រះថេរៈ ហើយក៏ហែកសំពត់នោះពាក់កណ្តាល បានថ្វាយមួយចំណែកចំពោះព្រះថេរៈ

នោះ ។ ព្រះថេរៈឈរក្នុងទីកំពាំងម្ខាង លះមែកឈើដែលកាច់
មកបានចេញ ដណ្តប់សំពត់ផ្ទាំងនោះហើយទើបចេញទៅ ។ គ្រា
នោះ ព្រោះរស្មីនៃសំពត់ ទូទាំងរាងកាយរបស់ព្រះថេរៈក៏មានរស្មី
តែមួយដូចគ្នា ដូចជាពន្លឺព្រះអាទិត្យស្រទន់ ដូច្នោះ ។ នាងសម្លឹង
មើលព្រះថេរៈនោះហើយគិតថា "ដំបូង លោកម្ចាស់របស់យើង
មិនស្អាតឡើយ តែពេលនេះរុងរឿងដូចព្រះអាទិត្យដែលមានរស្មី
ស្រទន់ដូច្នោះ យើងនឹងថ្វាយសូម្បីសំពត់ចំណែកនេះចំពោះលោក
ម្ចាស់នេះឯងទៀត" ហើយក៏បានថ្វាយសំពត់ចំណែកទី ២ និងបាន
តាំងសេចក្តីប្រាថ្នាថា "លោកម្ចាស់ដ៏ចម្រើន នាងខ្ញុំត្រាច់រង្គាត់ទៅ
ក្នុងកព គប្បីជាអ្នកទ្រទ្រង់ទូរ្ យបដ៏ស្អាត បុរសណាម្នាក់ឃើញនាងខ្ញុំ
ហើយ កុំអាចតាំងនៅដោយការៈនៃខ្លួនបានឡើយ ឯស្រីដទៃដែល
ឈ្នះមានរូបស្អាតជាងនាងខ្ញុំ កុំមានឡើយ" ។ សូម្បីព្រះថេរៈក៏
បានធ្វើអនុមោទនាហើយ ហើយក៏ចៀសចេញទៅ ។ នាងត្រាច់-

រង្គាត់ទៅក្នុងទេវលោក បានមកកើតក្នុងអវិជ្ជបុរីក្នុងកាលនោះឯង បានមានរូបរាងស្អាតដូចដែលបានប្រាថ្នាដូច្នោះ ។

លំដាប់នោះ ក្នុងព្រះនគរនោះ ជនទាំងឡាយបានវាយស្គរប្រកាសការងារមហោស្រពប្រចាំខែកត្តិកមាស (ខែ ១២) ។ ជនទាំងឡាយបានរៀបចំព្រះនគរទុកក្នុងថ្ងៃពេញបូរមីខែ ១២ ហើយ ។ អភិបាកសេនាបតីកាលនឹងទៅកាន់ទីរក្សា (ទីធ្វើការងារ) របស់ខ្លួន ទើបហៅភរិយាដែលជាទីស្រឡាញ់នោះមក និយាយថា "ឧម្មាទន្តី ឬនសម្ងាញ់ ថ្ងៃនេះនឹងមានមហោស្រពក្នុងវេលាយប់នៃកត្តិកមាស ព្រះរាជាទ្រង់នឹងប្រទក្សិណាព្រះនគរ ស្តេចនឹងយាងកាត់ទ្វារផ្ទះរបស់យើងដំបូង ឬនកុំប្រាកដខ្លួនឲ្យព្រះរាជាទ្រង់ឃើញណា ព្រោះបើព្រះអង្គឃើញឬនហើយ នឹងមិនអាចតាំងសតិទុកបានឡើយ" ។ នាងឧម្មាទន្តីនោះទទួលពាក្យស្វាមីថា "ទៅចុះ លោកប្តី (ដល់វេលានោះ) ខ្ញុំនឹងដឹង" កាលស្វាមីទៅហើយ ទើបបង្គាប់នាងទាសីថា

"ក្នុងវេលាព្រះរាជាស្តេចមកកាន់ទ្វារផ្ទះរបស់យើងនេះ នាងចូរប្រាប់ដល់យើងណា" ។

លំដាប់នោះ កាលព្រះអាទិត្យអស្តង្គតហើយ ព្រះចន្ទពេញវង់ក៏រះឡើងជំនួស ព្រះនគរដែលប្រជាប់តាក់តែងហើយ មើលទៅស្រស់ស្អាតដូចជាទេវនគរ ប្រទីបឆេះព្រោងព្រាតគ្រប់ទិស ព្រះរាជាទ្រង់ប្រជាប់តាក់តែងដោយសព្វាលង្ការ ទ្រង់ប្រថាប់លើរថសេះដ៏ប្រសើរ រៃហាមដោយពួកអាមាត្យ ទ្រង់ធ្វើប្រទក្សិណព្រះនគរដោយយសដ៏ធំ ស្តេចយាងដល់ទ្វារផ្ទះរបស់អភិជ្ញាកសេនាបតីជាផ្ទះខ្នងដំបូង ។ ក៏ផ្ទះខ្នងនោះឡោមព័ទ្ធដោយកំពែងពណ៌ដូចមនោ-សិលា មានសើនៅត្រង់ខ្វាងទ្វារប្រជាប់តាក់តែងដ៏ស្អាត ជាផ្ទះគួរកែកាយ ។ ខណៈនោះ នាងទាសីបានប្រាប់ឲ្យនាងឧម្មាទន្តីជ្រាបហើយ ។ នាងឧម្មាទន្តីឲ្យនាងទាសីកាន់ស្ទុគផ្កា ហើយឈរផ្ទែកត្រង់មាត់បង្អួចដោយលីលាដ៏ស្រស់ស្អាតដូចនាងកិន្នរី ចាចផ្ការដាក់

ព្រះរាជា ។ ព្រះរាជាក្រេឡកយើញនាង រំពេចនោះក៏កើតសេចក្តីវង្វេងព្រោះកិលេស មិនអាចនឹងតាំងសតិទុកបាន រហូតមិនអាចនឹងចាំបានថា "ផ្ទះនេះជារបស់អភិបារកសេនាបតី" ។

លំដាប់នោះ ព្រះរាជាត្រាស់ហៅនាយសារថីមក កាលនឹងត្រាស់សួរ ទើបត្រាស់ ២ ព្រះគាថាថា

[២០] និវេសនំ កស្ស នុទំ សុនន្ទ
ជាការេន បណ្ឌុមយេន គុត្តំ
កា ទិស្សតិ អគ្គិសិខាវ ទូរេ
រវិហាយសំ ឋតគ្គេ អច្ចិ ។

ម្នាលសុនន្ទសារថី នេះផ្ទះរបស់នរណាហ្ន៎ ឡើងមព័ន្ធដោយកំពែងពណ៌លឿង នរណាហ្ន៎ប្រាកដនៅក្នុងទីឆ្ងាយដូចជាអណ្តាតភ្លើងដែលឆេះនៅលើវិហារ និងដូចអណ្តាតភ្លើងលើកំពូលភ្នំដូច្នោះ ។

ធីតា ន្វាយំ កស្ស សុនទ្ទ ហោតិ

សុណិសា ន្វាយំ កស្ស អថោបិ ភរិយា

អក្ខាហិ មេ ទ្វិបទ្យមិធេវ ឋុដ្ឋា

អវាវតា យទិ វា អត្ថិ ភត្តា ។

ម្នាលសុនទ្ទសារបី ស្រីនេះជាធីតារបស់នរណាហ្ន៏ ជាកូនប្រសារ ឬជាភរិយារបស់នរណា មិនមានអ្នកហួងហែងទេ ឬ ស្វាមីរបស់នាងមានឬទេ យើងសួរហើយ សូមអ្នកចូរប្រាប់ដល់យើងដោយរហ័ស ។

បណ្តាបទទាំងនោះ បទថា **កស្ស ន្ទ្ទ** "នេះផ្ទះនរណាហ្ន៏" ភាគ់បទជា **កស្ស ន្ទ ឥទ** ។ បទថា **ឋណ្ឌ្ឍមយេន** "ពណ៌លឿង" បានដល់ សម្រេចដោយកំពែងឥដ្ឋពណ៌ក្រហម ។ បទថា **ទ្ទិសតិ** "ប្រាកដ" បានដល់ ឈរប្រាកដនៅត្រង់មាត់ចង្ហ្ច ។ បទថា **អច្ចិ** "**អណ្ណាតភ្លើង**" បានដល់ គំនរភ្លើងដែលមានខ្យល់បក់ឲ្យឆេះ ។

*បទថា **ធីតា នាយំ**[1] "**ស្រីនេះជាធីតា**" កាត់បទជា **ធីតា នុ អយំ** ។ បទថា **អវារតា** "**មិនមានអ្នកហួងហែង**" បានដល់ មិនមានអ្នកប្រកាន់ គឺ មិនមានអ្នកហួងហែង ។ បទថា **ភត្តា** "**ស្វាមី**" បានដល់ ស្វាមីរបស់នាងមានឬទេ អ្នកចូរប្រាប់សេចក្តីនោះដល់យើង ។*

លំដាប់នោះ នាយសារថីកាលនឹងក្រាបទូលសេចក្តីនោះចំពោះព្រះរាជា ទើបបានក្រាបទូល ២ គាថាថា

[២១] *អហំ ហិ ជានামិ ជនិន្ទ ឯតំ*
មត្យា ច ឃេត្យា ច អថោបិ អស្ស
តវេវ ឃេ បុរិសោ ភូមិបាល
រត្តិន្ទិវំ អប្ប្ឃមត្តោ តវត្ថ ។

បពិត្រព្រះអង្គជាធំលើប្រជានិករ ក៏ខ្ញុំព្រះអង្គស្គាល់ស្រីនោះព្រមទាំងមាតា បិតា និងស្វាមីរបស់នាង បពិត្រព្រះចម

---

[1] ១. ធីតា ន្ទាយំ ។

ភូមិបាល បុរសនោះជាអ្នកមិនប្រមាទក្នុងប្រយោជន៍របស់ព្រះ
អង្គទាំងយប់ទាំងថ្ងៃ ។

ឥទ្ធោ ច ផីតោ ច សុវឌ្ឍិតោ ច
អមច្ចោ ច តេ អញ្ញតរោ ជនិន្ទ
តស្សេ សា ភរិយា អភិបារកស្ស
ឧម្មាទន្តីតិ នាមធេយ្យេន រាជ ។

ស្វាមីរបស់នាងជាអ្នកមានឥទ្ធិពលធំទូលាយ ស្តុកស្តម្ភ
ទាំងជាអាមាត្យម្នាក់របស់ព្រះអង្គ បពិត្រព្រះរាជា ស្រីនោះ
ជាភរិយារបស់អភិបារកសេនាបតី នាងមានឈ្មោះថា ឧម្មា-
ទន្តី ព្រះអង្គ ។

បណ្តាបទទាំងនោះ បទថា **មត្យា ច បេត្យា ច** "ព្រមទាំង
មាតាបិតា" សេចក្តីថា ខ្ញុំព្រះអង្គរមែងស្គាល់ស្រីម្នាក់នោះ ព្រម
ទាំងមាតា និងបិតា ។ ដោយបទថា **អថាបិ អស្ស** "ស្វាមីរបស់

នាង" នាយសារថីក្រាបទូលថា "សូម្បីស្វាមីរបស់នាង ក៏ខ្ញុំព្រះអង្គ ស្គាល់" ។ បទថា **ឥទ្ធា** "**ជាអ្នកមានឥទ្ធិពល**" បានដល់ ជាអ្នក បានទទួលសេចក្ដីសម្រេចហើយ ។ បទថា **ផីតោ** "**ធំទូលាយ**" បានដល់ បរិបូណ៌ដោយសំពត់ និងគ្រឿងអលង្ការទាំងឡាយ ។ បទថា **សុវណ្ណិតោ** "**ស្ពុកស្ពម្ភ**" បានដល់ ជាអ្នកស្ពុកស្ពម្ភសម្បូរ ល្អ ។ បទថា **នាមធេយ្យេន** "**មានឈ្មោះ**" បានដល់ មាននាម ។ ពិតហើយ ស្ត្រីម្នាក់នេះរមែងធ្វើឲ្យបុរសដែលមើលនាង ឲ្យវង្វេង ប្រៀបដូចជាមនុស្សឆ្កួត គឺ មិនឲ្យបុរសនោះតាំងសតិបាន ព្រោះ ដូច្នោះ លោកទើបហៅថា **ឧម្មាទន្តី** ។

ព្រះរាជាទ្រង់បានស្តាប់ពាក្យទូលនោះហើយ កាលនឹងទ្រង់ សរសើរឈ្មោះរបស់នាងនោះ ទើបត្រាស់គាថាជាប់តគ្នាថា

[២២] **អម្ភោ អម្ភោ នាមមិទំ ឥមិស្សា**

មត្យា ច ហេត្យា ច កតំ សុសាធុ

តថាហិ មយ្ហំ អវលោកយន្តី

ឧម្មត្តកំ ឧម្មាទន្តី អកាសិ ។

អ្នកដ៏ចម្រើន ឈ្មោះដែលមាតា និងបិតាតាំងឲ្យស្រីនេះ ជាឈ្មោះសមគួរ ពិតជ្រិះ្ចះ កាលនាងឧម្មាទន្តីសម្លឹងមើលយើង រមែងធ្វើឲ្យយើងវង្វេងដូចជាមនុស្សឆ្កួត ។

*បណ្តាបទទាំងនោះ បទថា **មត្យា ច បេត្យា ច** "ដែលមាតានិងបិតា" បានដល់ ដែលមាតា និងបិតា ។ បទថា **មយ្ហំ** "យើង" ជាសម្បទានៈ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។ បទថា **អវលោកយន្តី** "**កាល... សម្លឹងមើល**" សេចក្តីថា នាងត្រូវយើងសម្លឹងមើលហើយ ក៏ត្រឡប់សម្លឹងមើលយើងវិញ បានធ្វើយើងឲ្យវង្វេងដូចជាមនុស្សឆ្កួត ។*

សូម្បីនាងឧម្មាទន្តីនោះជ្រាបថា ព្រះរាជាអង្គនោះទ្រង់ញាប់ញ័រព្រះទ័យហើយ ទើបបិទបង្ហួច ក៏បានចូលទៅកាន់បន្ទប់ដែល

ប្រកបដោយសិរីតាមដើម ។ តាំងអំពីកាលដែលព្រះរាជាទ្រង់ទត ព្រះនេត្រឃើញនាងហើយ ព្រះអង្គមិនបានមានព្រះទ័យនឹងទ្រង់ធ្វើ ប្រទក្សិណព្រះនគរឡើយ ។ ព្រះរាជាត្រាស់ហៅនាយសារថីមក ហើយ ត្រាស់ថា "សុនន្ទសម្ងាញ់ អ្នកចូរត្រឡប់រថចុះ ការងារ មហោស្រពនេះមិនសមគួរដល់យើងទេ តែសមគួរដល់អភិបារក-សេនាបតី សូម្បីព្រះរាជ្យសម្បត្តិក៏សមគួរដល់អភិបារកសេនាបតី ដូចគ្នា" ហើយឲ្យនាយសារថីត្រឡប់រថ ស្តេចឡើងកាន់ប្រាសាទ ហើយទ្រង់ផ្ទំលើទីផ្ទំដែលប្រកបដោយសិរី ត្រាស់ថា

[២៣] យោ បុណ្ណមាសេ មិគមន្ទលោចនា
ឧបាវិសី បុណ្ឌរីកត្តចង្ខី
ទ្វេ បុណ្ណមាយោ តទហូ អមញ្ញី[1]
ទិស្វាន ចាវជ្ជតត្តាសិនី ។

១.ឋ. អមញ្ញំ , ម. អមញ្ញាហំ ។

ក្នុងយប់នៃវ៉ែនតេញ្ញវង់ នាងដែលមានភ្នែកស្រដៀងសត្វ ទ្រាយ រាងកាយមានពណ៌ដូចផ្កាបុណ្ឌរីក អង្គុយនៅជិតមាត់ បង្អួច ក្នុងយប់នោះ យើងបានឃើញនាងជណ្តប់សំពត់ពណ៌ ក្រហមដូចជើងព្រាប សម្ដាល់ថា ព្រះចន្ទរះពីរដួង ។

អទ្ធាវបម្ហេហិ សុកេហិ ១ គ្គុកិ
បលោកយន្តី មំ យទា ២ ទ១ ក្ខ១ តិ
ជ១ ជ១ ម្ហ១ ម១ នា ១ ហ១ ១ ១

ក៏គ្រានោះ នាងស្អ្រស់ មានខ្លួនជាពណ៌មាស ពាក់
កុណ្ឌលកែវមណី មានសំពត់ស្រ្ទាកដណ្តប់ពណ៌តែមួយ ចាន
សម្ងីងមើលយើងដូចជាមេទ្រាយសម្ងីងមើលនាយព្រាន ។

កទាស្សុ មំ តម្ពនខា សុលោមា
ពាហា មុទូ ចន្ទនសារលិត្តា
រ៉ាជ្ជ្ជ្

ព្រហ្មវនេ ជាតទុមំវ មាលុវ ។

កាលណាហ្ន៎ ធីតារបស់លោកសេដ្ឋីតិរិដិវច្ឆៈ អ្នកមានគ្រឿងប្រដាប់ទ្រូងធ្វើដោយបណ្តាញមាស ចង្ហុះមូល នឹងឧបវ៉ែតយើងដោយដៃទាំងពីរដ៏ទន់ ដូចជាវល្លិ៍ជ្រៃរួបវ៉ែតដើមឈើដែលកើតក្នុងព្រៃធំ ដូច្នោះ ។

កទាស្សុ មំ លាទារសវត្ត្ត្ត្ត្ត

ពិន្ទុត្ត្ត្ត

ត្ត

ត

ត

អ្នកលេងសុរាជូច្នោះ ។

យទាទ្ទសំ តំ តិដ្ឋន្តី សព្ពគត្តំ[1] មនោរមំ

តតោ សកស្ស ចិត្តស្ស នាវពោធាមិ កញ្ចិនំ ។

ក្នុងកាលណា យើងបានឃើញនាងដែលមានរាងកាយគ្រប់ចំណែកគួរជាកាយនៃចិត្ត ឈរហើយក្នុងកាលនោះ យើងមិនដឹងអ្វីៗ ដល់ចិត្តរបស់ខ្លួនឡើយ ។

ឧម្មាទន្តី មយា ទិដ្ឋា អាមុត្តមណិកុណ្ឌលា[2]

ន សុប្ជាមិ ទិវារត្តិ សហស្សុំ ១ បរាជិតោ ។

យើងបានឃើញនាងឧម្មាទន្តី អ្នកប្រដាប់ដោយកុណ្ឌល-កែវមណីហើយ ដេកមិនលក់ទាំងថ្ងៃ និងយប់ ដូចចាញ់ស៊ីកមក ១.000 ដង ។

សក្ខ្ជ ចេ មេ ១ ១ ១

ឯកវត្តំ ទ្វិវត្តំ វា ករេយ្យ អកិបារកា

ឧម្មាទន្ត្យា រមិត្វាន សិរីវាជ តតោ សិយា ។

បើស្តេចសក្ក:គប្បីប្រទានពរដល់យើង សូមឲ្យយើងបានពរនោះចុះ អកិបារកសេនាបតីគប្បីរីករាយហើយជាមួយនាងឧម្មាទន្តី ១ ខែ ឬ ២ ខែ តពីនោះ ព្រះបាទសិរីវាជគប្បីបានរីករាយខ្លះ ។

បណ្តាបទទាំងនោះ បទថា **ឧណ្ណមាសេ** *"ក្នុងយប់ខែពេញវង់" បានដល់ ក្នុងយប់ព្រះចន្ទពេញវង់ ។ បទថា* **មិគមន្ទូលោ-ចនា** *"មានកែវភ្នែកដូចជាសត្វទ្រាយ" សេចក្តីថា ឈ្មោះថា មិគ-មន្ទូលោចនា ព្រោះអត្ថថា មានកែវភ្នែកស្រដៀងភ្នែកសត្វទ្រាយដែលកំពុងភ័យខ្លាចកូនសរ ស្ទុះរត់ទៅឈរអែបត្រង់ចន្លោះនៃព្រៃ ហើយលបមើលព្រានព្រៃ ។ បទថា* **ឧបាវិសី** *"អង្គុយនៅក្បែរបង្ហួច" សេចក្តីថា នាងអង្គុយជិតបង្ហួច យកបាតដៃដ៏ស្អាតពណ៌

ដូចផ្ការបទុម ចាប់ផ្តើរាយដាក់ហើយសម្ងីតមើលយើង ។ បទថា **បុណ្ឌរីកត្តចង្ខី** "**រាងកាយមានពណ៌ដូចផ្ការបុណ្ឌរីក**" បានដល់ រូបកាយមានពណ៌ដូចផ្ការបទុមក្រហម ។ បទថា **ទ្វេ បុណ្ណមាយោ** "**ព្រះចន្ទរះទ្បើងពីរដួង**" សេចក្តីថា ក្នុងថ្ងៃនោះ គឺ ក្នុងថ្ងៃការងារមហោស្រពនោះ ក៏យើងបានឃើញនាងស្បៃកដណ្ដប់សំពត់ពណ៌ក្រហមដូចជាពណ៌នៃជើងសត្វព្រាបនោះហើយ ឯមើលទៅកាពល្អស្អាតនៃផ្ទៃមុខរបស់នាង បានសម្គាល់ថា ព្រះចន្ទពីរដួងរះទ្បើងព្រោះព្រះចន្ទពេញវង់អណ្ដែតទ្បើង ២ ដួង គឺ មួយដួងរះទ្បើងចាកលោកធាតុនាទិសខាងកើត មួយដួងរះទ្បើងក្នុងនិវេសន៍របស់អភិ-ជារកសេនាបតី ។ បទថា **អឡារបម្ហេ** "**មានមុខទូលាយ**" បានដល់ មានផ្ទៃមុខល្អស្អាត ។ បទថា **សុកេ** "**សស្អាត**" បានដល់ សបរិសុទ្ធ ។ បទថា **វគ្គូ** "**ដោយអាការដ៏ស្អាត**" បានដល់ ក្នុងខណៈដែលនាងសម្ងីតមើលយើងដោយកែវភ្នែកទាំងពីរ ដែល

នោះ ។ បទថា **បព្ជតេ** "**លើភ្នំ**" សេចក្ដីថា ដូចជានាំយកដួងចិត្ត របស់យើងទៅ គឺ ជ្ជន់យកទៅ ដូចជានាងកិន្នរីកើតលើកំពូលភ្នំ ហិមពាន្ត ក្នុងព្រៃដែលមានផ្ការីកស្គុសស្ពាយ កាន់ពិណបញ្ចេញ សំឡេងរបស់ខ្លួនជាមួយសំឡេងពិណ រមែងដឹកនាំចិត្តកិន្នរៈមក បាន ដូច្នោះ ។

បទថា **ព្រហតី** "**ដ៏ស្រស់ប្រិមប្រិយ**" គឺ នាងដ៏ប្រសើរ ។ បទថា **សាមា** "**មានខ្លួនពណ៌មាស**" គឺ ដែលមានខ្លួនជាពណ៌ដូចមាស ។ បទថា **ឯកចូឡសនា** "**មានសំពត់ដណ្ដប់តែមួយ**" បានដល់ នៅដោយសំពត់មួយចំណែក ។ អធិប្បាយថា មានសំពត់ដណ្ដប់មួយកំណាត់ ។ ដោយបទថា **ឧន្ទាវុ ទិក្ខតិ** "**ជៀងមើលយើងដូចជាមេម្រ៉ីគទ្រាយសម្ងឹងមើលនាយព្រានដូច្នោះ**" ព្រះរាជាត្រាស់ថា "ស្រីដ៏ខ្ពង់ខ្ពស់នោះ មានសរសៃសក់ល្អិត មានមុខធំទូលាយ មានចិញ្ចើមវែងរៀវ មានភ្នែកធំស្អាត មានច្រមុះស្រួច មានបបូរ

មាត់ក្រហម ធ្មេញទាំងឡាយសស្អាត មានចង្កូមមុត មានកមូលរលោងល្អ មានដៃទន់ មានដោះតាក់តែងល្អស្អាត មានចង្កេះល្អ ដូចមេម្រ៉ីគទ្រាយ មានត្រគាកធំ មានរូបរាងស្មើដូចដើមចេកមាស ក្នុងខណៈដែលនាងសម្ងឹងមើលយើង រមែងសម្ងឹងមើលដូចមេម្រ៉ីគ គេចចូលព្រៃព្រោះសេចក្តីខ្លាច ហើយបែរមកមើលនាយព្រានទៀតដូច្នោះ" ។ បទថា **ពាហាមុទុ**[1] **មានដើមដៃទន់**" បានដល់ មានដើមដៃទន់ល្ងន់ ។ បទថា **សន្ទតធីរកុត្តិយា "មានកួនមាយា"** គឺ មានកួនឈ្វាសក្នុងអាការម្ចុកម្ជ៉ក់ ។ បទថា **ឧបញ្ញិស្សតិ មំ**[2] **"នឹងបានឱ្យតែយើង"** សេចក្តីថា ព្រះរាជាទ្រង់រើរវាយប្រាជ្ញាថា "នារីដ៏ស្អាតនោះមានក្រចកទាំងអស់ពណ៌ក្រហម ប្រសប់ក្នុងអាការម្ចុកម្ជ៉ក់ ស្អាតតាំងអំពីសីស: កាលណាហ្ន៎ ទើបនឹងបានឱ្យតែនូវយើង" ។ បទថា **កាញ្ចនជាលុវច្ឆទា "មានគ្រឿងប្រដាប់ទ្រូងធ្វើ**

បិដក. ១. ពាហាមុទុ ។ ២. ឧបញ្ញិស្សតិ ។

ដោយបណ្ដាញមាស *" បានដល់ ដែលប្រដាប់តាក់តែងដោយគ្រឿង ប្រដាប់ទ្រូងដោយបណ្ដាញមាស ។ បទថា* ***វិលាកមជ្ឌា "ចង្កេះ មូលកូ"*** *" បានដល់ រាងកាយចំណែកត្រង់ចង្កេះ ។ បទថា* ***ព្រហា-រនេ "ក្នុងព្រៃធំ"*** *" បានដល់ ក្នុងព្រៃដ៏ធំ ។ បទថា* ***រត្តសុច្ឆវី "មានសម្បុរក្រហមស្អាត"*** *" បានដល់ មានសម្បុរដូចកែវប្រពាឡ ក្រហមដូចទឹកលក្ខ ត្រង់បាតដៃ បាតជើង ចុងក្រចក និងសាច់ បបូរមាត់ ។ បទថា* ***ពិន្ទុត្ថនី "មានដោះជាបរិមណ្ឌលដូចជុំនៃពពុះ ទឹក"*** *" បានដល់ មានដោះមូលកូដូចជុំនៃពពុះទឹក ។ បទថា* ***តតោ "ក្នុងកាលនោះ"*** *" បានដល់ ចាប់តាំងអំពីកាលយើងបានឃើញនាង ឈរហើយ ។ បទថា* ***សកស្ស ចិត្តស្ស "ដល់ចិត្តរបស់យើង"*** *មានអធិប្បាយថា យើងមិនបានកាពជាធំក្នុងចិត្តរបស់ខ្លួនឡើយ ។ ដោយបទថា* ***កញ្ចិ នំ "អ្វីៗ"*** *ព្រះរាជាត្រាស់ថា "យើងមិនដឹង អ្វីៗ ថា ស្រីនេះមានឈ្មោះដូច្នេះ យើងបានជាមនុស្សឆ្គួតហើយ" ។*

បទថា **ទិដ្ឋា** "**ជានយើញ**" ជានដល់ លុះយើញនាងហើយ ។ បទ
ថា **ន សុប្ផាមិ** "**ដេកមិនលក់**" ជានដល់ យើងរមែងមិនជាន្ទូ
ការដេកលក់ទាំងយប់ និងទាំងថ្ងៃ ។ បទថា **សោ ច លភេថ**
"**សូមឲ្យយើងគប្បីជានន្ទូពារនោះចុះ**" សេចក្ដីថា សូមឲ្យពារដែល
សក្ដិទ្រាជប្រទានដល់យើងចូរជារបស់យើងចុះ គឺ យើងគប្បីជាន
ន្ទូពារនោះចុះ ។

ពួករាជបុរស ទើបនាំគ្នាទៅប្រាប់ដល់អភិជារកសេនាបតីថា
"បពិត្រលោក ស្ដេចផ្ទៃដីទ្រង់ធ្វើប្រទក្សិណព្រះនគរ លុះទៅដល់
ទ្វារផ្ទះរបស់លោកហើយ ស្ដេចក៏ត្រឡប់ទ្បើងកាន់ប្រាសាទវិញ" ។
អភិជារកសេនាបតីនោះ ទើបទៅកាន់ផ្ទះរបស់ខ្លួន ហើយហៅនាង
ខុម្ជាទន្ដីមកសួរថា "ប្អូនសម្ងាញ់ ប្អូនសម្ដែងខ្លួនឲ្យប្រាកដដល់ព្រះ
រាជាឬ" ។ នាងតបថា "ចា៎ មានបុរសម្នាក់ ពោះធំចង្ហ្ងមធំ ឈរ
លើរថ ខ្ញុំមិនស្គាល់បុរសនោះថាជាព្រះរាជា ឬមិនមែនព្រះរាជាទេ

តែពួកមនុស្សពោលថា ជាឯកបុរស ជាធំ ខ្ញុំឈរនៅក្បែរមាត់បង្ហួច ទើបបានបាចផ្ការ៉ាចុះទៅ បុរសនោះឈរមួយស្រមៃ ក៏ត្រឡប់ទៅ" ។ អភិបាកសេនាបតីបានស្តាប់ពាក្យនោះហើយ ទើបគិតថា "ប្អូនធ្វើឲ្យបងវិនាសហើយដោយពិត" លុះស្អែកឡើង ទើបប្រញាប់ទៅកាន់ព្រះរាជនិវេសន៍អំពីព្រឹក ឈរនៅត្រង់ទ្វារបន្ទប់ដ៏មានសិរី បានញ្ជូនសំឡេងព្រះរាជារ៉ាវ៉ាយដល់នាងឧម្មាទន្តី ទើបគិតថា "ព្រះរាជាអង្គនេះមានព្រះទ័យស្រឡាញ់ក្នុងនាងឧម្មាទន្តី បើមិនបាននាងគង់ទ្រង់សុគតដោយពិត យើងគួរនឹងជួយដោះទោសដែលមិនមែនជាគុណទាំងរបស់ព្រះរាជា និងរបស់យើងចេញ ហើយថ្វាយជីវិតចំពោះព្រះរាជាអង្គនេះ" ទើបត្រឡប់ទៅកាន់ផ្ទះខ្លួនហើយ ប្រាប់ឲ្យហៅអ្នកបម្រើដែលស្និទ្ធម្នាក់មកប្រាប់ថា "នែបាអើយ នៅត្រង់ទីឯណោះ មានដើមឈើចាស់មានព្រៃមួយដើម អ្នកកុំឲ្យនរណាដឹងពេលព្រះអាទិត្យអស្តង្គតហើយ អ្នកចូរទៅកាន់ទីនោះ ចូលទៅ

អង្គុយក្នុងដើមឈើ ខ្ញុំនឹងធ្វើពលីកម្មត្រង់ដើមឈើនោះ លុះទៅ
ដល់ដើមឈើនោះ នឹងនមស្ការទេវតា ហើយអង្វរថា បពិត្រទេ-
វរាជដែលជាធំ កាលមហាស្រពមានក្នុងព្រះនគរ ព្រះរាជារបស់
ពួកខ្ញុំទ្រង់មិនបានលេង ស្តេចត្រឡប់ទៅកាន់បន្ទប់ដ៏មានសិរី ទ្រង់
ផ្ទំរវើរវាយ ពួកខ្ញុំមិនជ្រាបដល់ហេតុនោះទេ្ឃយ ព្រះរាជាទ្រង់មាន
ឧបការៈច្រើនដល់ពួកទេវតា ទ្រង់លះទ្រព្យ ១.០០០ ឲ្យធ្វើពលីកម្ម
រាល់ៗ កន្ទះឆ្នាំ សូមពួកលោកជ្រាប់ថា ព្រះរាជាទ្រង់រវើរវាយព្រោះ
អាស្រ័យហេតុឈ្មោះនេះ យើងនឹងអង្វរថា ចូរឲ្យទានជីវិតដល់
ព្រះរាជារបស់ពួកខ្ញុំផងចុះ ក្នុងខណៈនោះ ខ្ជូនអ្នកគប្ប៉ីធ្វើសំឡេង
ហើយពោលថា ម្នាលសេនាបតី ដែលឈ្មោះថា ការឈឺចាប់មិន
បានមានដល់ព្រះរាជារបស់ពួកលោកទេ្ឃយ តែព្រះអង្គមានចិត្តជាប់
ជំពាក់ក្នុងនាងឧម្មាទន្តីជាភរិយារបស់លោក បើព្រះអង្គបាននាងក៏
នឹងមានជីវិត បើមិនបាននាងនឹងសុគតដោយពិត បើលោកជ្រាជ្ញា

ន៏ងឲ្យព្រះអង្គតាំងព្រះជន្មនៅ ក៏ចូរថ្វាយនាងឧម្មាទន្តីចំពោះព្រះរាជាចុះ ដូច្នេះ” ឲ្យអ្នកបម្រើចាំនូវពាក្យទាំងនោះហើយទើបបញ្ជូនទៅ អ្នកបម្រើក៏ទៅអង្គុយក្នុងព្រង់ឈើនោះ ។ លុះស្អែកឡើង សេនា-បតីទៅកាន់ស្ថានទីនោះហើយ ទើបពោលពាក្យអង្វរ ។ អ្នកបម្រើ ក៏ធ្វើតាមពាក្យគ្រប់ប្រការ ។ សេនាបតីពោលថា “ល្អហើយ” ក៏ បានសំពះទេវតា ប្រាប់ឲ្យពួកអាមាត្យជ្រាបរឿងនោះ ហើយចូល ទៅកាន់ព្រះនគរ ឡើងទៅកាន់ព្រះរាជនិវេសន៍ គោះទ្វារបន្ទប់ផ្ទុំ ដែលប្រកបដោយសិរី ។ ព្រះចៅផែនដីត្រឡប់បានស្គាល់តី ហើយ ត្រាស់សួរថា “នរណាហ្នឹង?” អភិបាលកសេនាបតីទើបក្រាបទូលថា “បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គ គឺ អភិបាលកសេនាបតី” ។ ត្រា នោះ ព្រះរាជាទ្រង់បើកទ្វារឲ្យសេនាបតី ។ សេនាបតីទើបចូលទៅ ថ្វាយបង្គំចំពោះព្រះរាជា ហើយពោលគាថាថា

[២៤] ***ភូតានិ មេ ភូតបតី នមស្សតោ***

អាគម្ម យក្ខា ឥទមេតទព្រវី

រញ្ញោ មនោ ឧម្មាទន្ត្យា និវិដ្ឋោ

ទទាមិ តេ នំ បរិចារយស្សុ ។

បពិត្រព្រះអង្គជាធំលើជន កាលខ្ញុំព្រះអង្គនមស្ការទេវតាទាំងឡាយហើយ ទេវតាបានប្រាប់សេចក្តីនេះដល់ខ្ញុំព្រះអង្គថា ព្រះទ័យរបស់ព្រះរាជាជាប់ជំពាក់ក្នុងនាងឧម្មាទន្តី ខ្ញុំព្រះអង្គសូមថ្វាយនាងចំពោះព្រះអង្គ សូមព្រះអង្គចូរឲ្យនាងបម្រើចុះ ។

*បណ្តាបទទាំងនោះ បទថា **នមស្សតោ** "**នមស្ការ**" បានដល់ការដែលខ្ញុំព្រះអង្គធ្វើនូវពលីកម្មបួងសួងហើយ ដើម្បីនឹងដឹងដល់ហេតុនៃការរវើរវាយរបស់ព្រះអង្គ ។ បទថា **តំ** "**នាង**" បានដល់ខ្ញុំព្រះអង្គសូមថ្វាយនាងឧម្មាទន្តីនោះ ឲ្យជាបាទបរិចារិកាប្រចាំព្រះអង្គ ។*

លំដាប់នោះ ព្រះរាជាត្រាស់សួរសេនាបតីថា "អកិបារកៈ សម្ងាញ់ សូម្បីពួកទេវតាក៏ដឹងរឿងដែលយើងរើរវាយព្រោះមានចិត្តប្រាថ្នាក្នុងនាងឧម្មាទន្តីដែរឬ?" សេនាបតីទូលតបថា "ដូច្នោះមែន ព្រះអង្គ" ។ ព្រះរាជាទ្រង់ព្រះតម្រិះថា "ដំណឹងថា សេចក្តីអាក្រក់របស់យើង មនុស្សលោកទាំងអស់ក៏បានដឹងហើយ" ទ្រង់ទើបតាំងនៅក្នុងធម៌ គឺ សេចក្តីខ្វាស បានត្រាស់គាថាតទៅថា

[២៥] បុញ្ញា ច ធំសេ អមរោ ន ចម្ហិ
ជនោ ច មេ បាបមិទញ្ច ជញ្ញា
ភុសោ ច ត្យស្ស មនសោ វិយាតោ
ទត្វ បិយំ ឧម្មទន្តី អទិដ្ឋា ។

ក៏យើងគប្បីប្រាសចាកបុណ្យ ទិងមិនជាទេវតា មួយទៀត បុគ្គលគប្បីដឹងសេចក្តីអាក្រក់របស់យើងនេះ ទិងកាលលោកឲ្យនាងឧម្មាទន្តីកវិយាកំពូលស្រឡាញ់ហើយ មិនឃើញនាង

សេចក្ដីចង្អៀតចង្អល់ដ៏ខ្លាំងនឹងគប្បីមានដល់លោក ។

*បណ្ដាបទទាំងនោះ បទថា **វិធំសេ**[1] "**គប្បីប្រាស**" នយ ថា ម្នាលអភិបារកសេនាបតីសម្ងាញ់ កាលយើងបម្រើហើយនឹងនាងដោយអំណាចកិលេស រមែងវិនាសចាកបុណ្យ និងនឹងមិនបានជាទេវតា ព្រោះហេតុត្រឹមតែការបម្រើជាមួយនាងនោះ មួយទៀត មហាជនគប្បីជ្រាបសេចក្ដីអាក្រក់លាមកនេះ តពីនោះ ក៏នឹងគប្បីតិះដៀលថា "ព្រះរាជាទ្រង់ធ្វើវត្ថុដែលមិនគួរធ្វើទ្បើយ" មួយទៀត កាលលោកឲ្យដល់យើងហើយ ជាខាងក្រោយលោកមិនបានយើញនូវកិរិយាជាទីស្រឡាញ់ សេចក្ដីចង្អៀតចង្អល់ក៏នឹងគប្បីមានដល់លោក ។*

គាថាដ៏សេស ជាពាក្យសួរ និងពាក្យឆ្លើយរបស់អ្នកទាំងពីរ (គឺ របស់ព្រះរាជា និងអភិបារកសេនាបតី) ដូចតទៅនេះ ។

---

[1] ១. ធំសេ ។

[២៦] ជនិនូ នាញ្ញត្រ តយា មយា ច
សព្វាបិ កម្មស្ស កតស្ស ជញ្ញា
យន្តេ មយា ឧម្មាទន្តី បទិន្នា
ភុសេហិ ភជ្ជ រនជ្ជ សជ្ជាហិ ។

បពិត្រព្រះអង្គជាធំលើប្រជានិករ ប្រជាជនសូម្បីទាំងអស់ក្រៅពីខ្ញុំព្រះអង្គ និងព្រះអង្គចេញ មិនគប្បីដឹងកម្មដែលយើងធ្វើទេ ខ្ញុំព្រះអង្គសូមថ្វាយនាងឧម្មាទន្តីចំពោះព្រះអង្គ ព្រះអង្គទ្រង់ចូរអភិរមជាមួយនាងឲ្យពេញព្រះទ័យតាមប្រាថ្នាហើយ សូមទ្រង់លះបង់ ។

[២៧] យោ ចាបកំ ភម្ម្ករ មនុស្ស
ស្ស មញ្ញតិ មាយិទ មញ្ញិ អញ្ញ
ឧ ស្ស ន្ត ភូតានិ ភ ភ ន្ត ម
ឯ ត ច យ ហ ន្ត ន ភ ឧ ។

មនុស្សណាធ្វើកម្មដ៏លាមក មនុស្សនោះរមែងសម្គាល់ថា បុគ្គលដទៃមិនដឹងការធ្វើនេះ តែនរជនពួកណាប្រកបហើយ លើប្រ៉ៃចពី នរជនទាំងនោះរមែងឃើញគេដែលធ្វើដូច្នោះ ។

អញ្ញោ នុ តេ កោចិ នរោ បបញ្ញា

សទ្ធេយ្យ លោកស្មឹ ន មេ ឋិយាតិ

ឥធ ច ត្យស្ស មនសោ វិយោគោ

ទត្វា ឋិយំ ឧម្មាទន្តី អទិដ្ឋា ។

បុគ្គលដទៃណាហ្ន៏ ក្នុងផែនដីទូទាំងលោក គប្បីជឿលោក ឬថា នាងឧម្មាទន្តីមិនជាទីស្រឡាញ់របស់ (គឺ អកិបារកៈ) និងកាលលោកឲ្យនាងឧម្មាទន្តី ឋិយាកំពូលស្រឡាញ់ហើយ មិនឃើញនាង សេចក្តីចង្អៀតចង្អល់ចិត្តយ៉ាងខ្លាំង នឹងគប្បីកើតមានដល់លោក ។

[២៨] *អន្ធា ឋិយា មយ្ហ ជនិន្ទ ឯសា*

ន សា មមំ អប្ជិយា ភូមិបាល

គច្ឆេ ត្វំ ឧម្មាទន្តី ភទ្ទន្ត

សីហោ សេលស្ស គុហំ ឧបេតិ ។

បពិត្រព្រះអង្គជាធំលើប្រជាជន នាងឧម្មាទន្តីនោះ ជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គដោយពិត បពិត្រព្រះភូមិបាល នាងមិនបានជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គក៏មិនមែន សូមសេចក្តីចម្រើន ចូរមានចំពោះព្រះអង្គ សូមព្រះអង្គស្តេចទៅកាន់នាងឧម្មាទន្តី ដូចជារាជសីហ៍ចូលកាន់គុហាសិលាដូច្នោះ ។

[២៨] ន បីឡិតា អត្តទុក្ខេន ធីរា

សុខេ ឋិតំ ធម្ម បរិចូជន្តិ

សម្ហេហិតា ភាបិ សុខេន មត្តា

ន ធាបកម្ម ធ្ជ សមាចរន្តិ ។

អ្នកប្រាជ្ញទាំងឡាយ ត្រូវសេចក្តីទុក្ខរបស់ខ្លួនបៀតបៀន

ហើយ រមែងមិនលះបង់កម្មដែលមានផលជាសុខ សូម្បីជាអ្នកវង្វេង ស្រវឹងដោយសេចក្តីសុខ ក៏រមែងមិនប្រព្រឹត្តនូវបាបកម្ម ។

[៣០] តុវញ្ហិ មាតា ច បិតា ច មយ្ហំ
ភត្តា បតី ភោសកោ ទេវតា ច
ទាសោ អហំ តុយ្ហ សបុត្តទារោ
យថាសុខំ សីរ[(១)] ភវាហិ កាមំ ។

ក៏ព្រះអង្គទាំងជាព្រះមាតាព្រះបិតា ជាអ្នកចិញ្ចឹម ជានាយ ចៅហ្វាយ ជាអ្នកបីបាច់ និងជាទេវតារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គព្រមទាំងបុត្ត និងភរិយាជាទាសៈរបស់ព្រះអង្គ បពិត្រ ទ្រង់ជាធំលើអ្នកដែនសីរី សូមព្រះអង្គទ្រង់បរិភោគកាមតាមសប្បាយចុះ ។

១.ម. សាមិ, ខ. សិពូ ។

[៣១] យោ ឥស្សរោម្ហីតិ ករោតិ បាបំ
កត្វា ច សោ នុត្តបតេ បរេសំ
ន តេន សោ ជីវតិ ទីឃមាយុ
ទេវាបិ ចាបេន សមេក្ខរេ នំ ។

បុគ្គលណារមែងធ្វើបាប ដោយសេចក្តីសម្គាល់ថា យើងជាអ្នកធំក្រៃលែង និងគ្រាធ្វើហើយ ក៏មិនកន្ត្រាចចំពោះជនដទៃ បុគ្គលនោះរមែងមិនរស់នៅរហូតអស់អាយុវែង ព្រោះកម្មនោះ សូម្បីទេវតាក៏សម្ងឹងមើលបុគ្គលនោះដោយភ្នែកដ៏អាក្រក់ ។

[៣២] អញ្ញាតកំ សាមិកេហិ បទិន្នំ
ធម្ម បិតា យេ បដិច្ចន្តិ ទានំ
បដិច្ចកា ទាយកា ចាបិ តត្ត
សុខ្ចលញ្ជេ ករោន្តិ កម្មំ ។

ជនពួកណាតាំងនៅក្នុងធម៌ រមែងទទួលទានដែលជារបស់អ្នកដទៃដែលម្ចាស់ទានប្រគល់ឲ្យហើយ ជនពួកនោះជាអ្នកទទួលផង ជាអ្នកឲ្យក្នុងទាននោះផង បានឈ្មោះថា ធ្វើកម្មដែលមានផលជាសុខព្រោះទាននោះដោយពិត ។

[៣៣] អញ្ញោ នុ តេ កោចិ នរោ បបញ្ចា
សទ្ធេយ្យ លោកស្មិ ន មេ បិយាតិ
ភុសោ ច ត្យស្ស មនសោ វិយោគោ
ទត្វា បិយំ ឆម្មាទន្តី អទិដ្ឋា ។

ជនដទៃណាហ្ន៎ក្នុងផែនដីទូទាំងលោកជ្រៀលោកឬថា នាងឆម្មាទន្តីមិនជាទីស្រឡាញ់របស់យើង (គឺអកិបារកៈ) និងបើលោកឲ្យនាងឆម្មាទន្តីកំពូលកវិយាជាទីស្រឡាញ់ហើយ មិនឃើញនាង សេចក្ដីចង្អៀតចង្អល់ចិត្តដ៏ខ្លាំង នឹងគប្បីមានដល់លោក ។

[៣៤] អន្ធា ឋិយា មយ្ហ ជនិន្ទ ឯសា
ន សា មមំ អប្ជិយា ភូមិបាល
យន្តេ មយា ឧម្មាទន្តី បទិន្នា
ភុសេហិ រាជ រនេ សជាហិ ។

បពិត្រព្រះអង្គជាធំលើប្រជាជន នាងឧម្មាទន្តីនោះ ជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គដោយពិត បពិត្រព្រះភូមិបាល នាងមិនជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គក៏ទេ ខ្ញុំព្រះអង្គព្រមថ្វាយនូវនាងឧម្មាទន្តីចំពោះព្រះអង្គ ព្រះអង្គចូរទ្រង់អភិរមជាមួយនាងពេញព្រះទ័យហើយ ទ្រង់ចូរលះបង់ចុះ ។

[៣៥] យោ អត្តទុក្ខេន បរេស្ស ទុក្ខំ
សុខេន វា អត្តសុខំ ទហាតិ
យថេវ ទ្ធ មយ្ហ តថា បរេសំ
យោ ឯវ ជានាតិ ស វេទ ធម្មំ ។

ជនណាបង្ក្នូវទុក្ខឲ្យដល់អ្នកដទៃដោយទុក្ខរបស់ខ្លួន ឬ
បង្ក្នសេចក្ដីសុខរបស់ខ្លួន ដោយដណ្ដើមសេចក្ដីសុខរបស់អ្នក
ដទៃ ជនណាដឹងយ៉ាងនេះថា សេចក្ដីសុខ និងសេចក្ដីទុក្ខរបស់
យើងនេះក៏ដូចអ្នកដទៃ ជននោះឈ្មោះថា ដឹងធម៌ ។

[៣៦] អញ្ញោ នុ តេ កោចិ បវោ ឧបវ្ជ
សទ្ធេយ្យ លោកស្មិ ន មេ ឧិយាតិ
ភុសោ ច ត្យស្ស មនសោ ឧិយាតោ
ទត្ជ្ជ ឧិយំ ឧម្ជាទន្ដ្ដ អទិដ្ជ ។

ជនដទៃណាហ្ន៎ ក្នុងផែនដីទូទាំងលោកគប្ជីជ្ជៀលោកឬថា
នាងឧម្ជាទន្ដ្ដីមិនជាទីស្រឡាញ់របស់យើង និងកាលលោកឲ្យ
នាងឧម្ជាទន្ដ្ដីកំពូលកវិយាជាទីស្រឡាញ់ ហើយមិនឃើញនាង
ការចង្ជ្ជៀតចង្ជ្ជល់ចិត្ដយ៉ាងខ្លាំង ទ្ជ៎ងគប្ជីមានដល់លោក ។

[៣៧] ជនិនូ ជានាសិ ឧិយា ម្ជមេសា

ន សា មមំ អប្ជ្ជិយា ភូមិបាល

បិយេន តេ ទម្មិ បិយំ ជនិន្ទ

បិយទាយិនោ ទេវ បិយំ លភន្តិ ។

បពិត្រព្រះអង្គជាធំលើប្រជាជន ព្រះអង្គរមែងទ្រង់ជ្រាបថា នាងឧម្មាទន្តីនេះជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ បពិត្រព្រះភូមិបាល នាងមិនជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គក៏ទេ ខ្ញុំព្រះអង្គសូមថ្វាយវត្ថុដែលជាទីស្រឡាញ់ចំពោះព្រះអង្គដោយវត្ថុជាទីស្រឡាញ់ បពិត្រព្រះសម្មតិទេព អ្នកឲ្យវត្ថុដែលជាទីស្រឡាញ់រមែងបានវត្ថុដែលជាទីស្រឡាញ់ ។

[៣៨] សោ ទូនាហំ វធិស្ជ្ជាមិ អត្តានំ កាមហេតុកំ

នហិ ធម្មំ អធម្មេន អហំ វធិតុមុស្ជ្ជហេ ។

យើងនោះមានកាមនេះជាហេតុ នឹងសម្លាប់ខ្លួនដោយពិត យើងមិនអាចសម្លាប់ដោយអធម៌បានឡើយ ។

[៣៩] សចេ តុវំ មយ្ហ សតី ជនិន្ទ
ន កាមយាសិ នរវីរសេដ្ឋ
ចជាមិ នំ សព្វជនស្ស មជ្ឌ
មយា បមុត្តំ តតោ អ្ហ្យេសិនំ ។

បពិត្រព្រះអង្គជាធំលើប្រជាជន ទ្រង់ក្ដៀវក្លាជាងនរជនដ៏ប្រសើរ បើព្រះអង្គមិនពេញព្រះទ័យនឹងនាងឧម្មាទន្តីដែលជារបស់ខ្ញុំព្រះអង្គសោត ខ្ញុំព្រះអង្គនឹងលះបង់នាងក្នុងកណ្ដាលជនទាំងពួង ព្រះអង្គគប្បីនាំនាងដែលផុតអំពីខ្ញុំព្រះអង្គហើយមកអំពីទីនោះចុះ ។

[៤០] អទ្ទូសិយាញ្ជ អកិបារក តុវំ
ចជាសិ ឥត្ថ អហិតាយ ត្យស្ស
មហា ច ឥត ឧបវាទោបិ អស្ស
ន ចាបិ ត្យស្ស ន ឥ ម្ហិ ឥ ។

អកិបារកសេនាបតីអ្នកធ្វើនូវប្រយោជន៍ ប្រសិនបើលោកនឹងលះបង់នាងឧម្មាទន្តីដែលជាអ្នកកាកោសមិនបាន ដើម្បីវត្ថុដែលមិនជាប្រយោជន៍ដល់លោក សេចក្តីចង្អៀតចង្អល់យ៉ាងខ្លាំងនឹងគប្បីមានដល់លោក មួយទៀត សូម្បីអ្នកចូលខាងក្នុងព្រះនគរនេះក៏មិនមាន ។

[៤១] អហំ សហិស្សុ ឧបវាទមេតំ
និន្ទុ បសំសំ គរហាញ្ជ សញ្ញ
មមេតមាគច្ឆតុ ភូមិបាល
យថាសុខំ សីរិ ករោហិ ការ ។

បពិត្រព្រះភូមិបាល ខ្ញុំព្រះអង្គនឹងទ្រាំនឹងពាក្យស្តីបន្ទោស ពាក្យនិន្ទា ពាក្យសរសើរ និងពាក្យតិះដៀលនេះទាំងអស់ ក៏ពាក្យស្តីបន្ទោសជាដើមនោះ ចូរធ្លាក់មកលើខ្ញុំព្រះអង្គ បពិត្រព្រះអង្គជាធំជាងជនក្នុងដែនសីរី សូមព្រះអង្គបរិភោគកាមតាម

សប្ប្យាយចុះ ។

យោ នេវ និន្ទំ ន បុនប្ប្យសំសំ

អាទិយតិ គរហំ នោបិ ១ បូជំ

សិរី ច លក្ខ្មី ១ ១ អ១ បតិ ១ ១ ១

អ១ ១ ១

ខ្ញុំព្រះអង្គព្រមទទួលសេចក្ដីទុក្ខ និងសេចក្ដីសុខ វត្ថុដែលកន្ទងធម្មតា និងសេចក្ដីចង្អៀតចង្អល់ទាំងអស់ ព្រោះហេតុនៃការលះបង់នេះ ដោយទ្រូង ដូចផែនដីដែលទទួលរងនូវវត្ថុទាំងរបស់មនុស្សមាំមួន និងមនុស្សអ្នកកាយខ្វាចជូច្នោះ ។

[៤២] ធម្មាតិសារញ្ហ មនោវិឃាតំ
ទុក្ខញ្ហ និច្ចាមិ អហំ បរេសំ
ឯកោបិមំ តារយិស្សាមិ ភារំ
ធម្ម ឋិតោ កិញ្ចិ អហាបយន្តោ ។

យើងមិនប្រាថ្នាវត្ថុដែលកន្ទងធម្មតា សេចក្ដីចង្អៀតចង្អល់ចិត្ត និងសេចក្ដីទុក្ខដល់ជនដទៃទេ យើងតែម្នាក់ប៉ុណ្ណោះនឹងជាអ្នកតាំងនៅក្នុងធម៌ មិនញ៉ាំងប្រយោជន៍តិចតួចឲ្យវិនាសនឹងធ្លងការៈនេះទៅ ។

[៤៣] សគ្ហបគំ បុញ្ញកម្មំ ជនិន្ទ

មា មេ តុវំ អន្តរាយំ អកាសិ

ទទាមិ តេ ឧម្មាទន្តី បសន្នោ

រាជាវ យញ្ញ ធនំ ព្រាហ្មណានំ ។

បពិត្រព្រះអង្គជាធំលើប្រជា បុញ្ញកម្មរមែងឲ្យចូលដល់

សួគ៌ ព្រះអង្គទ្រង់កុំបានធ្វើអន្តរាយដល់ខ្ញុំព្រះអង្គឡើយ ខ្ញុំ

ព្រះអង្គមានចិត្តជ្រះថ្លា សូមថ្វាយនាងឧម្មាទន្តីចំពោះព្រះអង្គ

ដូចព្រះរាជាទ្រង់ប្រទានទ្រព្យសម្រាប់បូជាយញ្ញ ដល់ព្រាហ្មណ៍

ទាំងឡាយដូច្នោះ ។

[៤៤] អន្ធា តុវំ ភត្តេ ហិតោសិ មយ្ហំ

សខា មមំ ឧម្មាទន្តី តុវញ្ច

និន្ទូយ្យ ទេវា បិតរោ ច សព្វេ

ជាបញ្ច បស្សុ អភិសម្ជរាយ ។

លោកជាអ្នកចម្រើនដល់យើង ក្នុងការធ្វើនូវប្រយោជន៍

ដោយពិត នាងឧម្មាទន្តី និងលោកជាសម្ងាញ់របស់យើង ទេវតា និងព្រហ្មទាំងអស់ឃើញសេចក្តីអាក្រក់ដែលប្រព្រឹត្ត ទៅចំពោះមុខ គប្បីតិះដៀលបាន ។

[៤៥] នហេតំ ធម្មំ សីវិរាជ រាជ្ញ
សនេគមា ជានបទា ច សព្វ
យន្ត មយា ឧម្មាទនី បទិន្នា
ភុសេហិ រាជា រនេ ចំ សជាហិ ។

បពិត្រព្រះសីវិរាជ អ្នកនិគម និងអ្នកជនបទទាំងអស់មិន គប្បីជំទាស់នូវកម្មជាធម៌នោះឡើយ ខ្ញុំព្រះអង្គសូមថ្វាយនាង ឧម្មាទន្តីចំពោះព្រះអង្គ ព្រះអង្គចូរទ្រង់អភិរមជាមួយនាងតាម ពេញព្រះទ័យប្រាថ្នាចុះ ហើយសូមទ្រង់លះបង់ ។

[៤៦] អទ្ធា តុវំ ភត្តេ ហិ តោសិ មយ្ហ
សា មមំ ឧម្មាទន្តី តុ រាជ

សតញ្ច ធម្មានិ សុកិត្តិតានិ

សមុទ្ទវេលាវ ទុរច្ចយានិ ។

លោកជាអ្នកចម្រើនដល់យើង ក្នុងការធ្វើនូវប្រយោជន៍ដោយពិត នាងឧម្មាទន្តី និងលោកជាសម្ងាញ់របស់យើង ធម៌របស់សប្បុរសដែលប្រកាសល្អហើយ លំបាកនឹងប្រព្រឹត្តកន្លងបាន ដូចជាដែននៃមហាសមុទ្ទដូច្នោះ ។

[៤៧] *អាហុនេយ្យោ មេសិ ហិតានុកម្ប្យ*

ធាតា វិធាតា ចសិ កាមបាលោ

តយី ហុតា ភាជ មហប្ផលា ហិ

ការេន មេ ឧម្មាទន្តី ចជិច្ច ។

បពិត្រព្រះរាជា ព្រះអង្គទ្រង់គួរគោរពរបស់ខ្ញុំព្រះអង្គ ជាអ្នកប្រាថ្នាប្រយោជន៍ដ៏ធំ ទ្រង់ជាអ្នកទ្រទ្រង់ទុកដ៏យ៉ាងពិសេស និងទ្រង់រក្សានូវសេចក្តីប្រាថ្នា ព្រោះថា យញ្ញដែលបូជាក្នុង

ព្រះអង្គរមែងមានផលច្រើន សូមព្រះអង្គទ្រង់ទទួលយកនាង ឧម្មាទន្តីតាមសេចក្តីប្រាថ្នារបស់ខ្ញុំព្រះអង្គចុះ ។

[៤៨] អទ្ធា ហិ សញ្ជ អកិបារ តុវ
ធម្មំ អចារី មម កត្តុបុត្ត
អញ្ញ នុ តេ ក ឥធ សោត្ថិកត្តា
ទ្វិបទ នវ អរុណ ជីវលោកេ ។

អកិបារសេនាបតី ជាបុត្តរបស់លោកអ្នកធ្វើប្រយោជន៍ លោកបានប្រព្រឹត្តហើយនូវធម៌ទាំងពួងដល់យើង ដោយពិត មនុស្សជើងពីរដទៃ នរណាហ្ន៎ នឹងជាអ្នកធ្វើនូវសេចក្តីសួស្តី ក្នុងវេលាអរុណរះឡើងក្នុងជីវលោកនេះដល់លោក ។

[៤៩] ត្វ នុ សេដ្ឋ ត្ងមនុត្តរោសិ
ត្ងំ ធម្មគូ ធម្មវិទូ សុមេធ
សោ ធម្មគុត្តោ ចិរមេវ ជីវ

ធម្មញ្ច មេ ទេសយ ធម្មបាល ។

ព្រះអង្គដ៏ប្រសើរ ទ្រង់ជាកំពូល ទ្រង់ដំណើរដោយធម៌ ទ្រង់ដ៏ឆ្លាស់នូវធម៌ មានព្រះបញ្ញាល្អ សូមព្រះអង្គដែលធម៌ យុំគ្រងហើយ ទ្រង់ចូរមានព្រះជន្មយឺនយូរ បពិត្រព្រះអង្គទ្រង់ រក្សាធម៌ សូមព្រះអង្គប្រោសសម្តែងធម៌ដល់ខ្ញុំព្រះអង្គចុះ ។

[៥០] តទិង្ឆ អកិបារក សុណោហិ វចនំ មម
ធម្មន្តេ ទេសយិស្សាមិ សតំ អាសេវិតំ អហំ ។

អកិបារកសេនាបតី សូមលោកស្តាប់ពាក្យរបស់យើងចុះ យើងនឹងសម្តែងធម៌ដែលសប្បុរសសេពហើយដល់លោក ។

សាធុ ធម្មរុចី រាជា សាធុ បញ្ញាណវា នរោ
សាធុ មិត្តានមទ្ធុ ភ្លោ ជាបសន្ទ្ធការណំ សុខំ ។

ព្រះរាជាពេញចិត្តក្នុងធម៌ទើបល្អ នរជនអ្នកមានការដឹងដោយជុំវិញទើបល្អ ការមិនប្រទូស្តចំពោះមិត្តទើបល្អ ការមិន

ធ្វើបាបជាសុខ ។

អក្កោធនស្ស វិជិតេ ឋិតធម្មស្ស រាជិនោ

សុខំ មនុស្សា អាសេថ សីតច្ឆាយាយ សង្ឆវេ ។

មនុស្សទាំងឡាយគប្បីនៅជាសុខក្នុងផ្ទះរបស់ខ្លួន ដែលម្ចប់ត្រជាក់ ក្នុងដែនរបស់ព្រះរាជាដែលទ្រង់មិនក្រោធ អ្នកតាំងនៅក្នុងធម៌ ។

ន ចាហមេតំ អកិរោចយាមិ

កម្មំ អសមេក្ខកតំ អសាធុ

យេ ភាបិ ញត្វា ន សយំ ករោន្តិ

ឧបមា ឥមា មយ្ហ តុវំ សុណោហិ ។

យើងរមែងមិនគាប់ចិត្តក្នុងកម្មដែលធ្វើដោយមិនពិចារណា ដែលជាកម្មមិនល្អនោះឡើយ សូម្បីព្រះរាជាពួកណាទ្រង់ជ្រាបហើយ ទ្រង់ធ្វើឯង យើងពេញចិត្តកម្មរបស់ព្រះរាជាទាំងនោះ

សូមលោកចូរស្តាប់ឧបមារបស់យើងដូចតទៅនេះ ។

គវញ្ចា តរមានានំ ជិម្ហំ គচ্ছតិ បុঙ্গវো

សព្វា តា ជិម្ហំ គচ্ছন্តি នេត្តេ ជិម្ហំ គតេ សតি ។

កាលហ្វូងគោហែលឆ្លងត្រើយទៅ បើគោជាមេហ្វូងនាំទៅ

រៀច គោទាំងអស់នោះក៏ហែលទៅរៀច ក្នុងកាលគោមេហ្វូង

នាំទៅរៀច យ៉ាងណា ។

ឯវមេវ មនុស្សេសុ យោ ហោតি សេដ្ឋសម្មតោ

សោ চে អធម្មំ চরতি បគេវ ឥតរា បជា

សព្វំ រដ្ឋំ ទុក្ខំ សেতি រាជা চে ហোতি អធម្មিকো ។

ក្នុងពួកមនុស្សក៏យ៉ាងនោះដូចគ្នា បុគ្គលណាទទួលនូវការ

សរសើរថា ជាអ្នកប្រសើរបំផុត បើបុគ្គលនោះប្រព្រឹត្តអធម្ម

ន៏ងចាំបាច់ពោលថ្វីដល់ប្រជាជនក្រៅអំពីនេះ រដ្ឋទាំងអស់រមែង

នៅជាទុក្ខ បើព្រះរាជាមិនតាំងនៅក្នុងធម្ម ។

គវញ្ចេ តរមានានំ ឧជុំ គច្ឆតិ ឫជ្ជវោ

សព្វា តា ឧជុំ គច្ឆន្តិ នេត្តេ ឧជុំ គតេ សតិ ។

កាលហ្វូងគោហែលឆ្លងត្រើយទៅហើយ បើគោមេហ្វូងហែលទៅត្រង់ គោទាំងអស់នោះក៏ហែលទៅត្រង់ ក្នុងកាលគោមេហ្វូងនាំហែលទៅត្រង់ យ៉ាងណា ។

ឯវមេវ មនុស្សេសុ យោ ហោតិ សេដ្ឋសម្មតោ

សោ ចេបិ ធម្មំ ចរតិ បគេវ ឥតរា ឧជា

សព្វំ រដ្ឋំ សុខំ សេតិ រាជា ចេ ហោតិ ធម្មិកោ ។

ក្នុងពួកមនុស្សក៏យ៉ាងនោះ បុគ្គលណាទទួលការសរសើរថា ជាអ្នកប្រសើរបំផុត បើបុគ្គលនោះប្រព្រឹត្តធម៌ នឹងចាំបាច់ពោលថ្វីដល់ប្រជាជនក្រៅពីនេះ រដ្ឋទាំងអស់រមែងនៅជាសុខ បើព្រះរាជាតាំងនៅក្នុងធម៌ ។

ន ចាបាហំ អធម្មេន អមរត្តមកិបត្តយ

ឥមំ វា បឋវឺ សព្ពំ វិជេតុំ អភិបារកេ ។

អភិបារកសេនាបតី យើងមិនប្រាថ្នាកាពជាទេវតា និង

ដើម្បីគ្រប់គ្រងផែនដីទាំងអស់នេះដោយអធម្ម ។

យញ្ចិ កិញ្ចិ មនុស្សេសុ រតនំ ឥធ វិជ្ជតិ

គាវោ ទាសោ ហិរញ្ញញ្ច ឥត្ថិយំ ហារិចន្ទនំ ។

រតនៈណាមួយ គឺ គោ ទាសៈ ប្រាក់ សំពត់ និងចន្ទន៍-

ក្រហម ដែលមានក្នុងមនុស្សលោកនេះ ព្រោះតែរតនៈទាំង

នោះទេ្បីយ ។

អស្សត្ថិយោ រតនំ មណិកញ្ច

យញ្ចាបិមេ សន្ទ្ធសុរិយោ អភិបាលយន្តិ

ន តស្ស ហេតុ វិសមំ ចរេយ្យ

មជ្ឌ សិរីនំ ឧសភោស្មិ ជាតោ ។

បុគ្គលមិនគប្បីប្រព្រឹត្តទុសធម្ម ព្រោះហេតុនៃសម្បត្តិជា

ដើមថា សេះ ស្រី កែវមណី ឬសូម្បីវត្ថុដែលព្រះចន្ទ និង ព្រះអាទិត្យទាំងនេះកក្ឃាហើយ យើងជាអ្នកអង់អាច ក្នុងកណ្ដាលនៃដែនសីរីទាំងឡាយដូច្នោះ យើងមិនប្រព្រឹត្តទុសធម៌ ព្រោះហេតុនៃសម្បត្តិនោះ ។

នេតា ហិតា ឧគ្គតោ រដ្ឋបាលោ
ធម្មំ សីរីនំ អបចាយមានោ
សោ ធម្មមេវានុវិចិន្តយន្តោ
តស្មា សកេ ចិត្តវសេ ន វត្តោ ។

យើងជាអ្នកនាំ ទ្រង់ជាអ្នកផ្ទុងផ្ដើម ជាអ្នកចម្រើនរុងរឿង ជាអ្នកគ្រប់គ្រងដែន ទ្រង់ជាអ្នកគោរពធម៌រឿយៗ ព្រោះដូច្នោះ ទ្រង់មិនប្រព្រឹត្តទៅក្នុងអំណាចនៃចិត្តរបស់ខ្លួន ។

[៥១] អទ្ធា តុវំ មហារាជ និច្ចំ អព្យសនំ សិរី
ករិស្សសិ ចិរំ រជ្ជំ បញ្ញា ហិ តវ តាទិសី ។

បពិត្រមហារាជ ព្រះអង្គទ្រង់ប្រព្រឹត្តធម៌ ដែលមិនមានសេចក្តីវិនាស ជាដែនក្សេមហើយជានិច្ចដោយពិត ព្រះអង្គនឹងតាំងនៅក្នុងរាជ្យសម្បត្តិយឺនយូរ ព្រោះព្រះបញ្ញារបស់ព្រះអង្គនោះឯង ។

ឯតន្ត អនុមោទាម យំ ធម្មំ នប្ប្រមជ្ជសិ

ធម្មំ ២ មជ្ជ ២ ត្តិយោ រជ្ជា ចវតិ ឥស្សរោ ។

ព្រះអង្គទ្រង់មិនប្រមាទក្នុងធម៌ណា ខ្ញុំព្រះអង្គសូមអនុ-មោទនាធម៌នោះរបស់ព្រះអង្គ ក្សត្រជាធំ ទ្រង់ប្រមាទក្នុងធម៌ហើយ រមែងឃ្លាតចាករជ្ជ ។

ធម្មញ្ហារ មហារាជ មាតាបិតូសុ ២ ត្តិយ

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្ស្ស ។

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងព្រះជនន៍ និងព្រះជនក គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនុ៎ះហើយ ស្តេច

ទ៏ងទៅកាន់សួគ៌ ។

ធម្មញ្ចារ មហារាជ បុត្តទារេសុ ខត្តិយ

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងព្រះរាជបុត្ត និងព្រះម-
ហេសី គ្រាព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្តេច
ទ៏ងទៅកាន់សួគ៌ ។

ធម្មញ្ចារ មហារាជ មិត្តាមច្ចេសុ ខត្តិយ

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងមិត្ត និង
អាមាត្យ គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្តេចទ៏ង
ទៅកាន់សួគ៌ ។

ធម្មញ្ចារ មហារាជ រាហនេសុ ពលេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងរាជពាហនៈ និងពលទាហាន គ្រាទ្រង់ប្រព្រឹត្តនូវធម៌ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចារ មហារាជ គាមេសុ និគមេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងស្រុក និងនិគម គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចារ មហារាជ រដ្ឋេសុ ជនបទេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងពួកអ្នកដែន និងអ្នកជនបទ គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ សមណ ព្រាហ្មណេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងសមណៈ និងព្រាហ្មណ៍ គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ មិគបក្ខីសុ ខត្តិយ

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ក្នុងម្រឹគ និងបក្សីទាំងឡាយ គ្រាទ្រង់ប្រព្រឹត្តនូវធម៌ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ ធម្មោ ចិណ្ណោ[1] សុខាវហោ

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

១.ម. សុចិណ្ណ ។

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ចុះ ព្រោះថា ធម៌ដែលប្រព្រឹត្តហើយ រមែងនាំសេចក្តីសុខមកឲ្យ គ្រាទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ស្តេចនឹងទៅកាន់សួគ៌ ។

ធម្មញ្ចរ មហារាជ ឥន្ទ្រ ទេវ សព្រហ្មកា
សុចិណ្ណេន ទិវំ បត្តា មា ធម្មំ រាជ បមាទោតិ ។

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ចុះ ព្រោះថា ព្រះឥន្ទ្រ ទេវតា ព្រមទាំងព្រហ្ម ជាអ្នកដល់នូវទិព្វស្ថាន ព្រោះធម៌ដែលប្រព្រឹត្តល្អហើយ បពិត្រព្រះរាជា សូមព្រះអង្គទ្រង់កុំប្រមាទក្នុងធម៌ឡើយ ។

*បណ្តាបទទាំងនោះ បទថា **សព្វាបិ** "**សូម្បីទាំងអស់**"[1] សេចក្តីថា បពិត្រព្រះអង្គជាធំនៃប្រជា ខ្ញុំព្រះអង្គតែម្នាក់ប៉ុណ្ណោះ នឹងបិទបាំងរឿងនេះ នាំនាងឧម្មាទន្តីនោះមកថ្វាយ ព្រោះដូច្នោះ*

---

១. សេចក្តីនៃព្រះអដ្ឋកថា កែត្រឹមលេខឃ្នាបទី ២៦ ។

រៀរចាកព្រះអង្គ និងខ្ញុំព្រះអង្គចេញហើយ ប្រជាជនសូម្បីដទៃទាំងអស់មិនគប្បីដឹង គឺ មិនដឹងសូម្បីកិរិយាអាការនៃរឿងដែលធ្វើមកហើយនេះឡើយ ។ បទថា **ករ្ជសេហិ** "**ទ្រង់ចូរអភិរម្យជាមួយនាង**" សេចក្តីថា ខ្ញុំព្រះអង្គថ្វាយនាងឧម្មាទន្តីចំពោះព្រះអង្គហើយ សូមព្រះអង្គទ្រង់រួមអភិរម្យជាមួយនាង ធ្វើព្រៃ គឺ សេចក្តីប្រាថ្នារបស់ខ្លួនឲ្យក្រៃលែង គឺ ធ្វើឲ្យចម្រើន បានដល់ ចូរធ្វើសេចក្តីប្រាថ្នានៃចិត្តឲ្យពេញចុះ ។ បទថា **សជាហិ** "**ទ្រង់ចូរលះបង់ចេញ**" នយ ថា ក៏គ្រាព្រះអង្គធ្វើសេចក្តីប្រាថ្នានៃចិត្តពេញហើយ បើនាងមិនជាទីពេញព្រះទ័យរបស់ព្រះអង្គសោត គ្រានោះព្រះអង្គទ្រង់ចូរលះបង់នាងចុះ ចូរប្រគល់ឲ្យខ្ញុំព្រះអង្គដូចដើមចុះ ។ បទថា **កម្មករំ** "**ធ្វើកម្ម**" សេចក្តីថា អភិជ្ឌាកសេនាបតីដែលជាសម្ងាញ់ មនុស្សណាធ្វើកម្មដែលជាបាប ខាងក្រោយមកមនុស្សនោះសម្គាល់ គឺ គិតថា "ជនដទៃក្នុងលោកនេះកុំសម្គាល់ គឺ ចូរកុំដឹងកម្មដែលជាបាបនេះ

(របស់យើង) ទ្បើយ" ។ ការគិតរបស់បុគ្គលនោះ ជាការគិតដែលអាក្រក់ ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះនរជនទាំងនោះរមែងឃើញគេដែលធ្លាប់នោះហើយ ។ បទថា **បស្សន្តិ ភូតានិ ក-ភេន្តមេតំ "នរជនទាំងនោះរមែងឃើញគេដែលធ្លាប់ហើយនោះ"** គឺ ក៏ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធបុត្តទាំងឡាយអ្នកប្រកបហើយដោយឫទ្ធិ រមែងឃើញគេអ្នកធ្លាប់ហើយនោះឯង ។ បទថា **ន មេ ឥមា "នាងឧម្មាទន្តីមិនជាទីស្រឡាញ់នៃយើង"** សេចក្តីថា ម្នាលអកិបារកសេនាបតីសម្ងាញ់ ជនដទៃណាហ្ន៎ក្នុងលោកនេះ គឺ ក្នុងផែនដីទាំងអស់ ទ្ធឹងគប្ប៉ាជ្ជៀលោកយ៉ាងនេះថា នាងឧម្មាទន្តីមិនជាទីស្រឡាញ់របស់ខ្លួន ។

បទថា **សីហេវ សេលស្ស គុហំ "ដូចរាជសីហ៍ចូលកាន់គុហាសិលាដូច្នោះ"** សេចក្តីថា បពិត្រមហារាជ បើព្រះអង្គមិននាំនាងមកក្នុងទីនេះសោត សូមព្រះអង្គស្តេចចូលទៅកាន់ទីនៅរបស់

នាងនោះ ចូរធ្វើសេចក្តីប្រាថ្នារបស់ព្រះអង្គឲ្យសម្រេចបរិបូណ៌ក្នុងទីនោះចុះ ដូចជារាជសីហ៍ កាលកើតសេចក្តីរោលរាលនៃកិលេសក៏ទ្រឹងចូលទៅកាន់គុហាកែវដែលជាទីនៅរបស់រាជសីហ៍ញ៉ីដូច្នោះ ។ បទថា **សុខ្ចលំ "ដែលមានផលជាសុខ"** សេចក្តីថា ម្នាលអភិ-ជារកសេនាបតីសម្ងាញ់ ពួកបណ្ឌិតត្រូវសេចក្តីទុក្ខប៉ះខ្ទប់ខ្ជួនហើយ រមែងមិនលះបង់កម្មដែលឲ្យផលជាសុខ ឬថា ទ្រឹងជាបុគ្គលវង្វេងហើយ គឺ វង្វេងដោយមោហៈ ស្រវឹងដោយសេចក្តីសុខ រមែងមិនប្រព្រឹត្តកម្មដែលជាបាបឡើយ ។ បទថា **យថាសុខំ សីវិ ករោហិ កាមំ "បពិត្រព្រះអង្គជាធំលើដែនសីវិ សូមព្រះអង្គទ្រង់ចូរបរិភោគកាមតាមសប្បាយ"** ន័យថា បពិត្រព្រះបាទសីវិរាជទ្រង់ជាធំ ដែលឈ្មោះថា សេចក្តីតិះដៀលរមែងមិនមានដល់នាយចៅហ្វាយអ្នកប្រើទាសីរបស់ខ្ជួនទេ សូមព្រះអង្គចូរបរិភោគកាមតាមសប្បាយ តាមអធ្យាស្រ័យ គឺ ចូរធ្វើសេចក្តីប្រាថ្នារបស់ព្រះអង្គឲ្យបរិបូណ៌ចុះ ។

បទថា **ន តេន សោ ជីវតិ "បុគ្គលនោះរមែងរស់នៅអាយុវែងព្រោះកម្មនោះ"** សេចក្ដីថា ម្នាលអភិជ្ឌាកៈសម្ងាញ់ បុគ្គលណាធ្វើបាប ដោយសម្គាល់ថា "យើងជាអ្នកធំ" លុះធ្វើហើយមិនកន្ត មិនខ្វាចថា "ទេវតា និងមនុស្សទាំងឡាយនឹងពោលដល់កម្មនោះ ព្រោះកម្មនោះ បុគ្គលនោះមិនរស់នៅអស់កាលយូរឡើយ រមែងស្លាប់ដោយឆាប់នោះឯង មួយទៀត សូម្បីទេវតាទាំងឡាយក៏រមែងនាំគ្នាសម្ងឹងមើលដោយខ្សែភ្នែកមើលងាយថា "ការគ្រងរាជ្យសម្បត្ដិរបស់ព្រះរាជាដ៏លាមកនេះ នឹងមានប្រយោជន៍អ្វី ការដែលបុគ្គលនោះយកនូវធ្នាំងខ្សាច់ចងកសម្ងាប់ខ្លួនវិញប្រសើរជាង" ។ បទថា **អញ្ញាតកំ "ដែលជារបស់អ្នកដទៃ"** សេចក្ដីថា បពិត្រព្រះអង្គជាធំ ទានដែលជារបស់ជនដទៃ ដែលម្ចាស់របស់នោះប្រគល់ឲ្យហើយ ជនពួកណាតាំងនៅក្នុងធម៌របស់ខ្លួនហើយ ក៏រមែងទទួលទាននោះ ជនពួកនោះទាំងអស់ឈ្មោះថា ទាំងជាអ្នកទទួលទាំងជាអ្នកឲ្យទាន

នោះ រមែងនាំគ្នាធ្វើតែកម្មដែលមានផលជាសុខតែម្យ៉ាង ក៏កាលបដិគ្គាហកៈទទួលទានហើយ ទាននោះនឹងរមែងឲ្យផលដ៏ច្រើនដល់ទាយក ។ គាថាថា **អញ្ញោ នុ ។បេ។ អត្ថា ចិយា ។បេ។ យោ អត្ត**ទុក្ខេន "**បុគ្គលដទៃ ។ល។ ជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គដោយពិត ។ល។ ជនណាបង្ក**ទុក្ខ**ឲ្យដល់អ្នកដទៃ ដោយទុក្ខរបស់ខ្លួន**" ខ្លឹមសារនៃគាថានោះមានដូច្នេះ ម្នាលអភិបាកសេនាបតីសម្លាញ់ បុគ្គលណាខ្លួនឯងត្រូវសេចក្ដីទុក្ខបៀតបៀនហើយ រមែងញ៉ាំងនូវសេចក្ដីទុក្ខនោះឲ្យដល់អ្នកដទៃ គឺ នាំសេចក្ដីទុក្ខចេញទៅពីសរីរៈរបស់ខ្លួនហើយ ទៅជាក់ក្នុងសរីរៈរបស់អ្នកដទៃ ឬកាន់យកសេចក្ដីសុខរបស់ខ្លួនដោយសេចក្ដីសុខរបស់អ្នកដទៃ គឺ កាន់យកសេចក្ដីសុខរបស់អ្នកដទៃនោះមកជាក់ក្នុងខ្លួន ឈ្មោះថា រមែងធ្វើអ្នកដទៃឲ្យដល់នូវសេចក្ដីទុក្ខដោយសម្គាល់ថា "យើងនឹងនាំនូវសេចក្ដីទុក្ខរបស់ខ្លួនចេញ" ឈ្មោះថា រមែងធ្វើអ្នកដទៃឲ្យដល់នូវសេចក្ដីទុក្ខ

ដោយសម្គាល់ថា "យើងនឹងធ្វើខ្លួនឯងឲ្យមានសេចក្តីសុខសប្បាយ" ឈ្មោះថា រមែងធ្វើនូវសេចក្តីសុខរបស់បុគ្គលដទៃឲ្យវិនាសដោយ សម្គាល់ថា "យើងនឹងធ្វើខ្លួនឯងឲ្យមានសេចក្តីសុខ" បុគ្គលនោះ រមែងមិនដឹងធម៌ ។ ចំណែកបុគ្គលណាដឹងយ៉ាងនេះថា "សេចក្តី សុខ និងសេចក្តីទុក្ខរបស់យើងនោះយ៉ាងណា របស់បុគ្គលដទៃក៏ យ៉ាងនោះដូចគ្នា" បុគ្គលនោះឈ្មោះថា ដឹងធម៌ គឺ ស្គាល់ធម៌ ។

បទថា **ឋិយេន តេ ទម្មិ "ខ្ញុំព្រះអង្គសូមថ្វាយ... ចំពោះព្រះ អង្គដោយវត្ថុដែលជាទីស្រឡាញ់"** សេចក្តីថា ខ្ញុំព្រះអង្គប្រាថ្នាផល ដែលជាទីស្រឡាញ់ ដោយវត្ថុជាហេតុនៃសេចក្តីស្រឡាញ់ ទើប បានថ្វាយចំពោះព្រះអង្គ ។ បទថា **ឋិយំ លភន្តិ "រមែងបានវត្ថុ ដែលជាទីស្រឡាញ់"** សេចក្តីថា កាលគ្រាចប់ទៅក្នុងសង្ឆារវដ្ត ក៏ រមែងបាននូវវត្ថុដែលជាទីស្រឡាញ់ដូចគ្នា ។ បទថា **កាមហេតុកំ "មានកាមជាហេតុ"** សេចក្តីថា ម្នាលអភិជ្ឌាកសេនាបតីសម្ងាញ់

យើងកើតបរិវិតក្ក:ឡើងថា "យើងធ្វើនូវវត្ថុដែលមិនសមគួរដែលមានកាមជាហេតុហើយ នឹងសម្ងាប់ខ្លួនវិញ" ។ បទថា **មយ្ហ សតិ** "**នាងឧម្មាទន្តីដែលជារបស់ខ្ញុំព្រះអង្គ**" បានដល់ ដែលជារបស់មានហើយរបស់ខ្ញុំព្រះអង្គ ។ ចាប:ថា **មយ្ហ សតិ** ដូច្នេះក៏មាន ។ អធិប្បាយថា ប្រសិនបើព្រះអង្គសម្គាល់យ៉ាងនេះថា "នាងឧម្មា-ទន្តីនោះជារបស់ខ្ញុំព្រះអង្គ" ទើបទ្រង់មិនប្រាថ្នានាងសោត ។ បទថា **សព្វជនស្ស** "**ជនទាំងពួង**" សេចក្តីថា ខ្ញុំព្រះអង្គនឹងឲ្យសេនាទាំងអស់ប្រជុំគ្នា ហើយលះបង់ដល់ជនទាំងអស់នោះថា "ស្ត្រីម្នាក់នេះមិនជាប្រយោជន៍ដល់យើងឡើយ" ។ បទថា **តតោ អ្ហាយេសិ**[1] "**គប្បីនាំ... មកអំពីទីនោះចុះ**" សេចក្តីថា ព្រះអង្គគប្បីនាំនាងមកអំពីទីនោះចុះ ព្រោះនាងមិនមាននរណាគ្រប់គ្រងហើយ ។ បទថា **អទូសិយំ** "**អ្នកវាកទោសមិនបាន**" បានដល់ អ្នកមិនមានកំហុស ។

បិដក. ១. តតោ អ្ហាយេសិនំ ។

ព្រះរាជាត្រាស់ហៅអភិបារកសេនាបតី ដោយឈ្មោះម្យ៉ាងទៀតថា **"កត្តៃ** (អ្នកធ្វើនូវប្រយោជន៍) ។ ក៏អភិបារកសេនាបតីនោះរមែងធ្វើនូវប្រយោជន៍ដ៏ធំចំពោះព្រះរាជា ព្រោះដូច្នោះ ទើបគេហៅថា "កត្តៃ" ។ បទថា **ន ចាបិ ត្យស្ស "មួយទៀត សូម្បីអ្នកចូលខាងលោក... ក៏នឹងមិនមាន"** សេចក្តីថា សូម្បីក្នុងក្រុងក៏មិនមាននរណាចូលជាបក្សពួកលោក ព្រោះគិតថា "សេនាបតីជាអ្នកធ្វើវត្ថុដែលមិនគួរធ្វើយ៉ាងនេះ" ។ បទថា **និន្ទុं "ពាក្យនិន្ទា"** សេចក្តីថា អភិបារកសេនាបតីក្រាបទូលថា "ពាក្យស្តីបន្ទោសតែម្យ៉ាងប៉ុណ្ណោះក៏មិនមាន សូម្បីនរណានឹងនិន្ទា ឬសរសើរខ្ញុំព្រះអង្គចំពោះមុខក្តី ឬនឹងលើកទោសឡើងតិះដៀលក្តី ខ្ញុំព្រះអង្គក៏នឹងអត់ទ្រាំនូវពាក្យនិន្ទា ពាក្យសរសើរ និងពាក្យតិះដៀលនោះទាំងអស់ ពាក្យនិន្ទាជាដើមទាំងអស់នោះចូរធ្លាក់មកលើខ្ញុំព្រះអង្គចុះ ។

បទថា **តម្ហា "អំពីអ្នកនោះ"** សេចក្តីថា បុគ្គលណាមិនកាន់

យកពាក្យនិន្ទាជាដើមទាំងនេះ សិរី គឺ ឥស្សរិយយស និងលក្ខី គឺ បញ្ញា រមែងទៅប្រាសបុគ្គលនោះ គឺ រមែងតាំងនៅមិនបាន ដូចទឹក គឺ ទឹកភ្លៀងហូរចុះអំពីទីទួលដូច្នោះ ។ បទថា **ឯតោ**[1] **"ព្រោះហេតុនៃការលះបង់នេះ"** បានដល់ ចាកហេតុដែលខ្ញុំព្រះអង្គបានលះបង់នាងហើយនេះ ។ បទថា **ធម្មាតិសារញ្ច "វត្ថុដែលកន្ទងធម្មតា"** បានដល់ វត្ថុណាមួយដែលជាអកុសលធម៌ ប្រព្រឹត្តទៅកន្ទងផុតធម៌មាន ។ បទថា **បដិច្ឆិ សរ្ជាមិ "នឹងរមែងទទួល"** បានដល់ នឹងទទួលយកចំពោះ ។ ដោយបទថា **ថាវរានំ តសានំ "ទាំងរបស់បុគ្គលនឹងធឹង និងបុគ្គលកន្ត្រាក"** អភិបារកសេនាបតី "មហាប្រើ"ថាពីនឹងមិនព្រមទទួលវត្ថុតិចតួចរបស់ព្រះវ៉ីណាស្រពទាំងឡាយ និងរបស់បុថុជ្ជនទាំងឡាយក៏ទេ គឺ រមែងទទួលអត់ធន់ក្នុងវត្ថុទាំងអស់បាន យ៉ាងណា សូម្បីខ្ញុំព្រះអង្គក៏យ៉ាងនោះ នឹងព្រម

---

[1] ១. ឯត្ថ ។

ទទួល នឹងអត់ធន់ក្នុងវត្ថុទាំងអស់នោះឲ្យបាន ។ បទថា **ឯកោបិមំ** **"យើងសូម្បីតែម្នាក់ប៉ុណ្ណោះ"** សេចក្តីថា សូម្បីយើងតែម្នាក់ប៉ុណ្ណោះ នឹងធ្វើឲ្យផុត នឹងឆ្លង គឺ នឹងនាំទៅនូវការ: គឺ សេចក្តីទុក្ខរបស់ខ្លួននេះ ។ បទថា **ធម្មេ ឋិតោ** **"ជាអ្នកតាំងនៅក្នុងធម៌"** សេចក្តីថា ជាអ្នកតាំងនៅក្នុងធម៌ជាគ្រឿងវិនិច្ឆ័យ ក្នុងធម៌ដែលទាក់ទងនឹងប្រពៃណី និងក្នុងសុចរិតធម៌ ៣ ប្រការ ។ ដោយបទថា **សគ្គូបគំ** **"រមែងឲ្យចូលដល់សួគ៌"** សេចក្តីថា បពិត្រព្រះសម្មតិទេព ធម្មតាថា បុញ្ញកម្មរមែងជាហេតុឲ្យចូលដល់សួគ៌ ។ បទថា **យញ្ញំ ធនំ**[1] **"ទ្រព្យសម្រាប់បូជាយញ្ញ"** បានដល់ ទ្រព្យក្នុងការបូជាយញ្ញ ម្យ៉ាងទៀត ចាប:ក៏យ៉ាងនោះដូចគ្នា ។ បទថា **សខា** **"ជាសម្ងាញ់"** គឺ សូម្បីនាងខម្មាទន្តីក៏ជាសម្ងាញ់របស់យើង ។ បទថា **ឋិតកេ** "ព្រហ្ម" បានដល់ ព្រះព្រហ្ម ។ បទថា **សព្ពេ** **"ទាំងអស់"** សេចក្តីថា មិនមែនតែទេវតា និងព្រះព្រហ្មប៉ុណ្ណោះ សូម្បីប្រជាជនអ្នកក្រុងទាំង

ឋិដក. ១. យញ្ញ ធនំ ។

អស់ ក៏នឹងគប្បីនាំគ្នានិទ្ទាយើងបានថា "អ្នកស្រុកយើងអើយ ពួកអ្នកចូរមើលចុះ ស្រីដែលជាសម្ងាញ់ជាកវិយារបស់សេនាបតី ជាសម្ងាញ់គ្នា ព្រះរាជាអង្គនេះគង់នឹងធ្វើទុកក្នុងផ្ទះបានហ្ន៎" ។ បទថា **នហេតំ ធម្មំ "មិនគប្បី... កម្មដែលជាធម្មិនោះ"** បានដល់ មិនគប្បីជំទាស់កម្មដែលប្រកបដោយធម្មិនេះឡើយ ។ បទថា **យំ តេ មយា "ខ្ញុំព្រះអង្គ... ចំពោះព្រះអង្គ"** សេចក្ដីថា ព្រោះខ្ញុំព្រះអង្គ ថ្វាយនាងឧម្មាទន្តីចំពោះព្រះអង្គ ដូច្នោះ វត្ថុនេះទើបមិនប្រាកដថា ជាអធម្មិឡើយ ។ បទថា **សតំ**[1] **"របស់សប្បុរស"** សេចក្ដីថា ធម្មិទាំងឡាយ គឺ សេចក្ដីអត់ធន់ មេត្ត្ការ៉ុណា សីល និងមារ-យាទរបស់សប្បុរសទាំងឡាយមានព្រះពុទ្ធជាដើម ពណ៌នាទុកល្អហើយ ។ ដោយបទថា **សមុទ្ទវេលាវ ទុរច្ចយានិ "លំបាកដែលនឹងកន្ទងបាន ដូចខ្សែនៃសមុទ្ទដូច្នោះ"** ព្រះរាជាត្រាស់ថា "ព្រោះ

ឋិដក. ១. សតញ្ច ។

ជូច្នោះ សូម្បីយើងក៏ទ្រឹងមិនឈានកន្ទ្ងរ១ត្តនៃសីល ដូចជាមហា-
សមុទ្ទមិនកន្ទ្ងរត្រើយដែលជាខ១ត្តជូច្នោះ" ។ បទថា **អាហុនេយ្យ
មេសិ "ជាអ្នកគួរគោរពរបស់ខ្ញុំព្រះអង្គ"** សេចក្ដីថា បពិត្រមហា-
រាជ ព្រះអង្គទ្រង់សមគួរដល់ខ្ញុំព្រះអង្គក្រាកទទួល និងជាទីសក្ការ:
របស់ខ្ញុំព្រះអង្គ ។ បទថា **ធាតា វិធាតា ចសិ កាមបាលោ "ជា
អ្នកទ្រទ្រង់ទុក ជាទ្រទ្រង់ទុកយ៉ាងពិសេស និងជាអ្នកទ្រង់រក្សានូវ
សេចក្ដីប្រាថ្នាទុក"** សេចក្ដីថា បពិត្រព្រះសម្មតិទេព ព្រះអង្គឈ្មោះ
ថា ជាអ្នកទ្រទ្រង់ទុក ព្រោះទ្រទ្រង់ទុកនូវខ្ញុំព្រះអង្គ ឈ្មោះថា ជា
អ្នកទ្រទ្រង់ទុកយ៉ាងពិសេស ព្រោះទ្រង់នាំឲ្យកើតសេចក្ដីសុខក្នុង
ឥស្សរិយយស និងឈ្មោះថា ជាអ្នករក្សាសេចក្ដីប្រាថ្នាទុក ព្រោះ
ទ្រង់រក្សាសេចក្ដីត្រូវការដែលខ្ញុំព្រះអង្គបានដោយលំបាក និងប្រាថ្នា
ហើយ ។ បទថា **តយី ហុតា "យញ្ញដែលបូជាក្នុងព្រះអង្គ"** បាន
ដល់ នាងដែលខ្ញុំព្រះអង្គថ្វាយចំពោះព្រះអង្គ ។ បទថា **កាមេន**

មេ "តាមសេចក្ដីប្រាថ្នារបស់ខ្ញុំព្រះអង្គ" សេចក្ដីថា សូមព្រះអង្គ ទ្រង់ទទួលនាងឧម្មាទន្តីតាមសេចក្ដីត្រូវការរបស់ខ្ញុំព្រះអង្គ គឺ តាមសេចក្ដីប្រាថ្នារបស់ខ្ញុំព្រះអង្គចុះ ។ អភិបារកសេនាបតីថ្វាយនាងឧម្មាទន្តីចំពោះព្រះរាជា ដោយពាក្យពោលយ៉ាងនេះ ។ ព្រះរាជាទ្រង់បដិសេធថា "យើងមិនត្រូវការនាង" ។ ព្រះរាជា និងសេនា-បតី ទាំងពីរនាក់ រមែងលះបង់នាងឧម្មាទន្តី ដូចបុគ្គលយកខ្នងជើងគៀសសំបុកសត្វដែលធ្លាក់លើផែនដី ឲ្យធ្លាក់ទៅក្នុងព្រៃដូច្នោះ ។

ឥឡូវនេះ ព្រះរាជាកាលនឹងគំរាមសេនាបតីនោះ ដើម្បីមិនឲ្យគេពោលតទៅទៀត ទើបផ្ដើមត្រាស់គាថាថា **អទ្ធា ហិ "ដោយពិត"** ។ បណ្ដាបទទាំងនោះ បទថា **កត្តុបុត្ត "លោកជាបុត្តរបស់អ្នកដែលធ្វើនូវប្រយោជន៍"** សេចក្ដីថា សូម្បីបិតារបស់អភិបារក-សេនាបតីនោះក៏ជាអ្នកធ្វើនូវប្រយោជន៍ដែរ ព្រោះហេតុនោះ ព្រះរាជាទើបត្រាស់ហៅគេដូច្នោះ ។ មានពាក្យដែលលោកពោលអធិ-

ឬ្យាយទុកថា ព្រះរាជាត្រាស់គំរាមអភិបារកសេនាបតីនោះថា "ពិតហើយ កាលអំពីមុន អ្នកបានប្រព្រឹត្តធម៌ទាំងអស់ដល់យើង តែពេលនេះ អ្នកត្រឡប់ក្លាយជាបដិបក្ខ ពោលពាក្យដ៏ច្រើន អ្នកកុំពោលទៀតឡើយ បុគ្គលដទៃដែលមានជើងពីរ នរណាហ្ន៎ នឹងជាអ្នកធ្វើសេចក្តីសួស្តីឲ្យដល់អ្នក ក្នុងវេលាអុណារះឡើងក្នុងជីវលោកនេះ ក៏ប្រសិនបើមានព្រះរាជាអង្គដទៃមានចិត្តជាប់ជំពាក់ស្រឡាញ់ប្រាជ្ញាក្នុងកិរិយារបស់អ្នកដូចជាយើងសោត ក៏គប្បីប្រើឲ្យមនុស្សកាត់សីសៈរបស់អ្នកចេញក្នុងវេលាអុណារះនោះឯង ហើយឲ្យចាប់នាងមកទុកក្នុងព្រះរាជវាំងរបស់ព្រះអង្គនោះ តែយើងមិនព្រមធ្វើដូច្នោះ ព្រោះខ្លាចដល់អកុសលកម្ម អ្នកចូរនៅស្ងៀមចុះ យើងមិនមានសេចក្តីត្រូវការក្នុងនាងឡើយ" ។ អភិបារកសេនាបតីបានស្តាប់ព្រះតម្រាស់នោះហើយ កាលមិនអាចក្រាបទូលពាក្យអ្វីៗ ទៀតបាន ទើបផ្តើមពោលគាថាថា **ត្វं នុ "ព្រះអង្គ"** ដោយបំណងនឹងពោល

សរសើរព្រះរាជា ។ សេចក្ដីនៃគាថានោះថា បពិត្រមហារាជ ព្រះអង្គប៉ុណ្ណោះជាព្រះរាជាដ៏ប្រសើរបំផុតជាងព្រះរាជា ទ្រង់ជាកំពូលនៃព្រះរាជាទាំងអស់ក្នុងជម្ពូទ្វីបទាំងមូល ព្រះអង្គជាព្រះរាជាដែលធម៌គ្រប់គ្រងហើយ ព្រោះទ្រង់រក្សាធម៌ជាគ្រឿងវិនិច្ឆ័យ ធម៌ដែលទាក់ទងនឹងប្រពៃណី និងសុចរិតធម៌ ព្រះអង្គជាព្រះរាជាដ៏ងប្ជាស់នូវធម៌ ព្រោះដ៏ងប្ជាស់ទូទៅនូវធម៌ទាំងនោះ ព្រះអង្គទ្រង់មានព្រះបញ្ញាវាងវៃ ព្រះអង្គជាអ្នកដែលធម៌រក្សាយុំគ្រងទុកហើយ សូមព្រះអង្គចូរតាំងព្រះជន្មាយុយឺនយូរចុះ បពិត្រព្រះរាជាដ៏ប្រសើរ អ្នករក្សាធម៌យុំគ្រងធម៌ សូមព្រះអង្គទ្រង់សម្ដែងធម៌ដល់ខ្ញុំព្រះអង្គផងចុះ ។

លំដាប់នោះ ព្រះរាជាកាលនឹងទ្រង់សម្ដែងធម៌ ទើបត្រាស់គាថាផ្ដើមថា **តទិច្ឆ** “**បើដូច្នោះ**” ។ សព្ទថា **ឥច្ឆ** ក្នុងគាថានោះជានិបាត ប្រើក្នុងអត្ថថា ដាស់តឿន ។ អធិប្បាយថា ព្រោះអ្នក

ជាស់តឿនយើង ដូច្នោះ (អ្នកចូរស្តាប់ពាក្យរបស់យើង) ។ បទ
ថា **សតំ** "**ដែលសប្បុរស**" បានដល់ ដែលសប្បុរសទាំងឡាយ
មានព្រះពុទ្ធជាដើមសេតហើយ ។ បទថា **សាធុ** "**ទើបល្អ**" បាន
ដល់ ជាសេចក្តីល្អ គឺ ជាការប្រសើរបំផុត ។ ព្រះរាជាទ្រង់ឈ្មោះ
ថា ជាអ្នកពេញចិត្តក្នុងធម៌ ព្រោះអត្ថថា ទ្រង់ពេញព្រះទ័យក្នុងការ
វិនិច្ឆ័យធម៌ ប្រពៃណីធម៌ និងសុចរិតធម៌ ។ ពិតហើយ ព្រះរាជា
ដូច្នោះ សូម្បីត្រូវលះបង់ព្រះជន្មជីពក៏ទ្រង់មិនព្រមធ្វើកម្មដែលមិន
គួរធ្វើ ព្រោះដូច្នោះ ទើបជាព្រះរាជាដែលមានសេចក្តីល្អ ។ បទថា
បញ្ញាណវា "**អ្នកមានការដឹងដោយជុំវិញ**" បានដល់ ដល់ព្រមដោយ
ញាណ ។ បទថា **មិត្តានំ អទុព្ភោ**[1] "**ការមិនប្រទូស្តចំពោះមិត្ត**"
គឺ ភាពជាអ្នកមិនប្រទូស្តចំពោះមិត្ត ។ បទថា **ឋិតធម្មោ** "**អ្នក
តាំងនៅក្នុងធម៌**" គឺ មានធម៌ទាំង ៣ យ៉ាងតាំងទុកល្អហើយ ។

ឋិដក. ១. មិត្តានមទុព្ភ ។

បទថា **អាសេថ "គប្ប៎ានៅ"** គឺ គប្ប៎ដេកគប្ប៎អង្គុយ ។ ពិតហើយ បទថា **គប្ប៎ានៅ** នេះ ជាមាតិកានៃទេសនាប៉ុ"ណ្ណោះ ។ ក៏ក្នុងបទនេះ មានពាក្យអធិប្បាយថា គប្ប៎សម្រេចសេចក្តីសុខក្នុងឥរិយាបថទាំង ៤ ។ បទថា **សិតច្ឆាយាយ "ដែលមានម្លប់ត្រជាក់"** គឺ ស្រមោលដែលជាម្លប់ដ៏ត្រជាក់របស់បុត្តកវិយា ញាតិ និងមិត្តទាំងឡាយ ។ បទថា **សំយេ "ក្នុងផ្ទះរបស់ខ្លួន"** គឺ ក្នុងផ្ទះដែលជារបស់ខ្លួន ។ អធិប្បាយថា ក្នុងផ្ទះរបស់ខ្លួនឯង ។ ព្រះរាជាទ្រង់សម្តែងថា ពួកមនុស្សដែលមិនត្រូវបៀតបៀនដោយពលីកម្ម និងអាជ្ញាដែលមិនមែនជាធម៌ជាដើម គប្ប៎នៅជាសុខ ។ បទថា **ន ចាហមេតំ "យើងរមែងមិន... នោះទេ"** សេចក្តីថា អកិបារកៈ សម្ងាញ់ កម្មណាដែលមិនបានពិចារណាមុនធ្វើ ជាកម្មធ្វើមិនល្អ យើងមិនពេញចិត្តកម្មនោះទេ ។ បទថា **ញត្តូ[1] "ទ្រង់ជ្រាប**

ចិដក. ១. ញត្តូ ន ។

ហើយ" មានអធិប្បាយថា ក៏យើងពេញចិត្តកម្មរបស់ព្រះរាជាដែលទ្រង់ដឹងហើយ គឺ ពិចារណាហើយទ្រង់ធ្វើដោយព្រះអង្គឯង ។ ក៏ក្នុងបទថា **ឧបមា ឥមា** "**ឧបមារបស់យើងតទៅនេះ**" នេះ មានសេចក្តីថា សូមអ្នកចូរតាំងចិត្តស្តាប់នូវពាក្យឧបមា ២ ប្រការនេះរបស់យើងចុះ ។ បទថា **ជិម្ហំ** "**រៀច**" បានដល់ រៀច ។ បទថា **នេត្ត** "**ក្នុងកាលគោមេហ្វូង**" បានដល់ កាលគោឧសភ:ដ៏ប្រសើរនាំហ្វូងគោទៅ ។ បទថា **បគេវ** "**ចាំបាច់ពោលថ្វីដល់**" សេចក្តីថា កាលព្រះរាជាអង្គនោះទ្រង់ប្រព្រឹត្តអធម៌ហើយ ប្រជាជនក្រៅពីនេះក៏រមែងនាំគ្នាប្រព្រឹត្តអធម៌ដែរ គឺ ប្រព្រឹត្តកាន់តែក្រៃលែងឡើង ។ បទថា **ធម្មិកោ** "**ទ្រង់តាំងនៅក្នុងធម៌**" បានដល់ ព្រះរាជាទ្រង់លះនូវអគតិ ៤ ប្រការហើយ សោយរាជ្យសម្បត្តិដោយធម៌ ។ បទថា **អមរត្តំ** "**ដើម្បីភាពជាទេវតា**" បានដល់ ភាពជាទេព ។ បទថា **រតនំ** "**រតន:**" បានដល់ សវិញ្ញាណករតន: និង

អវិញ្ញាណកវតនៈ ។ បទថា **វត្ថិយំ** "**សំពត់**" គឺ សំពត់កាសិក-ព័ស្ត្រ ។ បទថា **អសរិត្តិយោ** "**សេះញ្ជី**" សំដៅដល់ សេះដែលមានសន្ទុះដូចខ្សល់ និងសំដៅដល់ស្រីដែលមានរូបដ៏ស្រស់ស្អាតក្រៃលែង ។ បទថា **រតនំ មណិកញ្ចូ** "**កែវមណី**" សំដៅដល់កែវ ៧ ប្រការ និងវត្ថុដែលមានតម្លៃច្រើន ។ បទថា **អភិបាលយន្តិ** "**រក្សាហើយ**" សេចក្តីថា រមែងធ្វើឲ្យរុងរឿងរក្សាហើយ ។ បទថា **ន តស្ស** "**នៃសម្បត្តិនោះ**" សេចក្តីថា បុគ្គលមិនគប្បីប្រព្រឹត្តខុសសូម្បីព្រោះហេតុនៃភាពជាស្តេចចក្រពត្តិនោះទេ ។ បទថា **ខ-សកោស្មិ** "**យើងជាអ្នកអង់អាច**" សេចក្តីថា ព្រោះយើងកើតជាព្រះរាជាដ៏ប្រសើរបំផុត ក្នុងកណ្តាលប្រជាជនអ្នកដែនសីវី ដូច្នោះយើងទើបមិនព្រមប្រព្រឹត្តខុស សូម្បីជាហេតុឲ្យបានជាស្តេចចក្រ-ពត្តិ ។ បទថា **នេតា** "**ជាអ្នកនាំ**" សេចក្តីថា យើងនឹងធ្វើឲ្យមហាជនតាំងនៅក្នុងកុសលកម្ម ហើយនាំទៅកាន់ទេវនគរ ជាអ្នក

ចម្រើនដល់មហាជននោះ ព្រោះការធ្វើនូវប្រយោជន៍ដ៏ចម្រើន ជាអ្នករុងរឿង ព្រោះមានប្រជាជនដ៏ធំទូទាំងជម្ពូទ្វីបថា "ជានញ្ញថា ព្រះបាទសីវិរាជទ្រង់ប្រព្រឹត្តធម៌" ជាអ្នកគ្រប់គ្រងដែន ព្រោះគ្រប់គ្រងដែនដោយធម៌ស្មើ ។ បទថា **អបចាយមានោ "និងជាអ្នកគោរពធម៌"** គឺ ឱនទៅក្នុងធម៌ដែលទាក់ទងដោយព្រះរាជប្រពៃណីរបស់ព្រះរាជាតាំងពីបុរាណកាលរបស់អ្នកដែនសីវិទាំងឡាយ ។ បទថា **សោ "យើងនោះ"** អធិប្បាយថា យើងជាអ្នកពិចារណាធម៌ហើយនោះឯង ព្រោះហេតុនោះ ទើបមិនប្រព្រឹត្តទៅក្នុងអំណាចចិត្តរបស់ខ្លួនឯង ។

អកិបារកសេនាបតី លុះបានស្តាប់ធម្មកថារបស់ព្រះមហាសត្វយ៉ាងនោះហើយ កាលនឹងធ្វើសេចក្តីសរសើរ ទើបពោលគាថាមានពាក្យផ្តើមថា **អទ្ធា "ពិតហើយ"** ។ បទថា **នប្ឋមជ្ជសិ "ទ្រង់មិនប្រមាទ"** សេចក្តីថា ទ្រង់មិនវង្វេងក្នុងធម៌ដែលព្រះអង្គត្រាស់ទុក

ហើយ គឺ ទ្រង់ប្រព្រឹត្តក្នុងធម៌នោះឯង ។ បទថា **ធម្មំ បមជ្ជ** "**ទ្រង់ប្រមាទក្នុងធម៌ហើយ**" បានដល់ ទ្រង់ភ្លេចធម៌ហើយ ប្រព្រឹត្ត ដោយអំណាចអគតិ ។ អភិបារកសេនាបតីនោះ គ្រាធ្វើសេចក្ដី សរសើរព្រះមហាសត្វយ៉ាងនេះហើយ ទើបពោលគាថាទូន្មាន ១០ គាថា មានបទថា **ធម្ម ចរ**[1] "**សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌**" ជូនេះ ជាដើមឲ្យក្រៃលែងឡើង ។ សេចក្ដីនៃគាថាទាំងនោះ បានពណ៌នា ទុកហើយក្នុងរឿងតេសកុណជាតកក្នុងខាងក្រោយនោះឯង ។

កាលអភិបារកសេនាបតីសម្ដែងធម៌ចំពោះព្រះរាជាយ៉ាងនេះ ហើយ ព្រះរាជាទ្រង់ក៏បានបន្ទោបង់ព្រះទ័យដែលជាប់ជំពាក់ប្រាជ្ញា ក្នុងនាងឧម្មាទន្តីចេញបាន ។

ព្រះសាស្ដាគ្រាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ក៏ ប្រកាសសច្ចៈទាំងឡាយ ហើយទ្រង់ប្រជុំជាតក ។ ក្នុងវេលាចប់

---

[1] ១. ធម្មញ្ជរ ។

សចេ: ភិក្ខុរូបនោះក៏តាំងនៅក្នុងសោតបត្តិផល ។ សុនន្ទសារបី

ក្នុងគ្រានោះ បានមកជាព្រះអានន្ទ, អភិបារកសេនាបតីក្នុងគ្រានោះ

បានមកជាព្រះសារីបុត្ត, នាងឧម្មាទន្តីក្នុងគ្រានោះ បានមកជាព្រះ

នាងឧប្បលវណ្ណាថេរី, បរិស័ទដ៏សេសក្នុងគ្រានោះ បានមកជាពុទ្ធ-

*បរិស័ទក្នុងគ្រានេះ ចំណែកព្រះបាទសីរិវាជក្នុងគ្រានោះ គឺ **តថាគត***

នេះឯង ។

ចប់អដ្ឋកថា ឧម្មាទន្តីជាតកទី ២

អដ្ឋកថា មហាពោធិជាតកនី ៣

(រឿងបដិបទារបស់អ្នកដឹកនាំ)

ព្រះសាស្តាកាលស្តេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់ជាន ប្រារព្ធព្រះបញ្ញាបារមី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កិន្នុ ទណ្ឌំ កិមាជិនំ "ព្រោះហេតុអ្វីហ្ន៎... ឈើច្រត់ សែ្បកខ្លា"** ។

ក្នុងរឿងនេះនឹងមានច្បាស់ក្នុងមហាឧម្មគ្គជាតកខាងមុខ ។

ក៏ក្នុងកាលនោះ ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ជាអ្នកមានបញ្ញា អាចញ្ចាំញ្ចីវាទ:របស់ជនដទៃបានដូចគ្នា" ទើបទ្រង់បាននាំយកអតីតនិទានមកសម្តែង ដូចតទៅនេះ ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជ្យសម្បត្តិក្នុងពារាណសី ព្រះពោធិសត្វបានបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍-មហាសាល ដែលមានទ្រព្យសម្បត្តិប្រមាណ ៨០ កោដិ ក្នុងដែន

កាសី ។ មាតាបិតាបានតាំងឈ្មោះព្រះពោធិសត្វថា **ពោធិកុមារ** *។ ពោធិកុមារនោះកាលចម្រើនវ័យហើយ បានសិក្សាសិល្បសាស្ត្រ ក្នុងក្រុងតក្កសិលារហូតចប់ ហើយត្រឡប់មកគ្រប់គ្រងផ្ទះ ។ ក្នុងកាលតមក បានលះបង់កាមហើយចូលកាន់ព្រៃហិមពាន្ត បួសជាបរិព្វាជក មានមើមឈើ និងផ្លែឈើក្នុងព្រៃនោះជាអាហារ រស់នៅអស់កាលយូរ លុះដល់រដូវក្ដៀង ទើបចេញចាកព្រៃហិមពាន្ត បានចារិកទៅដល់ក្រុងពារាណសីដោយលំដាប់ ចូលទៅក្នុងព្រះរាជ-ឧទ្យាន ក្នុងស្អែកឡើង បានត្រាច់កិក្ខាចារក្នុងព្រះនគរតាមសមគួរ ដល់បរិព្វាជក រហូតដល់ទ្វារព្រះរាជនិវេសន៍ ។ ព្រះរាជាប្រថាប់ឈរត្រង់សីហបញ្ជរ ទតព្រះនេត្រឃើញព្រះពោធិសត្វនោះ ទ្រង់ជ្រះថ្លាក្នុងកិរិយាស្ងប់ស្ងៀមរបស់លោក ទើបត្រាស់ឲ្យរាជបុរសទៅនិមន្តលោកចូលមកកាន់ទីប្រថាប់របស់ព្រះអង្គ ទ្រង់ធ្វើបដិស-ណ្ឋារៈ ទ្រង់បានស្តាប់ធម្មកថាតិចតួច ហើយទ្រង់ថ្វាយកោជនមាន*

រសជាតិដ៏ប្រណីតផ្សេងៗ ។ ព្រះមហាសត្វទទួលកត្តាហារហើយ
រលឹកថា "ដែលឈ្មោះថារាជត្រកូលនេះ មានទោសច្រើន ទាំងពួក
បច្ចាមិត្តក៏មានច្រើន នរណាហ្ន៎នឹងជួយកម្ចាត់ទុក្ខដែលនឹងកើតឡើង
ដល់យើងបាន" ។ ព្រះពោធិសត្វបានសម្លឹងឃើញសុនខពណ៌លឿង
មួយក្បាលដែលជាទីប្រោសប្រាណរបស់ព្រះរាជា នៅក្នុងទីជិតៗ
ទើបចាប់ចុងមួយដុំធំ សម្តែងទីនឹងឲ្យដល់សុនខនោះ ។ ព្រះរាជា
ទ្រង់ជ្រាបអាការនោះ ទើបមនុស្សនាំយកកាជនៈមកជាក់ភ្ជ ហើយ
ឲ្យដល់សុនខនោះ ។ ឯព្រះមហាសត្វគ្រាឲ្យដល់សុនខនោះហើយ
ក៏ធ្វើកត្តកិច្ចស្រេចដែរ ។ សូម្បីព្រះរាជាទ្រង់ទទួលប្ដេជ្ញារបស់ព្រះ
មហាសត្វនោះហើយ បានឲ្យជាងសាងបណ្ណសាលាទុកក្នុងព្រះរាជ
ឧទ្យានក្នុងព្រះនគរ ហើយទ្រង់ថ្វាយបរិក្ខារសម្រាប់បព្វជិត និមន្ត
ព្រះមហាសត្វនោះឲ្យនៅជាប្រចាំក្នុងទីនោះ ។ ក៏ព្រះរាជាស្ដេចបាន
ទៅកាន់ទីនោះ ទំនុកបម្រុងព្រះមហាសត្វមួយថ្ងៃ ២-៣ ដង រាល់ៗ

ថ្ងៃ ។ លុះដល់វេលាឆាន់ ព្រះមហាសត្វបានឡើងអង្គុយលើរាជ-
បល្ល័ঙ្ក ហើយឆាន់រាជភោជនជាប្រចាំនោះឯង ។ ដោយអាការយ៉ាង
នេះ វេលាក៏កន្ធងទៅអស់ ១២ ឆ្នាំ ។

ក៏ព្រះរាជាអង្គនោះមានអាមាត្យ ៥ នាក់ ធ្វើការទូន្មានអត្ត
និងធម្មិ ។ បណ្តាអាមាត្យទាំង ៥ នាក់នោះ ម្នាក់ជាអហេតុកវាទី
ម្នាក់ជាឥស្សរកវណាទី ម្នាក់ជាបុព្វេកតវាទី ម្នាក់ជាឧច្ឆេទវាទី
និងម្នាក់ទៀតជាខត្តវិជវាទី ។ ក្នុងបណ្តាអាមាត្យទាំង ៥ នាក់នោះ
អាមាត្យដែលជាអហេតុកវាទី ទូន្មានមហាជនឲ្យកាន់យកថា "សត្ត
ទាំងនេះជាអ្នកបរិសុទ្ធក្នុងសង្សារ" ។ អាមាត្យដែលជាឥស្សរកវ-
ណាទី ទូន្មានមហាជនឲ្យកាន់យកថា "លោកនេះព្រះជាម្ចាស់ជាអ្នក
សាង" ។ អាមាត្យដែលជាបុព្វេកតវាទី ទូន្មានមហាជនឲ្យកាន់យក
ថា "សេចក្តីសុខ ឬសេចក្តីទុក្ខរបស់សត្ត្ववទាំងនេះ កាលនឹងកើត
មក ក៏កើតឡើងដោយហេតុដែលខ្លួនធ្វើទុកក្នុងកាលមុននោះឯង" ។

អាមាត្យដែលជាខ្ចេទវាទី ទូន្មានដល់មហាជនឲ្យកាន់យកថា "ដែលឈ្មោះថា បុគ្គលដែលចាកលោកនេះទៅកាន់លោកខាងមុខ រមែងមិនមាន លោកនេះជាច់សូន្យ" ។ អាមាត្យដែលជាខត្តិជវាទីបានទូន្មានមហាជនឲ្យកាន់យកថា "បុគ្គលគួរសម្ងាប់សូម្បីមាតា បិតាហើយ បំណងធ្វើប្រយោជន៍របស់ខ្លួនឯងបាន" ។ អាមាត្យទាំង ៥ នាក់នោះ តាំងនៅក្នុងតំណែងជាអ្នកពិភាក្សាក្តីជំនួសព្រះរាជា តែត្រឡប់ជានាំគ្នាស៊ីសំណូកកាត់ក្តី ធ្វើជនដែលមិនមែនជាម្ចាស់របស់ឲ្យជាម្ចាស់របស់ និងធ្វើជនជាម្ចាស់របស់ឲ្យមិនជាម្ចាស់របស់ ។

ថ្ងៃមួយ បុរសម្នាក់ជាអ្នកចាញ់ក្តីព្រោះការកាត់ក្តីកោង ឃើញព្រះមហាសត្វគ្រាច់កិក្ខាចារចូលទៅកាន់ព្រះរាជនិវេសន៍ ទើបយំសំពះរៀបរាប់ថា "បពិត្រលោកជ័ចម្រើន លោកទៅធាន់ក្នុងព្រះរាជនិវេសន៍ ព្រោះហេតុអ្វីទើបបានសម្ងឹងមើលពួកអាមាត្យដែលវិនិច្ឆ័យក្តីទទួលសំណូក ធ្វើមនុស្សលោកឲ្យវិនាសហ្ន៎ ឥឡូវនេះ

ខ្ញុំជាម្ចាស់របស់ពិតៗ តែត្រូវពួកអាមាត្យទាំង ៥ នាក់ ស៊ីសំណូក អំពីកូនក្តីកោង ហើយធ្វើខ្ញុំមិនឲ្យជាម្ចាស់របស់វិញ" ។ ដោយការ អាណិតអាសូរក្នុងបុរសនោះ ព្រះមហាសត្វទើបទៅកាន់រោងវិនិ-ច្ឆ័យ កាត់ក្តីដោយធម៌ ក៏បានធ្វើមនុស្សជាម្ចាស់របស់ ឲ្យជាម្ចាស់ របស់ដូចដើម ។ មហាជនបានធ្វើសាធុការដោយសំឡេងដ៏ខ្លាំងៗ ព្រមគ្នានោះឯង ។ ព្រះរាជាទ្រង់បានស្តាប់សំឡេងនោះហើយ ទើប ត្រាស់សួរថា "នេះសំឡេងអ្វីហ្ន៎?" ។ លុះបានស្តាប់សេចក្តីនោះ ហើយ ទើបស្តេចចូលទៅអង្គុយជិតព្រះមហាសត្វដែលធ្វើកត្តកិច្ច ស្រេចហើយ ត្រាស់សួរថា "លោកដ៏ចម្រើន បានជ្រាបថា ថ្ងៃនេះ លោកម្ចាស់កាត់ក្តីខ្ជួនឯងឬ?" ព្រះមហាសត្វទូលថា "សូមថ្វាយ ព្រះពរមហាបពិត្រ" ។ ព្រះរាជាត្រាស់ថា "លោកដ៏ចម្រើន កាល លោកម្ចាស់ធ្វើការកាត់ក្តី សេចក្តីចម្រើនន៏ងមានដល់មហាជន ចាប់ តាំងអំពីនេះទៅ សូមលោកម្ចាស់ចូរជួយកាត់ក្តីឲ្យផងចុះ" ។ ព្រះ

មហាសត្វទូលថា "មហាបពិត្រ អាត្មាភាពជាបព្វជិត ការវិនិច្ឆ័យក្តីនេះ មិនមែនជាកិច្ចរបស់អាត្មាភាពឡើយ" ។ ព្រះរាជាត្រាស់ថា "លោកដ៏ចម្រើន លោកម្ចាស់គួរធ្វើសេចក្តីករុណាក្នុងមហាជនចុះ លោកម្ចាស់មិនបាច់វិនិច្ឆ័យរាល់ថ្ងៃក៏បាន គឺ ក្នុងវេលាព្រឹកចេញចាកឧទ្យានមកក្នុងទីនេះ ករុណាឆៀងចូលទៅកាន់សាលាក្តី ធ្វើការវិនិច្ឆ័យក្តីត្រឹមតែ ៤ រឿង លុមនឹងឆាន់ភត្តាហារស្រេចហើយ មុននឹងត្រឡប់ទៅកាន់ឧទ្យាន ករុណាជួយធ្វើការវិនិច្ឆ័យក្តីឲ្យ ៤ រឿងទៀត បើធ្វើបានយ៉ាងនេះ សេចក្តីចម្រើននឹងមានដល់មហាជន" ។ ព្រះមហាសត្វត្រូវព្រះរាជាអង្វរហើយ ទើបព្រមទទួលថា "យល់ព្រម" ។ តាំងអំពីថ្ងៃនោះមក ព្រះមហាសត្វក៏បានធ្វើយ៉ាងនោះ ។ ពួកកូនក្តីកោងទាំងឡាយមិនបានឱកាសឡើយ ។ រីឯពួកអាមាត្យទាំង ៥ នាក់នោះ កាលមិនបានសំណូកក៏ត្រឡប់ជាអ្នកទាល់ក្រ បានប្រឹក្សាគ្នាថា "តាំងពីវេលាដែលពោធិបរិព្វាជកមកកាត់ក្តី ពួក

យើងមិនបានអ្វីឡើយ ណ្ហើយចុះ ពួកយើងនឹងរករឿងបរិព្វាជក
នោះឲ្យបែកគ្នានឹងព្រះរាជាថា "គេជារាជសត្រូវ" ហើយឲ្យសម្លាប់
បរិព្វាជកឲ្យបាន" ។ ពួកអាមាត្យនោះនាំគ្នាទៅគាល់ព្រះរាជាហើយ
ក្រាបទូលថា "បពិត្រមហារាជ (ឥឡូវនេះ) ពោធិបរិព្វាជកប្រាថ្នា
នឹងធ្វើសេចក្តីវិនាសចំពោះព្រះអង្គ" កាលព្រះរាជាទ្រង់មិនជឿ បាន
ត្រាស់ថា "ពោធិបរិព្វាជកនោះជាអ្នកមានសីល សម្បូរដោយការ
ចេះដឹង នឹងមិនធ្វើកម្មបែបនោះជាច់ខាត" ទើបនាំគ្នាក្រាបទូលថា
"បពិត្រមហារាជ ប្រជាជនអ្នកក្រុងទាំងអស់ត្រូវពោធិបរិព្វាជកឲ្យ
នៅក្នុងកណ្តាប់ដៃរបស់ខ្លួនហើយ តែមិនអាចនឹងធ្វើពួកខ្ញុំព្រះអង្គ
ទាំង ៥ នាក់នេះបានប៉ុណ្ណោះ បើព្រះអង្គទ្រង់មិនជឿពាក្យរបស់
ពួកខ្ញុំព្រះអង្គសោត ក្នុងវេលាដែលពោធិបរិព្វាជកនោះមកកាន់ទី
នេះ ព្រះអង្គគប្បីទតព្រះនេត្រមើលបរិស័ទចុះ" ។ ព្រះរាជាទ្រង់
ទទួលថា "ល្អហើយ" ហើយប្រថាប់ឈរត្រង់សីហបញ្ជរ ទតព្រះ

នេត្រមើលបរិព្វាជកនោះកំពុងដើរមក ទ្រង់ក៏ឃើញបរិវារ ព្រោះ ព្រះអង្គមិនបានជ្រាប ទើបទ្រង់យល់ថា មនុស្សដែលមកនេះ ជា បរិវារបស់ព្រះមហាសត្ត្ব" ដូច្នេះហើយទើបទ្រង់ជឿ ហើយត្រាស់ ឲ្យពួកអាមាត្យនោះចូលមកគាល់ ត្រាស់សួរថា "ពួកយើងនឹងធ្វើ យ៉ាងណា?" ពួកអាមាត្យទាំងនោះក្រាបទូលថា "បពិត្រមហារាជ សូមព្រះអង្គត្រាស់បង្គាប់ឲ្យចាប់បរិព្វាជកនោះចុះ ព្រះអង្គ" ។ ព្រះ រាជាត្រាស់ថា "កាលយើងមិនទាន់ឃើញកំហុសដែលធំ នឹងត្រាស់ ឲ្យចាប់គេបានដូចម្តេច?" ពួកអាមាត្យក្រាបទូលថា "បើយ៉ាងនោះ សូមព្រះអង្គចូរត្រាស់ដកការឧបដ្ឋាកដែលធ្លាប់ធ្វើតាមប្រក្រតីដល់ បរិព្វាជកនោះចេញ បរិព្វាជកជាបណ្ឌិត លុះឃើញការទំនុកបម្រុង នោះថយចុះរឿយៗ គង់នឹងមិនជ្រាប់នរណាៗ ហើយក៏គេចចេញ ទៅឯង ។

ព្រះរាជាត្រាស់ថា "ល្អហើយ" ហើយត្រាស់ឲ្យដកការទំនុក

បម្រុងព្រះមហាសត្វចុះដោយលំដាប់ ។ ជាដំបូង ថ្ងៃដំបូងបុរសអ្នកចាត់ចែងឲ្យព្រះមហាសត្វអង្គុយលើបល្ល័ង្ក១ទេ ។ លុះលោកឃើញបល្ល័ង្ក១ទេប៉ុណ្ណោះក៏ដឹងថា ព្រះរាជាអស់សទ្ធាក្នុងយើងហើយ ទើបត្រឡប់ទៅកាន់ឧទ្យាន សូម្បីជាអ្នកមានសេចក្តីត្រូវការនឹងគេចចេញក្នុងថ្ងៃនោះ តែក៏ទប់ចិត្តមិនចេញទៅដោយគិតថា "យើងនឹងដឹងរឿងឲ្យច្បាស់ជាមុន ទើបចេញទៅ" ។ លុះស្អែកឡើង កាលព្រះមហាសត្វនោះអង្គុយលើបល្ល័ង្ក១ទេ បុរសអ្នកចាត់ចែងក៏កាន់យកកត្តាហារធម្មតារបស់ព្រះរាជា និងវត្ថុជ១ទៃមក ហើយបានថ្វាយកត្តាហារដែលលាយច្រឡំគ្នា ។ ក្នុងថ្ងៃទី ៣ បុរសអ្នកចាត់ចែងមិនព្រមឲ្យចូលក្នុងបន្ទប់ធំ ឲ្យស្នាក់ត្រង់ជើងជណ្តើរប៉ុណ្ណោះ ហើយបានថ្វាយកត្តាហារដែលលាយច្រឡំគ្នា ។ ព្រះមហាសត្វកាន់យកកត្តាហារនោះទៅកាន់ឧទ្យាន ទើបធ្វើកត្តកិច្ច ។ ក្នុងថ្ងៃទី ៤ បុរសអ្នកចាត់ចែងឲ្យឈរនៅត្រង់ប្រាសាទជាន់ក្រោម បានថ្វាយកត្តដែល

ចម្ងិនដោយចុងអង្ករ ។ ព្រះមហាសត្វក៏ទទួលសូម្បីកត្តានោះ ត្រឡប់ទៅកាន់ឧទ្យាន បានធ្វើកត្តកិច្ចហើយ ។ ព្រះរាជាត្រាស់សួរពួកអាមាត្យថា "មហាពោធិបរិព្វាជក សូម្បីកាលសក្ការៈវិនាសហើយ ក៏មិនព្រមចេញទៅ ពួកយើងនឹងធ្វើដូចម្តេចល្អ? ពួកអាមាត្យបានក្រាបទូលឧបាយថា "បពិត្រព្រះសម្មតិទេព គេប្រព្រឹត្តដើម្បីត្រូវការកត្តក៏មិនមែន តែគេប្រព្រឹត្តដើម្បីត្រូវការស្វតន្ត្រ ប្រសិនបើគេប្រព្រឹត្តដើម្បីត្រូវការកត្តពិត គេគប្បីគេចចេញទៅតាំងពីថ្ងៃដំបូងនោះឯង" ។ ព្រះរាជាត្រាស់សួរថា "ឥឡូវនេះ យើងគួរធ្វើយ៉ាងណាល្អ?" ពួកអាមាត្យក្រាបទូលថា "បពិត្រមហារាជ ស្ត្រីកនេះ សូមព្រះអង្គត្រាស់បង្គាប់ឲ្យសម្លាប់គេចុះ" ។ ស្តេចទទួលថា "ល្អហើយ" ហើយទ្រង់ប្រគល់ជាវទុកក្នុងដៃរបស់អាមាត្យទាំង ៥ នាក់នោះ ហើយត្រាស់ថា "ស្ត្រីកនេះ ពួកអ្នកចូរមកឈរលាក់ខ្លួនត្រង់ចន្ទោះទ្វារ រៀលាបរិព្វាជកនោះដើរចូលមក ចូរកាត់សីសៈគេហើយ

ជួយគ្នាចិញ្ចាំឲ្យជាចម្រៀកតូចៗ កុំឲ្យនរណាដឹងរឿង ហើយយក
ទៅទម្លាក់ក្នុងរណ្ដាលាមក ឆ្ងូតទឹកហើយសឹមត្រឡប់មកវិញចុះ” ។
អាមាត្យទាំងនោះទទួលថា “ព្រះករុណា” ហើយទើបកំណត់គ្នាថា
“ស្អែកនេះ ពួកយើងនឹងធ្វើការនោះ” ហើយក៏នាំគ្នាទៅកាន់ទីនៅ
រៀងៗ ខ្លួន ។ វេលាល្ងាច ព្រះរាជាកាលសោយភោជនវេលាល្ងាច
ហើយ ទ្រង់ផ្ទំលើទីផ្ទំដែលប្រកបដោយសិរី បានរលឹកដល់គុណ
របស់ព្រះមហាសត្ត ។ ព្រះសេទាក៏ហូរចេញអំពីព្រះសរីរៈ ។ ព្រះ
អង្គមិនបានទទួលសេចក្ដីរីករាយព្រះទ័យ ទ្រង់រសាប់រសល់ទៅមក
លើក្រឡាបន្ទំ ។ លំដាប់នោះ ព្រះអគ្គមហេសីផ្ទំនៅក្បែរព្រះអង្គ
ស្ដេចរមែងមិនធ្វើសូម្បីការចរចាជ្រាស្រ័យជាមួយព្រះនាងឡើយ ។
លំដាប់នោះ ព្រះនាងទើបទូលសួរស្ដេចថា “បពិត្រមហារាជ ហេតុ
អ្វីទ្រង់ទើបមិនធ្វើសូម្បីត្រឹមតែការសន្ទនាជ្រាស្រ័យ ឬថា ខ្ញុំម្ចាស់
មានកំហុសអ្វី?” ព្រះរាជាត្រាស់ថា “ទេវី នាងមិនមានកំហុសអ្វីទេ

តែបានដំណឹងថា ពោធិបរិព្វាជកបានក្លាយជាសត្រូវដល់ពួកយើង ដូច្នោះ យើងទើបបញ្ជូនអាមាត្យ ៥ នាក់ ចាត់ការសម្លាប់គេក្នុងថ្ងៃស្អែកនេះ អាមាត្យទាំងនោះនឹងសម្លាប់គេ នឹងកាប់ចិញ្ចៀរគេឲ្យជាចំណែកតូចៗ ហើយយកទៅចោះក្នុងរណ្ដៅលាមក ក៏ពោធិប-រិព្វាជកនោះបានសម្ដែងធម៌ដ៏ច្រើនដល់ពួកយើង អស់រយៈ ១២ ឆ្នាំ សូម្បីទោសបន្ទិចបន្ដួចរបស់គេ យើងក៏មិនធ្លាប់ឃើញប្រចក្ស ធ្លាប់តែទទួលពាក្យប្រាប់អំពីអ្នកដទៃ យើងក៏បង្គាប់ឲ្យទៅសម្លាប់គេ ព្រោះហេតុនោះ យើងទើបសោកសៅ” ។

លំដាប់នោះ ព្រះនាងទើបបានលួងលោមព្រះទ័យព្រះរាជាថា “បពិត្រព្រះសម្ដេចទេព ប្រសិនបើពោធិបរិព្វាជកនោះក្លាយជាសត្រូវពិត កាលព្រះអង្គគ្រាស់ឲ្យសម្លាប់គេ ហេតុអ្វីទើបទ្រង់សោកសៅ ដែលឈ្មោះថា សត្រូវសូម្បីជាកូនក៏ត្រូវសម្លាប់ ដើម្បីសុវត្ថិភាពដល់ខ្លួន ព្រះអង្គទ្រង់កុំសោកសៅឡើយ” ។ ព្រោះពាក្យរបស់ព្រះ

នាង ស្តេចទើបបានធូរព្រះទ័យ ផ្ទំលក់ទៅ ។ ក្នុងខណៈនោះឯង សុនខពណ៌លឿងឈ្មោះថា **កោលេយ្យកៈ** បានស្តាប់ពាក្យនោះហើយ ទើបគិតថា "ស្អែកនេះ យើងគួរនឹងជួយជីវិតពោធិបរិព្វាជកនោះ ដោយកម្លាំងរបស់ខ្លួន" ។ លុះព្រឹកឡើង ទើបចុះចាកប្រាសាទពីព្រឹក មកកាន់ព្រះទ្វារធំ ដេកយកក្បាលកើយលើធរណីទ្វារ រង់ចាំមើលផ្លូវព្រះមហាសត្វដើរមក ។ ចំណែកពួកអាមាត្យទាំងនោះឯង ក៏នាំគ្នាកាន់ដាវដើរមកឈរអែបត្រង់ចន្លោះទ្វារអំពីព្រឹកដែរ ។ សូម្បីព្រះពោធិសត្វកាលបានវេលាហើយ ទើបចេញចាកឧទ្យានមកកាន់ទ្វារវាំង ។

លំដាប់នោះ សុនខកោលេយ្យកៈឃើញព្រះពោធិសត្វហើយ ទើបហាមាត់បញ្ចេញចង្ហូមទាំង ៤ ស្រែកឡើងដោយសំឡេងខ្លាំងៗ ថា "បពិត្រលោកដ៏ចម្រើន លោកមិនបានកិក្ខាក្នុងទីដទៃសូម្បីក្នុងដែនជម្ពូទ្វីបនេះឬ ស្តេចផែនដីរបស់ពួកយើងទ្រង់ឲ្យអាមាត្យ ៥

នាក់មានជាវគ្រប់ដៃ លាក់ខ្លួនត្រង់ទ្វារដើម្បីត្រៀមការសម្លាប់លោក លោកកុំមកទទួលយកនូវសេចក្តីស្លាប់ក្នុងទីនេះឡើយ ចូរប្រញាប់ត្រឡប់ទៅដោយឆាប់ចុះ” ។ រីឯព្រះមហាសត្វដ៏ធំសេចក្តីនោះបានព្រោះខ្លួនជាអ្នកចេះក្នុងសំនៀងស្រែករបស់សត្វគ្រប់ប្រភេទ ទើបត្រឡប់អំពីទីនោះទៅកាន់ឧទ្យាន កាន់យកបរិក្ខារដើម្បីត្រៀមខ្លួនទ៏ងគេចចេញទៅ ។ ចំណែកព្រះរាជាប្រថាប់ឈរត្រង់សីហបញ្ជរ ទតព្រះនេត្រមើលព្រះមហាសត្វទាំងវេលាមក និងវេលាត្រឡប់ទៅ ទើបទ្រង់ព្រះតម្រិះថា “បើពោធិបរិព្វាជកនេះគឃ្លីជាសត្រូវនឹងយើងសោត កាលត្រឡប់ទៅកាន់ឧទ្យាន ក៏ទ៏ងឲ្យប្រជុំពួកពលត្រៀមការងារ បើមិនដូច្នោះ ក៏គង់ទ៏ងកាន់យកបរិក្ខាររបស់ខ្លួនហើយត្រៀមទ៏ងដើរផ្លូវ ជាដំបូងយើងទ៏ងដ៏ងកិរិយារបស់ពោធិបរិព្វាជកនោះ” ទើបស្តេចទៅកាន់ឧទ្យាន ទតព្រះនេត្រឃើញព្រះមហាសត្វដើរអំពីបណ្ណសាលា ដល់ខាងចុងទីចង្ក្រមដោយគិតថា “យើងទ៏ងកាន់យក

នូវបរិក្ខារបស់ខ្លួនហើយ នឹងទៅ" ទើបនមស្ការ ប្រថាប់ឈរត្រង់ទិសមគ្គរមួយ ត្រាស់គាថាថា

[៥២] *កិន្នុ ទណ្ឌំ កិមាជិនំ កិ ឆត្តំ កិ ឧបាហនំ*
កិ អង្ក្ខុសញ្ច បត្តញ្ច សង្ឆាដិញ្ចបិ ព្រាហ្មណ
តវមានរូបោ គណ្ហាសិ កិន្នុ បត្តយសេ ទិសំ ។

បពិត្រព្រាហ្មណ៍ ព្រោះហេតុអ្វីហ្ន៎ លោកទើបប្រញាប់-ប្រញាល់កាន់យកឈើច្រត់ ស្បែកខ្វា ឆត្រ ស្បែកជើង បាត្រ និងសំពត់ជ្រលក់ លោកប្រាថ្នានឹងទៅកាន់ទិសណាហ្ន៎ ។

គាថានោះមានសេចក្ដីថា ព្រះរាជាត្រាស់សួរថា "លោកដ៏ចម្រើន អំពីមុនលោកមកកាន់រាំងរបស់យើង មិនបានកាន់ឈើច្រត់ជាដើមឡើយ តែក្នុងថ្ងៃនេះ ព្រោះហេតុអ្វី លោកបានប្រញាប់កាន់យកនូវគ្រឿងបរិក្ខារសូម្បីទាំងអស់នេះ គឺ ឈើច្រត់ ស្បែកខ្វា ឆត្រ ស្បែកជើង ឆ្នាំងដី យាម ថង់សម្រាប់ដាក់ផ្លែឈើ បាត្រដី

និងសំពត់ជ្រលក់មកផងហ្ន៎ លោកប្រាជ្ញាទិសណាហ្ន៎ លោកប្រាជ្ញានឹងទៅទីណា?" ។

ព្រះមហាសត្វបានស្តាប់ពាក្យនោះហើយ គិតថា "ព្រះរាជាអង្គនេះយល់ថា ឥសីនេះមិនដឹងកម្មដែលខ្លួនឯងធ្វើទុក យើងនឹងឲ្យស្តេចដឹង" ទើបបានពោល ២ គាថាថា

[៥៣] ទ្វាទសេតានិ វស្សានិ វសិតានិ តវន្តិកេ
នាកិជានាមិ សោណេន បិង្គលេនាកិកូជិតំ ។
ស្វាយំ ទន្ត្តាវ ន ទតិ សុក្ខទាបំ វិទ៏ សយ
តវ សុត្ត សកវិយ្ យ្ យ្ យ

បពិត្រ និងព្រះជាយាដែលអស់សទ្ធា ទើបពោលនឹងអាត្មា យ៉ាងនេះ ។

បណ្តាបទទាំងនោះ បទថា **អកិកុជ្ជិតំ**[1] *សេចក្តីថា យើងមិនធ្លាប់បានឮសំឡេងដែលសុនទរបស់ព្រះអង្គនេះ ស្រែកដោយសំឡេងដ៏ខ្លាំងយ៉ាងនេះឡើយ ។ បទថា* **ទន្ត្តារ**[2] *“ហាក់ដូចជាមិនធ្លាប់ស្គាល់គ្នា” បានដល់ ហាក់ដូចមិនស្គាល់ ។ បទថា* **ស-ករិយស្ស** *“ជាមួយព្រះជាយា” នយថា ព្រោះវាបានឮពាក្យរបស់មហាបពិត្រ និងព្រះជាយាត្រាស់បង្គាប់ឲ្យអាមាត្យ ៥ នាក់ត្រៀមការសម្រាប់អាត្មាភាព ទើបបញ្ចេញសំឡេងយ៉ាងខ្លាំង ហាក់ដូចជាមិនធ្លាប់ស្គាល់គ្នាថា “លោកមិនបានកិក្ខាក្នុងទីដទៃឬ ព្រះរាជាបានត្រាស់ឲ្យអាមាត្យសម្រាប់លោក លោកកុំមកក្នុងទីនេះឡើយ” ។ បទថា* **រ៎ាតសទ្ធស្ស មំ បតិ** *“ដែលអស់សទ្ធា ទើបពោលនឹងអាត្មា*

បិដក. ១. បិន្ឋលេនាកិកូជិតំ ។ ២. ទន្ត្តារ ។

យ៉ាងនេះ" ព្រះមហាសត្វពោលថា "សុនខនោះវាបានស្តាប់ពាក្យ
របស់មហាបពិត្រដែលអស់សទ្ធាក្នុងយើង ទើបពោលដូច្នេះ" ។

ក្នុងលំដាប់នោះ ព្រះរាជាទ្រង់ព្រមទទួលកំហុស កាលនឹង
ទ្រង់ឲ្យព្រះមហាសត្វលើកទោស ទើបត្រាស់គាថាទី ៤ ថា

[៥៤] *អហុ ឯស ករោ ទោសោ យថា ភាសសិ ព្រាហ្មណ*
ឯស ភិយ្យោ បសីទামិ ១ សេ ព្រាហ្មណ មា គមា ។

បពិត្រព្រាហ្មណ៍ ទោសដែលខ្ញុំធ្វើហើយនោះ ក៏ពិតតាម
ដែលលោកពោល ខ្ញុំនេះកាន់តែជ្រះថ្លាក្រៃលែងឡើង សូម
លោកចូរនៅចុះ កុំចេញទៅឡើយព្រាហ្មណ៍ ។

បណ្តាបទទាំងនោះ បទថា **ភិយ្យោ** "ក្រៃលែង" សេចក្តីថា
ខ្ញុំបានត្រាស់បង្គាប់ដូច្នេះពិតមែន នេះជាកំហុសរបស់ខ្ញុំ ក៏ខ្ញុំកាន់
តែជ្រះថ្លាថែមទៀតក្នុងកាលឥឡូវនេះ សូមលោកចូរនៅក្នុងទីនេះ
ដូចដើមចុះ កុំទៅកាន់ទីដទៃឡើយព្រាហ្មណ៍ ។

ព្រះមហាសត្វបានស្តាប់ពាក្យនោះហើយ ទើបទូលថា "សូមថ្វាយព្រះពរ ធម្មតាថា បណ្ឌិតទាំងឡាយរមែងមិននៅរួមគ្នាជាមួយសត្រូវ ដែលធ្វើការកំចាំងក្រោយខ្នងដូចជាព្រះអង្គឡើយ" កាលនឹងប្រកាសអនាចារបស់ព្រះរាជានោះ ទើបពោលគាថាថា

[៥៥] *សព្វសោ តោ បុរេ អាសិ តតោបិ សពលោ អហុ*

សព្វលោហិតកោ ទានិ ការោ បក្ខមិតុំ មម ។

កាលមុន ជ្រាយសសុទ្ធ ក្រោយមកក៏មានវត្ថុដទៃលាយ ឥឡូវនេះក្រហមហើយ គ្រានេះជាវេលាសមគួរដែលអាត្មានឹងចេញទៅហើយ ។

អញ្ញន្តរំ បុរេ អាសិ តតោ មជ្ឌ តតោ ពហិ

បុរា និទ្ធមនា ហោតិ សយមេវ ឯជាមហំ ។

មួយទៀត កាលមុន អាសនៈមាននៅខាងក្នុង តមកមានត្រង់កណ្តាល តមកមាននៅខាងក្រៅ មុននឹងត្រូវបណ្តេញ

ចេញអំពីព្រះរាជនិវេសន៍ អាត្មាសូមចេញទៅខ្លួនឯង ។

វីតសទ្ធំ ន សេវេយ្យ ខុទបានំវ នោទកំ

សចេបិ នំ អនុ១ណ ភារិកទ្ទុមគន្ធិកំ ។

បុគ្គលមិនគួរគប់រកអ្នកដែលប្រាសចាកសទ្ធា ដូចអណ្ដូងដែលមិនមានទឹកជូរ្ចោះ បើសូម្បីបុគ្គលនឹងគប្បីជីកអណ្ដូងទឹកនោះ អណ្ដូងនោះក៏គង់មានទឹកដែលមានក្លិនកក់ ។

បសន្នមេវ សេវេយ្យ អប្ប្ជសន្ធំ វិវជ្ជយ

បសន្ធំ ២ យិ១ុ១ាសេយ្យ ១ហទំ ១ុទកត្ថិកោ ។

បុគ្គលគួរគប់គ្រងមនុស្សដែលជ្រះថ្លាប៉ុណ្ណោះ គួរវៀរបុគ្គលដែលមិនជ្រះថ្លា គួរចូលទៅអង្គុយជិតបុគ្គលដែលជ្រះថ្លា ដូចបុគ្គលត្រូវការទឹក ចូលទៅរកអន្ទង់ទឹកជូរ្ចោះ ។

ភជ ភជន្ធំ ២ ១ិ១ិ១ំ អភជន្ធំ ន ភជ្ជយ

អ១ប្ប១ិ១ធម្មោ ១ សោ យោ ភជន្ធំ ន ភជ្ជតិ ។

បុគ្គលគួរគប់រកអ្នកដែលគប់រក មិនគួរគប់រកអ្នកដែលមិនគប់រក បុគ្គលណាមិនគប់រកអ្នកដែលគួរគប់រក បុគ្គលនោះឈ្មោះថាមានធម៌របស់អសប្បុរស ។

យោ ភជន្តំ ន ភជតិ សេវមានំ ន សេវតិ

សវៃ មនុស្សបាបិដ្ឋោ មិគោ សាខស្សិតោ យថា ។

បុគ្គលណាមិនគប់រកបុគ្គលដែលគប់រក មិនសេពបុគ្គលអ្នកសេព ជននោះឯងជាមនុស្សអាក្រក់បំផុត ដូចម្រឹគអាស្រ័យមែកឈើ (ស្វា) ដូច្នោះ ។

អច្ចាកិច្ចណសំសគ្គា អស្សមោ សរណេន ច

ឯតេន មិត្តា ជីរន្តិ អកាលេ យាចនាយ ច ។

មិត្តទាំងឡាយ រមែងលាកនឹងគ្នាដោយហេតុ ៣ ប្រការនេះ គឺ ដោយការស្និទ្ធស្នាលគ្នាហួសពេក ១ ដោយការមិនទៅរកគ្នា ១ ដោយការសូមក្នុងវេលាមិនសមគួរ ១ ។

តស្មា នាកិច្ចណំ គច្ឆេ ន ច គច្ឆេ ចិរាចិរំ

កាលេន យាចំ យាចេយ្យ ឯវំ មិត្តា ន ជីររេ[1] ។

ព្រោះដូច្នោះ បុគ្គលទើបមិនគួរទៅមករកគ្នាឲ្យញឹកញាប់ពេក មិនគួរយ្ហាតឆ្ងាយយូរ និងគួរសូមវត្ថុដែលគួរតាមកាលដ៏សមគួរ ដោយអាការយ៉ាងនេះ មិត្តទាំងឡាយទើបមិនលាកចិត្តពីគ្នា ។

អតិចិរំ និវាសេន ចិរយោ ភវតិ អប្ឋិយោ

អាមន្ត ខោ តំ គច្ឆាម បុរ តេ ហោម អប្ឋិយា ។

បុគ្គលជាទីស្រឡាញ់ រមែងមិនជាទីស្រឡាញ់ទីងគ្នាបានព្រោះការនៅរួមគ្នាយូរពេក កាលមុនអាត្មាមិនជាទីស្រឡាញ់របស់មហាបពិត្រ អាត្មាពោលហើយក៏សូមលាទៅហើយ ។

បណ្ដាបទទាំងនោះ បទថា *សព្ឋសោតោ* "ជាយសសុទ្ធ" *គឺ*

១.ម. ន ជិយរេ ។

សូមថ្វាយព្រះពរ មុនដំបូង ជាយរបស់អាត្មាក្នុងនិវេសន៍របស់ព្រះ
អង្គមានពណ៌សសុទ្ធ ព្រះអង្គសោយជាយប្រកេទណា ក៏ព្រះរាជ-
ទានជាយប្រកេទនោះ (ដល់អាត្មា) ។ បទថា ***តតោ “ខាងក្រោយ”***
សេចក្ដីថា ក្រោយអំពីនោះ គឺ ក្នុងកាលដែលព្រះអង្គទ្រង់ជ្រៀតក្យ
របស់បុគ្គលអ្នកញុះញង់ ហើយលាកចិត្តក្នុងអាត្មា ជាយទើបមាន
ពណ៌ដទៃ និងលាយច្របល់ គ្នាផង ។ បទថា ***ឥទានិ “ឥឡូវនេះ”***
គឺ ឥឡូវនេះ ជាយក៏ក្លាយជាក្រហមសុទ្ធ ។ បទថា ***កាលោ “ជា***
វេលា” *បានដល់ គ្រានេះ ជាវេលាដែលអាត្មានឹងត្រូវចេញចាកពី*
សម្ផាក់របស់ព្រះអង្គដែលល្ងង់ខ្លៅ ។ បទថា ***អញ្ញន្តរំ “ខាងក្នុង”***
សេចក្ដីថា គ្រាដំបូង អាសនៈរបស់អាត្មាមាននៅខាងក្នុង គឺ ពួក
អ្នកបម្រើនិមន្តអាត្មាអង្គុយលើបល្ល័ង្ក មានផ្ទៃធំ ដែលប្រដាប់ហើយ
មានសេ្ងតធ្ងន់ លើកឡើង ។ បទថា ***មជ្ឌ “ត្រង់កណ្ដាល”*** *គឺ*
ត្រង់ក្បាលជណ្ដើរ ។ បទថា ***បុព និទ្ទមនា ហោតិ “មុននឹងត្រូវ***

បណ្ដេញចេញអំពីព្រះរាជនិវេសន៍" សេចក្ដីថា ចាប់កអូសចេញ
ទៅ ។ បទថា **អនុ១ណ "ទ្ធ៏ងគប្បីជីក"** សេចក្ដីថា បើបុរសទៅ
ដល់អណ្ដូងដែលមិនមានទឹក កាលមិនឃើញទឹក ទើបជីកកកាយ
ឡើង ។ សូម្បីនឹងធ្វើដូច្នោះ ទឹកនៃអណ្ដូងនោះក៏គង់នឹងមានតែ
ភ្ជិនកក់ ផឹកមិនបានព្រោះមិនជាទីពេញចិត្ត យ៉ាងណា សូម្បីបច្ច័យ
ដែលបុគ្គលចូលទៅរកអ្នកប្រាសចាកសទ្ធា ហើយបានមក ក៏ជា
របស់តិច និងសៅហ្មង មិនជាទីពេញចិត្ត មិនសមគួរនឹងបរិភោគ
ដូច្នោះ ។ បទថា **ឧសន្ធ "ដែលជ្រះថ្លា"** បានដល់ មានសទ្ធាតាំង
មាំហើយ ។ បទថា **រហទ "អន្ទង់ទឹក"** បានដល់ អន្ទង់ទឹកធំ និង
ជ្រៅ ។ បទថា **ភជន្ត "អ្នកគប់ជាមួយ"** បានដល់ បុគ្គលគួរគប់
រកបុគ្គលដែលគប់រកខ្លួនប៉ុណ្ណោះ ។ បទថា **អភជន្ត "អ្នកមិនគប់
ជាមួយ"** បានដល់ អ្នកជាសត្រូវ ។ បទថា **ន ភជ្ជយ "មិនគួរ
គប់រក"** បានដល់ មិនគប្បីគប់រក ។ បទថា **ន ភជ្ជតិ "មិនគប់**

រក" សេចក្ដីថា បុរសណាមិនគប់រកបុគ្គលដែលគប់រកខ្លួន ដែលមានចិត្តគិតប្រាថ្នាប្រយោជន៍ បុរសនោះឈ្មោះថា មានធម៌របស់អសប្បុរស ។ បទថា **មនុស្សជ្ឌាបិដ្ឌោ** "**ជាមនុស្សអាក្រក់ជាទីបំផុត**" បានដល់ មនុស្សលាមក គឺ មនុស្សថោកទាប ។ បទថា **សាខសរ្ជិតោ** "**ម្រ៉ែតដែលអាស្រ័យមែកឈើ**" គឺ ស្វា ។ បទថា **អច្ចាកិកូណសំសគ្គា** "**ដោយសេចក្ដីស្ងួតស្ងាត់ខ្លាំងពេក**" បានដល់ ដោយសេចក្ដីស្ងួតស្ងាត់គ្នារៀយៗ ហួសពេក ។ បទថា **អកាលេ** "**ក្នុងវេលាមិនសមគួរ**" សេចក្ដីថា មិត្តទាំងឡាយឈ្មោះថា រមែងលាកចិត្តនឹងគ្នា ព្រោះការសូមរបស់ជាទីស្រឡាញ់របស់អ្នកដទៃ ក្នុងកាលមិនទាន់ដល់វេលាដ៏សមគួរ សូម្បីព្រះអង្គក៏អស់សេចក្ដីមេត្តាក្នុងអាត្មា ព្រោះតែការនៅរួមគ្នាយូរពេក ។ បទថា **ឥស្ម**ា "**ព្រោះដូច្នោះ**" សេចក្ដីថា ព្រោះមិត្តទាំងឡាយរមែងបែកគ្នាដោយការស្ងួតស្ងាត់ហួសពេក និងដោយការឃ្លាតឆ្ងាយពេក ដូច្នោះ ។

*បទថា **ចិរាចរំ** "**ឲ្យយឺតយូរ**" សេចក្ដីថា មិនបណ្ដាយវេលាឲ្យ*
*ក្ងន់ទៅយូរឡើយ ក៏ទៅរកគ្នា គឺ ចូលទៅរកគ្នា ។ បទថា **យាចំ** "**វត្ថុដែលគួរសូម**" សេចក្ដីថា គួរសូមវត្ថុដែលសមគួរក្នុងវេលា*
*ដែលសមគួរ ។ បទថា **ន ជីរេ** "**ទើបមិនលាកចិត្តនឹងគ្នា**" បាន*
ដល់ មិត្តទាំងឡាយមិនបែកគ្នាដោយអាការយ៉ាងនេះ ។ បទថា
បុរា តេ ហោម** "**មុនដែលអាត្មាមិនទាន់ជាទីមិនស្រឡាញ់របស់
***មហាបពិត្រ**" សេចក្ដីថា អាត្មានៅមិនទាន់ជាទីមិនស្រឡាញ់របស់*
មហាបពិត្រត្រឹមណា អាត្មាពោលហើយនឹងត្រាច់ទៅត្រឹមនោះ ។

ព្រះរាជាត្រាស់ថា

[៥៦] *ឯវំ ចេ យាចមានានំ អញ្ជលី នាវពុជ្ឈសិ*
បរិចារិកានំ សត្ថានំ វចនំ ន ករោសិ នោ
ឯវន្តំ អកិយាចាម បុន ករិយាសិ ករិយាយ ។

បើលោកម្ចាស់មិនទទួលដឹងអញ្ជលីរបស់សត្ថ ដែលជា

បរិវារអ្នកអង្វរហើយយ៉ាងនេះ មិនធ្វើតាមពាក្យសូមរបស់ខ្ញុំ ខ្ញុំសូមអង្វរលោកម្ចាស់យ៉ាងនេះថា សូមលោកម្ចាស់ជ្រោសត្រឡប់មកទីនេះម្តងៗ ចុះ ។

បណ្តាបទទាំងនោះ បទថា **នាវពុជ្ឌ្ឍសិ** *"មិនទទួលដឹង" គឺ បពិត្រលោកដ៏ចម្រើន បើលោកមិនព្រមទទួលដឹង គឺ មិនព្រមទទួលនូវអញ្ជាលីដែលខ្ញុំអង្វរហើយយ៉ាងនេះ ។ បទថា* **បរិយាយ** *"**មកម្តងៗ**" សេចក្តីថា ព្រះរាជាទ្រង់ត្រាស់អង្វរថា "សូមលោកវកឱកាសត្រឹមតែម្តង ដើម្បីមកកាន់ទីនេះទៀត" ។*

ព្រះពោធិសត្វទូលថា

[**៥៧**] *ឯវញ្ចេ នោ វិហារតំ អន្ត្ពាយោ ន ហេស្សតិ*
តុយ្ហំ វាបិ មហារាជ មយ្ហំ វា រដ្ឋវឌ្ឍន
អប្ជ្ជ នាម ឧបេស្សម អហោរត្តានមច្ចយេ ។
មហាបពិត្រអ្នកការក្សារដ្ឋ ប្រសិនបើយើងទាំងឡាយនៅ

យ៉ាងនេះ អ្នកយន្ទ្រីងមានដល់មហាបពិត្រ ឬដល់អាត្មាភាព សោត ដូច្នេះ យើងទាំងឡាយគប្បីឃើញគ្នាខ្លះ កាលថ្ងៃ និង យប់ក្នុងនៅ ។

បណ្តាបទទាំងនោះ បទថា **ឯវញ្ចេ នោ** *"ប្រសិនបើយើងទាំង* ***ឡាយ... យ៉ាងនេះ"*** *ព្រះពោធិសត្វសម្តែងថា "មហាបពិត្រ បើ អ្នកយន្ទ្រីងមិនបៀតបៀនយើងទាំងពីរ ដែលនៅបែកគ្នាយ៉ាងនេះ ជីវិតរបស់ព្រះអង្គ ឬរបស់អាត្មាក៏ទ្រឹងយ៉ឺនយូរ" ។ បទថា* ***បសេ្សម "គប្បីឃើញ"*** *បានដល់ ពួកយើងគប្បីបានជួបគ្នាដោយពិត ។*

ព្រះពោធិសត្វគ្រាពោលយ៉ាងនេះចប់ហើយ បានសម្តែងធម៌ ដល់ព្រះរាជា ទើបទូលថា "មហាបពិត្រ សូមព្រះអង្គទ្រង់កុំប្រមាទ ឡើយ" ហើយចេញចាកឧទ្យានត្រាច់កិក្ខាចារទៅក្នុងស្ថានទីដែល មានចំណែកស្មើគ្នាមួយកន្លែង ចេញចាកក្រុងពារាណសីហើយ ក៏ ដល់ហិមវន្តប្បទេសដោយលំដាប់ ស្នាក់នៅអស់កាលបន្តិច បាន

ត្រឡប់មកនៅក្នុងព្រៃ អាស្រ័យបចូន្ត្រគ្រាមមួយកន្លែង ។ តាំងពីវេលាដែលព្រះពោធិសត្វចេញទៅហើយ ពួកអាមាត្យទាំងនោះ ក៏បាននាំគ្នាអង្គុយត្រង់សាលាវិនិច្ឆ័យក្តីទៀត កាលនឹងធ្វើការបៀត-បៀន បាននាំគ្នាគិតថា "បើមហាពោធិបរិព្វាជកនឹងត្រឡប់មកវិញ ជីវិតរបស់ពួកយើងគង់មិនមានដោយពិត ពួកយើងគួរធ្វើនូវហេតុដែលនឹងឲ្យបរិព្វាជកនោះមិនត្រឡប់មកបានទៀតយ៉ាងណាស្អ្ហ?" លំដាប់នោះ ពួកគេទើបប្រឹក្សាគ្នាថា "ធម្មតាសត្វទាំងឡាយរមែងមិនអាចនឹងលះបង់ទីដ្ឋានដែលខ្លួនជាប់ជំពាក់បានឡើយ ទីដ្ឋានដែលមហាពោធិបរិព្វាជកនោះជាប់នៅក្នុងទីនេះ គឺ អ្វីហ្ន?" តពីនោះ ពួកអាមាត្យក៏ជ្រាបថា "គង់ជាព្រះអគ្គមហេសីរបស់ព្រះរាជាដោយពិត" ទើបប្រឹក្សាគ្នាថា "ប្រការដែលមហាពោធិបរិព្វាជកនោះមកព្រោះអាស្រ័យព្រះអគ្គមហេសី នេះជាហានៈដែលនឹងមាន ពួកយើងគប្បីប្រញាប់សម្លាប់ព្រះអគ្គមហេសីនោះចេញដោយឆាប់" ។ ពួក

អាមាត្យទាំងនោះទើបនាំគ្នាក្រាបទូលសេចក្តីនេះចំពោះព្រះរាជាថា "ច្រើនថ្ងៃមកនេះ ពួកខ្ញុំព្រះអង្គបានឮរឿងមួយ" ។ ព្រះរាជាត្រាស់សួរថា "រឿងអ្វី?" ពួកអាមាត្យក្រាបទូលព្រះរាជាកុហកថា "ឮថា មហាពោធិបរិព្វាជក និងព្រះទេវីបានបញ្ជូនសារធ្វើយឆ្ងងគ្នាទៅមករឿយៗ" ។ ព្រះរាជាត្រាស់សួរថា "សារនោះបញ្ជូនឲ្យធ្វើអ្វីដែរ?" ពួកអាមាត្យក្រាបទូលថា "ដំណឹងថា មហាពោធិបរិព្វាជកនោះឯង បញ្ជូនសារមកព្រះរាជទេវីថា នាងអាចនឹងផ្តាច់ព្រះជន្មព្រះរាជាឲ្យស្លាប់ដោយកម្លាំងរបស់ខ្លួន ហើយលើកសេ្វតឆត្រឲ្យដល់យើងបានឬទេ ចំណែកព្រះទេវីនោះ ក៏បញ្ជូនសារតបទៅមហាពោធិបរិព្វា-ជកនោះថា ការផ្តាច់ព្រះជន្មព្រះរាជាជាការៈរបស់ខ្ញុំ សូមឲ្យមហាពោធិបរិព្វាជកមកឲ្យរហ័សចុះ ដូច្នេះ" ។ កាលពួកអាមាត្យទាំងនោះក្រាបទូលរឿយៗ ព្រះរាជាក៏ទ្រង់ជឿ ទើបបានត្រាស់សួរថា "ឥឡូវនេះ យើងគប្បីធ្វើដូចម្តេចល្អ?" កាលពួកអាមាត្យក្រាបទូល

ថា "គួរផ្តាច់ព្រះជន្មព្រះទេវីចេញ" ទ្រង់មិនទាន់បានពិចារណា ក៏ត្រាស់បង្គាប់ថា "បើដូច្នោះ ពួកអ្នកចូរសម្ងាប់នាងចុះ ហើយកាប់ចិញ្ចៀនឲ្យជាចំណែកតូចៗ ចោះវាទៅក្នុងរណ្ដៅលាមកចុះ" ។ ពួកអាមាត្យទាំងនោះធ្វើការតាមព្រះតម្រាស់ហើយ ។ សេចក្ដីដែលព្រះទេវីត្រូវផ្តាច់ព្រះជន្ម បានប្រាកដឡើងទូទៅក្នុងព្រះនគរ ។

គ្រានោះ ព្រះរាជឱរស ៤ អង្គរបស់ព្រះទេវីនោះទ្រង់ជ្រាបថា "ព្រះបិតាទ្រង់ត្រាស់ឲ្យផ្តាច់ព្រះជន្មព្រះមាតារបស់ពួកយើងជាអ្នកគ្មានកំហុស" ទើបបានចងសត្រូវជាមួយព្រះរាជា ។ ព្រះរាជាទ្រង់បានជាអ្នកប្រសព្ធនឹងភ័យយ៉ាងធំ ។ ព្រះមហាសត្វបានជ្រាបរឿងនោះ ទើបត្រិះរិះថា "រៀរចាកយើងចេញហើយ បុគ្គលដទៃឈ្មោះថាអាចនឹងឲ្យព្រះកុមារទាំងនោះយល់ព្រម និងឲ្យព្រះបិតាទ្រង់អត់ទោសឲ្យមិនមាន យើងនឹងជួយជីវិតព្រះរាជា និងដោះព្រះកុមារឲ្យផុតចាកបាប" ។ ក្នុងថ្ងៃស្អែកឡើង លោកទើបចូលទៅ

កាន់បច្ចន្តគ្រាម ឆាន់សាច់ពានរដែលពួកមនុស្សនាំមកប្រគេន និង
សូមស្បែកពានរនោះ នាំយកមកហាលឲ្យស្ងួតទុកក្នុងអាស្រម ធ្វើ
រហូតអស់ក្ងិន ប្រើដណ្ដប់ ស្បៃកខ្ទះ បង់កខ្ទះ ។ សួរថា "ការ
ដែលព្រះមហាសត្វធ្វើដូច្នោះ ព្រោះហេតុអ្វី?" ឆ្លើយថា "ការធ្វើ
ដូច្នោះ ក៏ដើម្បីនឹងប្រាប់ដល់ពួកមនុស្សថា ពានរនេះ មានឧបការ:
ច្រើនដល់យើង ដូច្នេះ" ។ ព្រះមហាសត្វកាន់យកស្បែកពានរនោះ
ទៅកាន់ក្រុងពារាណសីដោយលំដាប់ ហើយចូលទៅរកព្រះកុមារ
ទាំងឡាយ ទូលជាស់តឿនថា "ដែលឈ្មោះថាកម្ម គឺ ការសម្ងាប់
ព្រះបិតាជាកម្មដ៏ធ្ងន់ ពួកអ្នកមិនសមគួរធ្វើកម្មនោះទ្បើយ ធម្មតា
ថា សត្វដែលមិនចាស់មិនស្លាប់មិនមាន យើងមកហើយ (ក្នុងទី
នេះ) ក៏ដោយបំណងថា នឹងសូមឲ្យពួកអ្នកមានការសាមគ្គីដល់គ្នា
និងគ្នា រៀងយើងបញ្ជូនដំណឹងទៅ ពួកអ្នកគប្បីនាំគ្នាមក" លុះ
ទូន្មានព្រះកុមារស្រេចហើយ ទើបចូលទៅកាន់ព្រះរាជឧទ្យានខាង

ក្នុងព្រះនគរ ក្រាលស្បែកពានរហើយ អង្គុយលើផែនថ្ម ។ ក្នុងខណៈនោះ មនុស្សចាំឧទ្យានឃើញលោក ក៏ប្រញាប់ទៅក្រាបទូលព្រះរាជា ។ ព្រះរាជាទ្រង់ស្តាប់ដំណឹងនោះហើយ ទ្រង់ក៏សោម-នស្ស ទើបនាំអាមាត្យទាំង ៥ នាក់នោះទៅក្នុងទីនោះ ទ្រង់នមស្តារព្រះមហាសត្វហើយប្រថាប់អង្គុយ ប្រារព្ធនឹងធ្វើបដិសណ្ឋារៈ ។ ចំណែកព្រះមហាសត្វមិនបានរីករាយជាមួយព្រះរាជាទេ បានសូបអង្ហែលស្បែកពានរធ្វើព្រងើយ ។ លំដាប់នោះ ព្រះរាជាទើបត្រាស់នឹងព្រះមហាសត្វយ៉ាងនេះថា "លោកដ៏ចម្រើន លោកមិនព្រមចរចាជាមួយនឹងខ្ញុំ រវល់សូបអង្ហែលស្បែកពាន តើស្បែកពានរបស់លោកនេះមានឧបការៈច្រើនជាងខ្ញុំឬ?" ព្រះមហាសត្វទូលថា "ពិតដូច្នោះមែន មហាបពិត្រ ពានរនេះមានឧបការៈដ៏ច្រើនដល់យើង យើងអង្គុយលើខ្នងរបស់វាត្រាច់ទៅ ពានរនេះនាំក្អមទឹកមកឲ្យដល់យើង ជោសសម្អាតទីនៅឲ្យយើង បានធ្វើអកិសមាចារិកវត្តបដិ-

បត្តិដល់យើង តែយើងត្រឡប់ជាស៊ីសាច់របស់វា យកស្បែកហាល ឲ្យស្ងួតទុកក្រាលអង្គុយខ្លះ ក្រាលដេកខ្លះ ព្រោះខ្លួនមានចិត្តទុព្ភិ ពានរនេះមានឧបការៈច្រើនដល់យើងដូច្នេះ" ។ ព្រះមហាសត្វលើក ស្បែកពានរឡើងពោលជាវោហារៀងពានរ ដើម្បីត្រូវការទម្លាយ ភ័ន:របស់អាមាត្យទាំងនោះ អាស្រ័យបរិយាយនោះ ទើបពោល ពាក្យនេះ ដោយប្រការដូច្នេះ ។ ពិតហើយ ព្រះមហាសត្វពោល ថា "យើងអង្គុយលើខ្នងវាត្រាច់ទៅ" ព្រោះលោកធ្លាប់ស្ទៀកដណ្ដប់ ស្បែករបស់វា ។ លោកពោលថា "វានាំក្អមទឹកមកឲ្យ" ព្រោះ លោកយកស្បែករបស់វាពាក់ត្រង់ស្នាស្ពាយក្អមទឹក ។ ការដែល លោកពោលថា "វាបោសសម្អាតទីនៅឲ្យ" ព្រោះលោកធ្លាប់យក ស្បែកនោះបោសដី ។ លោកពោលថា "វាធ្វើវត្តបដិបត្តិដល់យើង" ព្រោះខ្ងងត្រូវស្បែកនោះក្នុងវេលាដេក និងត្រង់ជើងក្នុងវេលាដែល ជាន់ ។ លោកពោលថា "តែយើងត្រឡប់ជាស៊ីសាច់របស់វា ព្រោះ

ខ្ជួនមានចិត្តទុព្ទ្ធ” ព្រោះលោកបានសាច់របស់វាមកហើយក៏ចរិ-
ភោគក្នុងវេលាយ្ជាន ។

ពួកអាមាត្យទាំងនោះបានស្តាប់ពាក្យនោះហើយ មានសេចក្តី
សម្គាល់ថា “លោកនោះធ្វើបាណាតិបាតហើយ” ទើបនាំគ្នាទះដៃ
ធ្វើការសើចឡើងថា “លោកដ៏ចម្រើន ពួកលោកចូរមើលកម្មរបស់
បព្ជជិតចុះ បានឮហើយមិនមែនឬថា បព្ជជិតនេះសម្ជាប់ស្ងាស៊ី
សាច់ នៅកាន់យកស្បែកត្រាច់ទៅ” ។ ព្រះមហាសត្ជយើញពួក
អាមាត្យទាំងនោះធ្វើដូច្នោះ ទើបគិតថា “ពួកអាមាត្យទាំងនេះនៅ
មិនទាន់ដឹងសេចក្តីដែលយើងយកស្បែកពានរមកដើម្បីត្រូវការនឹង
ទម្ជាយវាទ:របស់ខ្ជួន យើងនឹងឲ្យពួកគេដឹង” ជាដំបូងទើបហៅ
អាមាត្យអហេតុកវាទីមក ហើយសួរថា “អ្នកដ៏មានអាយុ លោក
សើចយើងព្រោះហេតុអ្ជី?” គេតបថា ព្រោះលោកធ្វើកម្ម គឺ ការ
ប្រទូស្តចំពោះមិត្ត និងធ្វើបាណាតិបាតផង” ។

លំដាប់នោះ ព្រះមហាសត្វគិតថា "បុគ្គលជឿពាក្យអាមាត្យទាំងនោះ ដោយគតិ និងទិដ្ឋិហើយធ្វើតាមនោះ នឹងមានអ្វីដែលនឹងគប្បីពោលថា បុគ្គលនោះធ្វើសេចក្តីអាក្រក់" កាលនឹងទម្លាយវាទៈរបស់អហេតុកវាទីអាមាត្យនោះ ទើបពោលជាគាថាថា

[៥៨] ឧទីរណា ចេ សង្ហ្ការ ការាយមនុវត្តតិ
អកាមា អការណីយំ វា ការណីយំ វាបិ ក្រុព្ធតិ
អកាមការណីយស្មិ ក្ងិធ ជ្ជាបេន លិម្ប្ជតិ ។

បើពាក្យអ្នកប្រព្រឹត្តទៅតាមគតិដែលល្អ និងតាមសភាពសត្វធ្វើកម្មដែលមិនគួរធ្វើខ្លះ ដែលគួរធ្វើខ្លះ ព្រោះមិនមានសេចក្តីត្រូវការ សត្វអ្វីក្នុងលោកនេះ នឹងនៀយណាយដោយជ្ជាបក្នុងកម្មដែលគប្បីធ្វើដោយមិនមានសេចក្តីត្រូវការហ្ន៎

សោ ចេ អត្តា ច ធម្ម្ជោ ច កល្យាណោ ន ច ជ្ជាបកោ
ភោតោ ចេ ១ចនំ សច្ចំ សុហតោ ១ានភេ ១យា ។

បើសេចក្ដីនៃកាសិតរបស់អ្នកនោះ ជាអត្ថ ជាធម៌ និង ជាពាក្យស្អាត មិនអាក្រក់ បើពាក្យរបស់អ្នកពិត ស្វាក៏ជាការដែលយើងសម្ងាប់ល្អហើយ

អត្ថនោ ចេ ហិ ភាទេ្ស អបរាធំ វិជានិយ

ន មំ ត្វំ ឧរេហយ្យាសិ ភោតោ ភាតេ ហិ ភាទិសោ ។

បើអ្នកដឹងនូវកំហុសនៃភាទ:របស់ខ្លួន ក៏មិនគប្បីតិះដៀលយើងទ្បើយ ព្រោះថា ភាទ:របស់អ្នកជាយ៉ាងដូច្នោះឯង ។

*បណ្ដាបទទាំងនោះ បទថា **ឧទីរណា** "ពាក្យសម្ដី" បានដល់ពាក្យនិយាយ ។ បទថា **សង្ខ្ដត្យា** "តាមគតិដែលល្អ" បានដល់ផ្លូវទៅដែលល្អ គឺ ដោយការចូលដល់អភិជាតិនោះៗ ក្នុងបណ្ដាអភិជាតិទាំង ៦ យ៉ាង ។ បទថា **ការាយមនុវត្ដតិ** "ប្រព្រឹត្ដទៅ... **តាមសការ:**" សេចក្ដីថា រមែងប្រព្រឹត្ដទៅតាមការ: ។ ពាក្យនេះជាសម្ប្ទាន: ប្រើក្នុងអត្ថនៃករណ: ។ បទថា **អកាមា** "ព្រោះ*

មិនមានសេចក្ដីត្រូវការ" គឺ មិនមានសេចក្ដីប្រាថ្នា មិនមានសេចក្ដីចង់បាន ។ បទថា **អការណីយំ វា "កម្មដែលមិនគួរធ្វើ"** បានដល់អំពើអាក្រក់ដែលជាវត្ថុមិនគួរធ្វើ ។ បទថា **ការណីយំ វា "ដែលគួរធ្វើ"** បានដល់ រមែងធ្វើ ។ បទថា **កុវិធ "សត្វណាក្នុងលោកនេះ"** កាត់បទជា **កោ ឥធ** ។ មានពាក្យដែលលោកអធិប្បាយទុកថា លោកជាអហេតុកវាទី ជាអ្នកមានការយើញជាដើមថា "មិនមានហេតុ មិនមានបច្ច័យ ដើម្បីសេចក្ដីសៅហ្មងនៃសត្វទាំងឡាយ" ទើបពោលថា "លោកនេះរមែងសូន្យទៅ គឺ រមែងប្រែប្រួលទៅតាមគតិដែលល្អ និងតាមសការៈ សោយសុខ និងទុក្ខក្នុងទីនោះៗ និងសត្វដែលមិនមានសេចក្ដីត្រូវការ (តាំងចិត្ត) រមែងធ្វើបាបខ្លះ បុណ្យខ្លះ" ពាក្យរបស់លោកនេះ បើដូច្នោះ កាលបាបដែលសត្វធ្វើដោយមិនមានសេចក្ដីប្រាថ្នា (ក្នុងបាប) មាន សត្វណាក្នុងលោកនេះ រមែងប្រទ្បាក់ដោយបាបក្នុងបាបដែលប្រព្រឹត្តទៅតាមធម្មតា

របស់ខ្លួន ។ ក៏បើសត្វរមែងប្រទ្ឆាក់ដោយបាបដែលខ្លួនមិនបានធ្វើ ហើយ មិនមាននរណាប្រទ្ឆាក់ដោយបាបឡើយ ។ បទថា **សោ ចេ "បើសេចក្តីនៃកាសិតរបស់លោកនោះ"** អធិប្បាយថា សេចក្តីនៃកាសិតរបស់លោក គឺ វាទៈដែលថាមិនមានហេតុនោះ បើជាសេចក្តីដែលមានប្រយោជន៍ ឲ្យនូវប្រយោជន៍ ជាធម៌មានសេចក្តីល្អមិនអាក្រក់ បើពាក្យរបស់លោកដ៏ចម្រើនដែលថា "សត្វទាំងឡាយមិនមានហេតុ មិនមានបច្ច័យ រមែងសៅហ្មងឯង រមែងសោយសុខ និងទុក្ខឯង" នេះជាការពិត ពាន្ធដែលយើងសម្លាប់ល្អហើយ ទោសអ្វីក្នុងសេចក្តីនេះនឹងគប្បីមានដល់យើង ។ បទថា **វិជានិយ "ដឹង"** សេចក្តីថា សម្ងាញ់ បើលោកគប្បីដឹងដល់កំហុសនៃវាទៈរបស់ខ្លួនហើយ លោកមិនគប្បីនឹងតិះដៀលយើងឡើយ ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះថា វាទៈរបស់លោកដ៏ចម្រើនជាដូច្នោះ ព្រោះដូច្នោះ លោកគប្បីសរសើរយើងថា "លោកនេះធ្វើ

តាមវាទ:របស់យើង" តែកាលមិនដឹងវាទ:របស់ខ្លួន ក៏រមែងមកតិះដៀលយើង ។

ព្រះមហាសត្វគ្រប់សង្កត់អាមាត្យនោះ បានធ្វើឲ្យជាមនុស្សអស់បជិកាណ ដោយប្រការដូច្នេះ ។ សូម្បីព្រះរាជាអង្គនោះទ្រង់ក៏អៀនអន់ក្នុងកណ្ណាលបរិស័ទ ប្រថាប់អង្គុយជាក់ព្រះសូរងចុះ ។ សូម្បីព្រះមហាសត្ត ទម្លាយវាទ:នៃអហេតុកវាទីអាមាត្យនោះហើយ ទើបហៅឥស្សរករណវាទីអាមាត្យមក ហើយសួរថា "លោកដ៏មានអាយុ លោកសើចយើងព្រោះហេតុអ្វី បើថា លោកសម្តែងវាទ: ដោយសារ:ថា វត្ថុទាំងពួងព្រះជាម្ចាស់ជាអ្នកសាង?" ហើយបានពោលជាគាថាថា

[៥៨] ឥស្សរោ សព្វលោកស្ស សចេ កប្បេតិ ជីវិតំ
ឥទ្ធី ព្យសនការាវ ពា្ហ កម្មំ កល្យាណបាបកំ
និទ្ទេសការី បុរិសោ ឥស្សរោ តេន លិម្ពតិ ។

បើព្រះជាអ្នកសាងជីវិត សាងសេចក្ដីសម្រេច សាងនូវសេចក្ដីវិនាស សាងកម្មល្អ និងកម្មអាក្រក់ ឲ្យដល់លោកទាំងអស់សោត បុរសអ្នកធ្វើតាមពាក្យរបស់ព្រះ ក៏រមែងធ្វើបាបបាន ព្រះក៏រមែងប្រឡាក់ដោយបាបនោះឯង ។

សោ ចេ អត្តា ច ធម្មោ ច កល្យាណោ ន ច បាបកោ
ភោតោ ចេ វចនំ សច្ចំ សុហតោ ឋានេ មយា ។

បើសេចក្ដីនៃការសិតរបស់លោកនោះ មានអត្ត មានធម្ម និងជាពាក្យល្អ មិនអាក្រក់ បើពាក្យរបស់លោកជាការពិត ស្វាក៏ជាការដែលយើងសម្លាប់ល្អហើយ ។

អត្តនោ ចេ ហិ ឋានស្ស អបរាធំ វិជានិយ
ន មំ ត្វំ ឧបហេយ្យាសិ ភោតោ ឋានេ ហិ តាទិសោ ។

បើអ្នកដឹងនូវកំហុសនៃវាទៈរបស់ខ្លួន ក៏មិនគប្បីនឹងតិះ-ដៀលយើងឡើយ ព្រោះថា វាទៈរបស់អ្នកជាដូច្នោះ ។

បណ្តាបទទាំងនោះ បទថា ***ករេយ្យតិ ជីវិតំ "សាងជីវិត"*** *គឺ បើថា ព្រះព្រហ្ម ឬព្រះជាម្ចាស់អង្គណាៗ នឹងចាត់ចែងជីវិតដល់ មនុស្សលោកទាំងអស់យ៉ាងនេះថា "លោកចូរចិញ្ចឹមជីវិតដោយការ ក្ងរស្រែ លោកចូរចញ្ចឹមជីវិតដោយការចិញ្ចឹមគោ" ជាដើម ។ បទ ថា* ***ឥទ្ធិ ព្យសនការញ្ច "សាងសេចក្ដីសម្រេច សាងសេចក្ដីវិនាស"*** *អធិប្បាយថា បើព្រះជាម្ចាស់នោះឯងសាង គឺ ធ្វើសេចក្ដីសម្រេច ប្រការផ្សេងៗ មានកាពជាធំជាដើម សាងសេចក្ដីវិនាសនៃពពួក ញាតិជាដើម និងសាងកម្មណ្ដ កម្មអាក្រក់ដ៏សេសទាំងអស់ ។ បទ ថា* ***និទ្ទេសការី "អ្នកធ្វើតាមពាក្យរបស់ព្រះជាម្ចាស់"*** *សេចក្ដីថា បើថា បុរសណាមួយដ៏សេស ធ្វើតាមពាក្យបញ្ជា គឺ ពាក្យបង្គាប់ របស់ព្រះជាម្ចាស់នោះឯង បើដូច្នោះ នរណាៗ ក៏រមែងធ្វើបាបបាន ព្រះជាម្ចាស់ប៉ុណ្ណោះរមែងទទួលនូវបាបនោះឯង ព្រោះព្រះជាម្ចាស់ ជាអ្នកបង្គាប់ឲ្យធ្វើបាបនោះ ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យ*

មុននោះឯង ។ មួយទៀត គប្បីជ្រាបសេចក្តីក្នុងទីទាំងអស់ ដូចក្នុងទីនេះចុះ ។

ព្រះមហាសត្វគ្រាទម្ងាយឥសរ្យកវណាវ:ចាន ដោយឥសរ្យ-វកវណ:នោះឯង ដូចបុគ្គលយកមែកស្វាយថ្ពក់ផ្ទៃស្វាយឲ្យធ្លាក់ចុះ ដោយប្រការដូច្នេះហើយ ទើបហៅបុព្វេកតវាទីអាមាត្យមក ហើយពោលថា "លោកដ៏មានអាយុ លោកសើចក្នុងយើងព្រោះហេតុអ្វី បើលោកសម្គាល់ថា បុព្វេកតវាទជាការពិត?" ហើយបានពោលជាគាថាថា

[៦០] *សចេ បុព្វេកតហេតុ សុខទុក្ខំ និគচ্ছតិ*
ចោរវណកំ កតំ ចាបំ តមេសោ មុញ្ចតេ ឥណំ
ចោរវណកឥណមោក្ខោ ក្ងិធ ចាបេន លិម្ប្ពតិ ។

បើរមែងចូលដល់សេចក្តីសុខ និងសេចក្តីទុក្ខ ព្រោះហេតុនៃកម្មដែលធ្វើទុកហើយក្នុងកាលមុន ចាបជារបស់ចាស់ដែល

គេធ្វើទុកហើយ គេរមែងដោះបំណុលនោះបាន ផ្ទុយវិញចុតចាក
បំណុលចាស់មានហើយ នរណាហ្ន៎ក្នុងលោកនេះនឹងប្រឡាក់
ដោយបាប ។

សោ ចេ អត្ថោ ច ធម្មោ ច កល្យាណោ ន ច បាបកោ
ភោតោ ចេ វចនំ សច្ចំ សុហតោ ជានតោ មយា ។

បើសេចក្តីនៃកាសិតរបស់លោកនោះ មានអត្ថ មានធម៌
និងជាពាក្យល្អ មិនអាក្រក់ បើពាក្យរបស់លោកជាការពិត
ស្វាក៏ជាការដែលយើងសម្លាប់ល្អហើយ ។

អត្ថនោ ចេ ហិ ជានាសិ អបរាធំ វិជានិយ
ន មំ ត្វំ ឧរហេយ្យាសិ ភោតោ ជានតោ ហិ តាទិសោ ។

បើអ្នកដឹងកំហុសនៃកាន:របស់ខ្លួន ក៏មិនគប្បីនឹងតិះដៀល
យើងទ្បើយ ព្រោះថា ជាន:របស់អ្នកជាដូច្នោះ ។

បណ្តាបទទាំងនោះ បទថា បុព្វេកតហេតុ "ព្រោះហេតុនៃ

កម្មដែលធ្វើទុកហើយក្នុងកាលមុន *"* *បានដល់ ព្រោះតែហេតុដែលបានធ្វើកម្មទុកក្នុងកាលមុន គឺ ព្រោះការធ្វើកម្មដែលខ្លួនបានធ្វើទុកហើយក្នុងភពមុនដោយពិត ។ បទថា* ***តមេសោ មុញ្ចតេ ឥណំ*** *"* ***គេរមែងប្រឡាក់បំណុលនោះបាន*** *"* *សេចក្ដីថា បុគ្គលណាដល់នូវសេចក្ដីទុក្ខ ព្រោះការត្រូវសម្ងាប់ និងចងជាដើម បើបុគ្គលនោះប្រឡាក់បំណុល គឺ បាបចាស់ដែលគេបានធ្វើទុកហើយក្នុងវេលានេះ បើដូច្នោះ នេះក៏ជាការផុតចាកបំណុលចាស់របស់គេ ព្រោះថា យើងជាស្វា ត្រូវស្វាមួយនោះដែលជាបរិព្វាជកអំពីមុនសម្ងាប់ស៊ីហើយ បរិព្វាជកនោះត្រឡប់មកជាស្វាក្នុងអត្តភាពនេះ ក៏នឹងត្រូវយើងដែលត្រឡប់មកជាបរិព្វាជកសម្ងាប់ស៊ីវិញដូចគ្នា នរណាហ្ន៎ ក្នុងលោកនេះនឹងប្រឡាក់ដោយបាប ។*

ព្រះមហាសត្ត គ្រាទម្លាយវាទ:របស់បុព្វេកតវាទអាមាត្យនោះដោយប្រការដូច្នេះហើយ ទើបហៅឧច្ចទាទីអាមាត្យមកចំពោះមុខ

ហើយពោលគំរាមថា "លោកមានអាយុ លោកពោលពាក្យជាដើម ថា ទានដែលបុគ្គលឲ្យហើយមិនមានផល សម្គាល់ថា សត្វទាំង ឡាយរមែងជាច់សូន្យក្នុងលោកនេះប៉ុណ្ណោះ ដែលឈ្មោះថា សត្ត ទៅកាន់បរលោកមិនមានឡើយ លោកសើចនឹងយើងព្រោះហេតុ អ្វី?" ហើយពោលជាគាថាថា

[៦១] ចតុន្នំ យេ រុបាទាយ រូបំ សម្ភោតិ ជាណិនំ
យតោ ច រូបំ សម្ភោតិ តត្ថ ជ្ជានុ ឧបគច្ឆតិ ។

រូបរបស់សត្វទាំងឡាយ រមែងអាស្រ័យធាតុ ៤ ប៉ុណ្ណោះ កើតឡើង ក៏រូបកើតអំពីវត្ថុណា រមែងចូលដល់វត្ថុនោះដូច ដើម ។

ឥធេវ ជីវតិ ជីវោ បេច្ច បេច្ច ជ្ជនសាតិ
ឧច្ឆិជ្ជតិ អយំ លោកោ យេ ពាលា យេ ច បណ្ឌិតា
ឧច្ឆិជ្ជិមានេ លោកស្មិ ក្ជិធ ជ្ជាបេន លិម្ជតិ ។

ជីវៈរមែងរស់នៅតែក្នុងលោកនេះប៉ុណ្ណោះ លះទៅហើយ ក៏រមែងវិនាសក្នុងលោកខាងមុខ លោកនេះជាច់សូន្យ កាលលោកជាច់សូន្យយ៉ាងនេះ ជនពួកណាទាំងជាពាល ជាបណ្ឌិត ជនទាំងនោះរមែងជាច់សូន្យទាំងអស់ នរណាហ្ន៎ក្នុងលោកនេះ នឹងប្រឡាក់បាប ។

សោ ចេ អត្ថោ ច ធម្មោ ច កល្យាណោ ន ច ចាបកោ
ភោតោ ចេ វចនំ សច្ចំ សុហតោ ជានតោ មយា ។

បើសេចក្តីនៃកាសិតរបស់លោកនោះ មានអត្ថ មានធម្ម និងជាពាក្យស្អាត មិនអាក្រក់ បើពាក្យលោកជាការពិត ស្វាក៏ជាការដែលយើងសម្ងាប់ល្អហើយ ។

អត្ថនោ ចេ ហិ ជានាសិ អបរាធំ វិជានយ
ន មំ ត្វំ ឧរហេយ្យាសិ ភោតោ ជានតោ ហិ តាទិសោ ។

បើលោកដឹងកំហុសនៃកាន:របស់ខ្លួន ក៏នឹងមិនគប្បីតិះ-

ដៀលយើងឡើយ ព្រោះថា ភ្នែករបស់លោកយ៉ាងនេះ ។

បណ្តាបទទាំងនោះ បទថា **ចតុន្នំ** *"ធាតុ ៤" បានដល់ ភូតរូបទាំង ៤ មានបឋវីធាតុជាដើម ។ បទថា* **រូបំ** *"រូប" បានដល់ រូបក្ខន្ធ ។ បទថា* **តត្ថេវ** *"ក្នុងវត្ថុនោះដូចដើម" សេចក្តីថា រូបនោះរមែងកើតឡើងអំពីវត្ថុណា សូម្បីក្នុងវេលារលត់ ក៏រមែងត្រឡប់ទៅជាវត្ថុនោះដូចដើម ។ ព្រះមហាសត្វធ្វើការយើញរបស់ខ្ចេទវាទីអាមាត្យនោះឲ្យតាំងឡើងយ៉ាងនេះថា បុរសអ្នកប្រកបដោយមហាភូតរូបទាំង ៤ នេះ ធ្វើកាលកិរិយាក្នុងវេលាណា ដីក៏ត្រឡប់ក្លាយទៅរួមគ្នាជាមួយក្រុមដី... ទឹក... ភ្លើង... ខ្យល់ក៏ត្រឡប់ក្លាយចូលទៅរួមជាមួយក្រុមខ្យល់ ឥន្ទ្រិយទាំងឡាយក៏ចូលដល់សភាពជាអាកាស បុរសទាំងឡាយអ្នកមានកៅអីវែងជាទី ៥ (គ្រែស្នែងសព ៤ នាក់) រមែងសែងយកសាកសពដែលស្លាប់ទៅស្នាមជើងរមែងប្រាកដរហូតដល់ធ្នើង ដែលមានពណ៌ដូចសត្វព្រាប*

មានហើយ គ្រឿងបូជាមានផេះធ្ងន់ជាទីបំផុត ទានដែលពួកមនុស្ស
បញ្ញត្តិទុក បុគ្គលពួកណាមួយដែលពោលនូវវាទៈថា មាន ការ
ពោលរបស់បុគ្គលទាំងនោះទេ និងកុហក ទ័ងជាពាល ឬជាបណ្ឌិត
ក្តី កាលកាយនេះបែកធ្លាយ ក៏រមែងជាច់សូន្យ គឺ វិនាស បានដល់
មិនប្រាកដខាងមុខអំពីស្លាប់ទៅ ។ បទថា **ឥធេវ "ក្នុងលោកនេះ
ប៉ុណ្ណោះ"** សេចក្តីថា ជីវៈរមែងរស់នៅក្នុងលោកនេះប៉ុណ្ណោះ ។
បទថា **បេច្ច បេច្ច វិនស្សតិ "លះទៅហើយ រមែងវិនាសក្នុងលោក
ខាងមុខ"** សេចក្តីថា សត្វដែលកើតក្នុងបរលោក ក៏មិនបានត្រឡប់
មកក្នុងលោកនេះទៀតដោយអំណាចនៃគតិ រមែងវិនាសជាច់សូន្យ
ទៅក្នុងលោកខាងមុខនោះឯង កាលលោកជាច់សូន្យដូច្នេះ នរណា
ហ្ន៎ ទ័ងប្រឡាក់ដោយបាបក្នុងលោកនេះ ។

ព្រះមហាសត្ត គ្រាទម្លាយវាទៈរបស់ខច្ចទវាទីអាមាត្យនោះ
ដោយប្រការនេះហើយ ទើបហៅខត្តវិជ្ជវាទីអាមាត្យមក ហើយក៏

ពោលថា "លោកមានអាយុ លោកត្រាច់លើកលទ្ធិនេះថា បុគ្គលគួរសម្រាប់សូម្បីមាតាបិតា ដើម្បីប្រយោជន៍ខ្លួន លោកសើចក្នុងយើងព្រោះហេតុអ្វី?" ហើយពោលជាគាថាថា

[៦២] *អាហុ ១ត្តវិធា[1] លោកេ ពាលា បណ្ឌិតមានិនោ*
មាតរំ បិតរំ ហញ្ញេ អថោ ជេដ្ឋំបិ ភាតរំ
ហានេយ្យ បុត្តទារេ ច អត្តា ចេ តាទិសោ សិយា ។

អាចារ្យទាំងឡាយអ្នកមានវាទៈថា ការសម្រាប់មាតាបិតាជាកិច្ចគួរធ្វើ បុគ្គលពាលដែលសម្គាល់ខ្លួនថាជាបណ្ឌិត ចានពោលទុកហើយក្នុងលោកនេះថា បុគ្គលគប្បីសម្រាប់មាតាបិតា គប្បីសម្រាប់បង សម្រាប់ប្អូន សម្រាប់បុត្ត និងភរិយា ប្រសិនបើប្រយោជន៍ដូច្នោះគប្បីមាន ។

បណ្តាបទទាំងនោះ បទថា **ភ១ត្តវិធា[2]** *"អាចារ្យទាំងឡាយអ្នក*

១.ម. អាហុ ១ត្តវិធ ។ ២. ក្នុងបិដកមិនមាន តែបាឬ:ចានកែសេចក្តីហើយ ។

មានវាទ:ថា ការសម្ងាប់មាតាបិតាជាកិច្ចដែលគួរធ្វើ" បានដល់ អ្នកមានការយល់ឃើញថា ការសម្ងាប់មាតាបិតាជាវត្ថុគួរធ្វើ ។ មួយទៀត ចាប:ក៏ថា **ខត្តវិជ្ជា** នយដូចគ្នា ។ បទថា **ខត្តវិជ្ជា** នេះជាឈ្មោះរបស់អាចារ្យអ្នកមានការយល់ថា ការសម្ងាប់មាតាបិតាជាវត្ថុគួរធ្វើ ។ បទថា **ពាលា បណ្ឌិតមានិនោ "បុគ្គលពាលដែលសម្គាល់ថាជាបណ្ឌិត"** សេចក្ដីថា ជនទាំងឡាយដែលជាពាល ក៏សម្គាល់ហើយថា "ពួកយើងជាបណ្ឌិត នឹងប្រកាសវាទ:របស់ខ្លួនដែលជាបណ្ឌិត" ជាអ្នកមានការសម្គាល់ខ្លួនថាជាបណ្ឌិត ទើបបានពោលយ៉ាងនេះ ។ បទថា **អត្ថោ ចេ "បើប្រយោជន៍មានដូច្នោះ"** អាចារ្យពោលថា "បើប្រយោជន៍តិចតួចមានសភាពបែបនោះ នឹងគប្បីមានដល់ខ្លួនសោត បុគ្គលមិនគប្បីរៀនទូវអ្វីៗ ឡើយ គប្បីសម្ងាប់បានទាំងអស់" សូម្បីអ្នកក៏ជាបុគ្គលម្នាក់ក្នុងបណ្ដាអាចារ្យដែលមានវាទ:ដូច្នោះ ។

ព្រះមហាសត្ត គ្រាសម្តែងលទ្ធិរបស់ខត្តវិជ្ជាទីអាមាត្យនោះ ឲ្យតាំងឡើងយ៉ាងនេះហើយ កាលនឹងប្រកាសលទ្ធិរបស់ខ្លួន ទើបពោលជាគាថាថា

[៦៣] យស្ស រុក្ខស្ស ឆាយាយ និសីទេយ្យ សយេយ្យ វា
ន តស្ស សាខំ ភញ្ជេយ្យ មិត្តទុព្ភោ ហិ បាបកោ ។

បុគ្គលគប្បីអង្គុយ ឬដេកក្រោមម្លប់ឈើណា មិនគួរកាច់នូវមែករបស់ដើមឈើនោះ ព្រោះថា អ្នកប្រទូសរាយមិត្តជាបុគ្គលថោកទាប ។

អថ អត្ថ សមុប្បន្ន សមូលមបិ អព្ភុហ
អត្ថោ មេ សម្ភលេនាបិ សុហតោ ឱនវោ មយា ។

ប្រសិនបើកាលមានសេចក្ដីត្រូវការកើតឡើង បុគ្គលក៏គួរដកសូម្បីទាំងឫស សូម្បីប្រយោជន៍ដែលនឹងមានចំពោះខ្លួនច្រើន ស្ងាត់ជាការដែលយើងសម្លាប់ល្អហើយ ។

សោ ច អត្ថো ច ធម្មោ ច កល្យាណោ ន ច ១ បាបកោ

*ភោតោ ច ១ ១ ១

អាក្រក់ តែលោកពោលយ៉ាងនេះថា "កាលបើមានសេចក្ដីត្រូវការ កើតឡើង ក៏ឲ្យដកទៅសូម្បីទាំងឫស" ឯយើងក៏មានសេចក្ដីត្រូវការស្ដៀង ព្រោះដូច្នោះ សូម្បីថាយើងសម្ងាប់ពានរនេះហើយ ក៏ប្រយោជន៍គប្បីមានដល់យើងច្រើនដោយពិត ដូច្នោះ ពានរក៏ជាការដែលយើងសម្ងាប់ហើយយ៉ាងល្អ ។

ព្រះមហាសត្ត បានទម្លាយវាទ:របស់ខត្តវិជ្ជាទីអាមាត្យនោះ យ៉ាងនេះហើយ កាលអាមាត្យទាំង ៥ នាក់អស់បជិកាណ អង្គុយស្ងៀមហើយ ទើបហៅព្រះរាជាមក ហើយទូលឲ្យជ្រាបថា "មហាបពិត្រ ព្រះអង្គរមែងនាំយកនូវមហាចោរប្លន់ដែនទាំង ៥ នាក់នេះ តាមស្ដេចទៅ គួរខ្វាចចិត្តណាស់ ព្រះអង្គជាមនុស្សល្ងង់ ព្រោះថា បុគ្គលដល់នូវទុក្ខដ៏ធំក្រៃលែងទាំងក្នុងភពនេះ និងភពខាងមុខ ព្រោះតែការស្និទ្ធស្នាលជាមួយពួកបុគ្គលពាលបែបនេះ" កាលនឹងសម្ដែងធម៌ដល់ព្រះរាជា ទើបពោលជាគាថាថា

[៦៤] *អហេតុវាទោ បុរិសោ យោ ច ឥស្សរកុត្តិកោ*

បុព្ពេកតី ច ខរេ ច ទ្ធី យោ ច ខត្តវិជ្ជ ន ភ ។

បុរសអ្នកមានវាទៈថារកហេតុមិនបាន ១ អ្នកមានវាទៈថា ព្រះជាម្ចាស់សាងលោក ១ អ្នកមានវាទៈថាសុខ និងទុក្ខកើតព្រោះកម្មដែលធ្វើមកអំពីមុន ១ អ្នកមានវាទៈថាជាចំ់សួន្ស ១ អ្នកមានវាទៈថាសម្ចាប់មាតាបិតាជាកិច្ចគួរធ្វើ ១ ។

ឯតេ អសប្ប៊ុរិសា លោកេ ពាលា បណ្ឌិតមានិនោ

ការេយ្ យ តាទិសោ ជ្ជ ចាបំ អ ថ អញ្ញ ម្ប ី ការ យ

អសប្ប៊ុរិសសំ ស គ្ គ ា ទ ុ ក ្ ខ ន ្ ត ា ក ជ ុ ក ុ ទ ្ (យ ោ ។

ជនទាំង ៥ នាក់នេះ ជាអសប្ប៊ុរស ជាបុគ្គលពាល តែមានសេចក្ដីសម្គាល់ថាខ្លួនជាបណ្ឌិតក្នុងលោក បុគ្គលដូច្នោះ គប្ប៊ីធ្វើបាបដោយខ្លួនឯងក៏បាន គប្ប៊ីដឹកនាំសូម្ប៊ីអ្នកដទៃឲ្យធ្វើក៏បាន ការស្ថិទ្ធស្ថាលជាមួយអសប្ប៊ុរស ជាការអាក្រក់

ក្រៃលែង មានផលដ៏ក្តៅផ្ទ្រាជាកម្រៃ ។

បណ្តាបទទាំងនោះ បទថា **តាទិសោ** "**បុគ្គលដូច្នោះ**" នយ ថា មហាបពិត្រ បុរសដូចគ្នានឹងបុរសដែលមានទិដ្ឋិ និងគតិទាំង ៥ នាក់នេះ គប្បីធ្វើបាបសូម្បីដោយខ្លួនឯងក៏បាន គប្បីធ្វើការបបួលអ្នកដទៃដែលជឿស្តាប់ពាក្យរបស់គេឲ្យធ្វើបាបក៏បាន ។ បទថា **ទុ-ក្ខដោ**[1] "**ជាបុគ្គលអាក្រក់**" សេចក្តីថា ការស្និទ្ធស្នាលជាមួយនឹងអសប្បុរសទាំងឡាយបែបនេះ រមែងជាការអាក្រក់ និងមានសេចក្តីក្តៅក្រហាយជាកម្រៃ ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។ ដើម្បីនឹងប្រកាសសេចក្តីនេះឲ្យជាក់ច្បាស់ គប្បីនាំព្រះសូត្រជាដើមថា "ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយណាមួយកើតឡើង ភ័យទាំងអស់នោះរមែងកើតឡើងអំពីបុគ្គលពាល" ដូច្នេះមកសម្តែង ។ ឬគប្បីនាំសេចក្តីនៃរឿងគោធជាតក សញ្ជីវជាតក និងអកិត្តិជាកត

ឋិដក. ១. ទុក្ខន្តោ កដុកុ ទ្រយោ ។

ជាដើម មកសម្តែងក៏ចាន ។

ឥឡូវនេះ ព្រះមហាសត្វកាលនឹងបន្ថែមព្រះធម្មទេសនាឲ្យ ចម្រើន ដោយបំណងសម្តែងដល់សេចក្តីឧបមា ទើបពោលគាថាថា

[៦៥] ខរញ្ជូរបេន ពកាសុ បុព្ពេ
អសង្ខិតោ អជយូបំ ខរបេតិ
ហន្ត្វា ខរណី អជិយំ អជញ្ចេ
ហន្ត្វា[1] សយិត្វា យេន កាមំ បលេតិ ។

ក្នុងគ្រាមុនឆ្កែព្រៃ[1] មួយក្បាលមានរូបដូចសត្វពពែ ពួកពពែមិនរង្គៀស ចានចូលទៅកាន់ហ្វូងពពែ សម្លាប់ពពែទាំងញីទាំងឈ្មោល គ្រាស៊ីហើយ ក៏គេចទៅដោយអាការយ៉ាងណា

តថាវិធេកេ សមណព្រាហ្មណាសេ

---

១. ចិដក. ប្រែថា សត្វកុក (ពកាសុ) ។

ឆទនំ កត្វា វញ្ចយន្តិ មនុស្ស

អនាសកា ថណ្ឌិលសេយ្យកា ច

រជាជលុ ខុក្ខជិកប្ប ធានំ

បរិយាយកត្តញ្ច អបានកត្តា

ចាចាចារ អរហន្ត្ថ ១

សមណព្រាហ្មណ៍ពួកខ្លះ ក៏មានអាការដូចយ៉ាងនោះ ធ្វើការបិទបាំងខ្លួន ត្រាប់ក្បាកពួកមនុស្ស ពួកខ្លះប្រព្រឹត្តមិនស៊ីអាហារ ពួកខ្លះដេកលើផែនដី ពួកខ្លះធ្វើកិរិយាលាបធូលីលើខ្លួន ពួកខ្លះតាំងសេចក្ដីព្យាយាមដើរច្រហោង ពួកខ្លះរៀរស៊ីអាហារមួយពេល ពួកខ្លះមិនផឹកទឹក ជាបុគ្គលមានអាចារៈដ៏ថោកទាប ត្រាប់និយាយអួតអាងថាជាព្រះអរហន្ត ១

ឯតេ អសប្ប៊ុរិសា លោកេ ពាលា បណ្ឌិតមានិនោ

ការេយ្ យ តាទិសោ ជ្ជ ជ្ជ អ ជ្ជ ការ

ការ

អសប្ប៎ុរិសសំសគ្គោ ទុក្ខន្ត្ថោ កដុកុ ទ្ទ្រយោ ។

បុគ្គលទាំងនោះជាអសប្ប៎ុរសក្នុងលោក ជាបុគ្គលពាលតែមានសេចក្ដីសម្គាល់ថា ខ្លួនជាបណ្ឌិត បុគ្គលដូច្នោះគប្ប៎ីធ្វើបាបខ្លួនឯងក៏បាន គប្ប៎ីបបួលសូម្ប៎ីអ្នកដទៃឲ្យធ្វើក៏បាន ការច្រឡូកច្រឡំជាមួយអសប្ប៎ុរសជាសេចក្ដីអាក្រក់ មានផលក្ដៅក្រហាយជាកម្រៃ ។

យមាហុ នត្ថិ ១ រិយន្ត្ថិ ហេតុញ្ច អបវ ១ ទន្ត្ថិ យ

*ឧ ១ ១ ១

ការយ្យ តាទិសោ ជាបំ អថោ អញ្ញម្ប៎ ការយ

អសប្ប៎ុរិសសំសគ្គោ ទុក្ខន្ត្ថោ កដុកុ ទ្ទ្រយោ ។

បុគ្គលទាំងនេះជាអសប្ប៎ុរស ជាបុគ្គលពាល តែមានការ

សម្គាល់ថាខ្លួនជាបណ្ឌិត បុគ្គលដូច្នោះគប្ប៎ីធ្វើជាបដោយខ្លួន

ឯងក៏ជាន គប្ប៎ីដឹកនាំអ្នកដទៃឲ្យធ្វើជាបក៏ជាន ការនៅច្រឡូក

ច្រឡំដោយអសប្ប៎ុរសជាសេចក្ដីអាក្រក់ មានផលក្ដៅក្រហាយ

ជាកម្រៃ ។

សចេ ហិ ១ រ១យ១ នាស្ស ១ ១ ១ ១ ១ ១

*ន ១ ១ ១ ១ ១

តស្មា យន្តានិ ការេតិ រាជា ករតិ វុឌ្ឍកី ។

តែព្រោះសេចក្ដីព្យាយាមមាន រីឯកម្មល្អកម្មអាក្រក់មាន ដូច្នោះ ពួកជាងទើបធ្វើយន្តទាំងឡាយឲ្យសម្រេច ព្រះរាជាទ្រង់ទើបចិញ្ចឹមពួកជាងឈើ ។

យទិ វស្សសតំ ទេវោ ន វស្សេ ន ហិមំ បតេ

ឧច្ចិជ្ជេយ្យ អយំ លោកោ វិនស្សេយ្យ អយំ ជនោ ។

បើក្បៀងមិនធ្លាក់ ទឹកសន្សើមមិនធ្លាក់ ១០០ ឆ្នាំ លោកនេះក៏គប្បីវិនាសសូន្យ ពួកសត្វក៏គប្បីវិនាស ។

យស្មា ច វស្សតី ទេវោ ហិមញ្ចានុបុ្ផសីយតិ

តស្មា សស្សានិ បច្ចន្តិ រដ្ឋញ្ច ជ្ជាលយតេ ចិរំ ។

តែព្រោះក្បៀងក៏ធ្លាក់ ទឹកសន្សើមក៏ជ្រោះព្រំ ដូច្នោះ ស្រូវទើបទុំ និងចិញ្ចឹមអ្នកដែនឲ្យរស់នៅបានយូរ ។

គវញ្ច តរមានានំ ជិម្ហំ គច្ឆតិ ឫជ្ជុ ។

សព្វា តា ជិម្ហំ គច្ឆន្តិ នេត្ថ ជិម្ហំ គតេ សតិ ។

កាលបើពួកគោហែលឆ្លងត្រើយទៅ គោមេហ្វូងដែលនាំ
ទៅវៀច កាលគោមេហ្វូងហែលទៅវៀច គោទាំងអស់នោះ
ក៏រមែងហែលទៅវៀច យ៉ាងណា ។

ឯវមេវ មនុស្សេសុ យោ ហោតិ សេដ្ឋសម្មតោ
សោ ចេ អធម្មំ ចរតិ បគេវ ឥតរា បជា
សព្វំ រដ្ឋំ ទុក្ខំ សេតិ រាជា ចេ ហោតិ អធម្មិកោ ។

ក្នុងពួកមនុស្សក៏ដូច្នោះដូចគ្នា ជនណាបានទទួលការសរ-
សើរថា ជាអ្នកប្រសើរបំផុត បើបុគ្គលនោះប្រព្រឹត្តមិនមែន
ជាធម៌ ទីឯចាំបាច់ពោលថ្វីដល់ប្រជាជនក្រៅអំពីនេះ ។ អ្នក
ដែនទាំងពួងរមែងនៅជាទុក្ខ បើព្រះរាជាមិនតាំងនៅក្នុងធម៌ ។

គវេ ភ្ជ្ជ តរមានានំ ឧជុំ គច្ឆតិ ឧក្ខ្ជ្ជ
សព្វា តា ឧជុំ គច្ឆន្តិ នេត្ថ ឧជុំ គតេ សតិ ។

កាលបើហ្វូងគោហែលឆ្លងទៅហើយ គោមេហ្វូងហែលទៅ

ត្រង់ កាលមានគោមេហ្វូងហែលទៅត្រង់ គោទាំងអស់នោះ

ក៏រមែងហែលទៅត្រង់ យ៉ាងណា ។

ឯវមេវ មនុស្សេសុ យោ ហោតិ សេដ្ឋសម្មតោ

សោ ចេបិ ធម្មំ ចរតិ បគេវ ឥតរា បជា

សព្វំ រដ្ឋំ សុខំ សេតិ រាជា ចេ ហោតិ ធម្មិកោ ។

ក្នុងពួកមនុស្សក៏ដូច្នោះដូចគ្នា បុគ្គលណាបានទទួលការ

សរសើរថា ជាអ្នកដ៏ប្រសើរបំផុត បើបុគ្គលនោះប្រព្រឹត្តជា

ធម៌ ចាំបាច់ពោលថ្វីដល់ប្រជាជនក្រៅអំពីនេះ អ្នកដែនទាំង

អស់រមែងនៅជាសុខ បើព្រះរាជាតាំងនៅក្នុងធម៌ ។

មហារុក្ខស្ស ផលិនោ អាមំ ឆិន្ទតិ យោ ផលំ

*រសញ្ញូ ន ជានាតិ ពីជញ្ញូ ១ ១ ១

រមែងមិនដឹងនូវរសនៃផ្លែឈើនោះ ទាំងពួជនៃដើមឈើនោះ ក៏រមែងវិនាស ។

មហារុក្ខូបមំ រដ្ឋំ អធម្មេន (យោ) បសាសតិ
រសញ្ញូ ន ជានាតិ រដ្ឋញ្ញូ វិនស្សតិ ។

រដ្ឋប្រៀបដូចជាដើមឈើធំ ព្រះរាជាណាទ្រង់គ្រប់គ្រងមិនមែនជាធម៌ ព្រះរាជានោះរមែងមិនស្គាល់រសនៃរដ្ឋនោះ និងរដ្ឋរបស់ព្រះរាជានោះក៏រមែងវិនាសទៅ ។

មហារុក្ខស្ស ផលិនោ បក្កំ ឆិន្ទតិ យោ ផលំ
រសញ្ញូ វិជានាតិ ពីជញ្ញូ ន នស្សតិ ។

កាលដើមឈើធំមានផ្លែ អ្នកណាបេះយកផ្លែទុំៗ មក អ្នកនោះរមែងដឹងនូវរសនៃផ្លែឈើនោះ ទាំងពួជនៃដើមឈើនោះ ក៏មិនវិនាស ។

មហារុក្ខូបមំ រដ្ឋំ ធម្មេន យោ បសាសតិ

រសញ្ញូ វិជានាតិ រដ្ឋញ្ញូ ន ន ន ។

រដ្ឋក៏ប្រៀបដូចជាដើមឈើធំ ព្រះរាជាណាទ្រង់គ្រប់គ្រងដោយធម៌ ព្រះរាជានោះទ្រង់ជ្រាបនូវរសនៃរដ្ឋនោះ និងរដ្ឋរបស់ព្រះរាជាអង្គនោះក៏មិនវិនាស ។

យោ ច រាជា ជនបទំ អធម្មេន បសាសតិ

សញ្ញូ ធីកិ សោ រាជា ទ្ធ ហោតិ ខត្តិយោ ។

មួយទៀត ខត្តិយរាជអង្គណាគ្រប់គ្រងជនបទមិនដោយធម៌ ខត្តិយរាជព្រះអង្គនោះទ្រង់រមែងឃ្លាតចាកព្រះនិសជ្ជទាំងពួង ។

តថេ ន ន ហ ។   យ ត ក ។ ។

*ជ ទ ន ត ។ ។ ។

អង្គនោះរមែងឃ្លាតចាកនូវចំណែកនៃព្រះរាជទ្រព្យ ។

ឧហារវរេ ខ្ត្ត ញ្ញូ សង្ខ្ហាមេ កតនិស្សរេ

ឧសរ្ជិតេ ហ៎ីសយំ រាជា ស ពលេន វិរុជ្ឌតិ ។

ព្រះរាជាអង្គណាទ្រង់បៀតបៀនព្រាន អ្នកដ៏ងរ ខ្ត្តនៃការ ប្រហារដ៏ល្អ និងបៀតបៀនទាហានអ្នកពេញចិត្តក្នុងសង្គ្រាម បៀតបៀនអាមាត្យអ្នករុងរឿង ព្រះរាជាអង្គនោះ រមែងឃ្លាត ចាកពលនិកាយ ។

តថេវ ឥសយោ ហ៎ីសំ សំយមេ ព្រហ្មចារិយ

អធម្មចារី ខ្ត្តិយោ ១សោ សគ្គេន វិរុជ្ឌតិ ។

មួយទៀត ក្សត្រដែលមិនប្រព្រឹត្តធម៌ បៀតបៀនបព្វជិត អ្នកស្វែងរកគុណ អ្នកសង្រ្ទម ប្រព្រឹត្តព្រហ្មចរិយធម៌ ក្សត្រ អង្គនោះ រមែងឃ្លាតចាកសួគ៌ ។

យោ ច រាជា អធម្មជ្ជោ ករិយំ ហន្តិ អទូសកំ

លុទ្ធំ ឋសវតេ ឋានំ បុត្តេហិ ច វិរុជ្ឌតិ ។

មួយទៀត ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ សម្លាប់ព្រះជាយាជាអ្នកមិនប្រទូស្ត រមែងបានប្រសព្ធនឹងឋានៈដ៏អាក្រក់ និងរមែងឃ្លាតចាកព្រះរាជបុត្ត១ាំងឡាយ ។

ធម្មំ ចរេ ជានបទេ នេគមេសុ ពលេសុ ច

ឥសយោ ច ន ហ៊ីសេយ្យ បុត្តទារេ សមញ្ជារេ ។

ព្រះរាជាគប្បីប្រព្រឹត្តធម៌ក្នុងអ្នកជនបទ អ្នកនិគម និងពល-និកាយ មិនគប្បីបៀតបៀនបព្ជិត គប្បីប្រព្រឹត្តស្មើក្នុងព្រះឱរស និងព្រះជាយា ។

ស តាទិសោ ភូមិបតិ រដ្ឋជ្ជាលោ អកោធនោ

សាមន្ត សម្ជកម្ជតិ ឥន្ទោវ អសុរាធិបោតិ ។

ព្រះរាជាទ្រង់ជាធំលើផែនដី ដូច្នោះ ជាអ្នកគ្រប់គ្រងស្រុកក្រុង ទ្រង់មិនគប្បីពិរោធ រមែងធ្វើឲ្យប្រទេសជិតខាងញាប់ញ័រ

ដូចព្រះឥន្ទ្រទ្រង់ជាធំលើពួកអសុរ ដូច្នោះ ។

*បណ្តាបទទាំងនោះ បទថា **ពកាសុ បុពេ** "**ក្នុងកាលមុនផ្ទៃព្រៃ**" បានដល់ ក្នុងកាលមុនមានផ្ទៃព្រៃ ។ បទថា **អសុ** នេះ ជានិបាត ។ ព្រះមហាពោធិបរិព្វាជកពោលអធិប្បាយថា មហា-បពិត្រ ក្នុងកាលមុន មានផ្ទៃព្រៃមួយកន្លាលមានរូបរាងស្រដៀងនឹងពពែ កន្ទុយរបស់វាវែង តែវាយកកន្ទុយស៊ីកទុកត្រង់ចន្ទោះជើងវាដែលពួកពពែមិនប្រយ័ត្នដោយរូបរាង ទើបចូលទៅក្នុងហ្វូងពពែដេញសម្លាប់ទាំងឈ្មោលទាំងញីក្នុងទីនោះឯង ក៏រត់គេចទៅដោយអាការយ៉ាងណា ។ បទថា **តថាវិធេកេ** "**មានអាការដូចយ៉ាងនោះ**" សេចក្តីថា សមណៈ និងព្រាហ្មណ៍ពួកខ្លះ ក៏មានអាការដូច្នោះ ធ្វើការបិទបាំង គឺ បិទបាំងខ្លួនឯងដោយកេទបពូជិត ធ្វើដូចជាប្រាជ្ញាប្រយោជន៍ ត្រាច់ចោកបញ្ឆោតមនុស្សលោកដោយវាចាដ៏ផ្អែមល្អែមជាដើម ។ បទថា **អនាសកា** "**ការប្រព្រឹត្តិមិនស៊ីអាហារ**" ជាដើម

លោកពោលទុកដើម្បីនឹងសម្តែងកិរិយាបិទបាំង របស់ពួកសមណ-ព្រាហ្មណ៍ទាំងនោះ ។ ពិតហើយ សមណព្រាហ្មណ៍ពួកខ្លះរមែងនាំគ្នាកុហកពួកមនុស្សថា "ពួកយើងដល់នូវការមិនស៊ីអាហារជាវត្ត ទើបមិនត្រូវការឲ្យពួកអ្នកទៅនាំអាហារអ្វីៗ មក" ។ ចំណែកពួកខ្លះក៏កុហកថា "ពួកយើងដល់នូវការដេកលើផែនដីជាវត្ត" ។ ឯចំពោះពួកខ្លះ ក៏កាន់យកការលាបស្រទ្បាបដោយធូលីជាគ្រឿងបំកាន់ ។ ពួកខ្លះក៏កាន់យកការតាំងសេចក្តីព្យាយាមដោយដើរច្រហោងជើងជាវត្ត ។ អធិប្បាយថា ពួកគេទាំងនោះកាលដើរទៅ ក៏ស្ទួយខ្លួនឡើង ច្រហោងជើងដើរទៅ ។ ពួកខ្លះបិទបាំងខ្លួនដោយការស៊ីនូវអាហារមួយដង គឺ អស់ ៧ ថ្ងៃខ្លះ ១០ ថ្ងៃខ្លះ ទើបស៊ីម្តងទៀតជាដើម ។ ពួកខ្លះជាអ្នកមិនព្រមផឹកទឹក នាំគ្នាពោលថា "ពួកយើងមិនផឹកទឹកទេ" ។ បទថា **អរហន្តោ វទានា "ដើរនិយាយអួតថាជាព្រះអរហន្ត"** សេចក្តីថា ជនទាំងនោះមានការប្រព្រឹត្តថោកទាប

នាំគ្នាដើរនិយាយយ៉ាងនេះថា "ពួកយើងជាព្រះអរហន្ត" ។ បទថា **ឯតេ "ជនទាំងនេះ"** សេចក្តីថា មហាបពិត្រ ជនទាំង ៥ នាក់នេះ ឬពួកជនដទៃដែលឈ្មោះថា មានទិដ្ឋិ និងគតិដូច្នេះ ជនពួកទាំងអស់នេះ ឈ្មោះថា ជាអសប្បុរស ។ បទថា **យមាហុ "ពួកជនដែលពោលថា"** កាត់បទជា **យេ អាហុ** ជនពួកណាពោល ។ បទថា **សចេ ហិ វីរិយំ នាស្ស "ប្រសិនបើសេចក្តីព្យាយាមមិនគប្បីមាន"** សេចក្តីថា មហាបពិត្រ បើសេចក្តីព្យាយាមដែលប្រព្រឹត្តទៅផ្លូវកាយ និងផ្លូវចិត្តដែលសម្បយុត្តដោយញ្ញាណមិនគប្បីមានសោត ។ បទថា **កម្មំ "កម្ម"** សេចក្តីថា បើសូម្បីកម្មល្អ និងកម្មអាក្រក់មិនគប្បីមាន ។ បទថា **ន ករេ "ទ្រង់ក៏នឹងមិនចិញ្ចឹម"** សេចក្តីថា បើដូច្នោះ ព្រះរាជាទ្រង់មិនគួរចិញ្ចឹមពួកជាងឈើ ឬថា ពួកខ្ញុំរាជការដទៃទុកឡើយ ។ បទថា **នបិ យន្តានិ "សូម្បីពួកជាង ក៏មិនគប្បីធ្វើយន្តទាំងឡាយឲ្យសម្រេចបាន"** សេចក្តីថា

សូម្បីពួកជាងក៏មិនគប្បីធ្វើយន្តទាំងឡាយ មានប្រាសាទ ៧ ជាន់ជាដើម ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះមិនមានសេចក្តីព្យាយាមក្នុងការងារ ។ បទថា ***ឧច្ចិជ្ជយ្យ "គប្បីសូន្យទេ"*** *គឺ មហាបពិត្រ ប្រសិនបើភ្លៀងមិនធ្លាក់ ទឹកសន្ទ្រីមក៏មិនធ្លាក់អស់ កាលត្រឹមប៉ុណ្ណោះ តអំពីនោះ លោកនេះក៏គប្បីសូន្យទេ ដូចកាលជាទីតាំងទ្បើងនៃកប្ប តែដែលឈ្មោះថា ការនឹងសូន្យទេមិនមានដោយទំនងដែលឧច្ឆេទវាទីអាមាត្យពោលហើយ ។ បទថា* ***ជ-លយតេ "ចិញ្ចឹម"*** *ជានដល់ រមែងចិញ្ចឹម ។*

ព្រះមហាសត្វជានពោល ៤ គាថាមានពាក្យផ្តើមថា ***ឥវ ពោ ឥវ មានានំ "ប្រសិនបើហ្វូងគោហែលឆ្លងត្រើយទៅហើយ"*** *ក៏ដើម្បីនឹងសម្តែងធម៌ដល់ព្រះរាជាប៉ុណ្ណោះ ។ ពាក្យផ្តើមថា* ***មហារុក្ខស្ស "កាលដើមឈើធំ"*** *ជូរច្នេះជាអាទិ ក៏ដើម្បីសម្តែងធម៌ដល់ព្រះរាជាដូចគ្នា ។ បណ្តាបទទាំងនោះ បទថា* ***មហារុក្ខស្ស "កាលដើមឈើ***

ធំ" បានដល់ ដើមស្វាយមានរសផ្អែម ។ បទថា **អធម្មេន "ព្រោះមិនមែនជាធម៌"** បានដល់ ព្រោះតាំងនៅក្នុងអគតិ ។ បទថា **រសញ្ញូ ន ជានាតិ "ព្រះរាជានោះរមែងមិនដឹងរសនៃរដ្ឋនោះ"** គឺ ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ រមែងមិនស្គាល់រស គឺ ឱជៈនៃរដ្ឋ បានដល់ រមែងមិនបាននូវភាពសម្បូរដោយសេចក្តីចម្រើន ។ បទថា **វិនស្សតិ "រមែងវិនាសទៅ"** បានដល់ រមែងសូន្យទៅ ។ មនុស្សទាំងឡាយរមែងនាំគ្នាលះបង់ស្រុក និងនិគម ហើយទៅនៅអាស្រ័យស្ថានទីដែលមិនរាបស្មើ គឺ ភ្នំដែលនៅត្រង់ជាយដែន ។ ផ្លូវនៃសេចក្តីចម្រើនទាំងអស់រមែងសូន្យទៅ ។ បទថា **សញ្ជាសធីកិ "ចាកព្រះឱសថទាំងពួង"** សេចក្តីថា ព្រះរាជាទ្រង់រមែងឃ្លាតចាកព្រះឱសថទាំងឡាយ មានឫសឈើ សំបកឈើ ស្លឹកឈើ ផ្លាឈើ និងផ្ទៃឈើជាដើម និងព្រះឱសថមានទឹកដោះជ្រូ និងទឹកដោះខាប់ជាដើម ព្រះឱសថទាំងនោះរមែងមិនដល់ព្រម ។

ព្រោះថា ផែនដីរបស់ព្រះរាជាអ្នកមិនតាំងនៅក្នុងធម៌ រមែងជាផែនដីប្រាសចាកឱជៈ ។ ព្រោះផែនដីនោះប្រាសចាកឱជៈហើយ ឱជៈនៃឱសថទាំងឡាយទើបមិនមាន ឱសថទាំងនោះមិនអាចនឹងរក្សារោគឲ្យវិនាសបាន ។ ព្រះរាជាអង្គនោះឈ្មោះថា ជាអ្នកឃ្លាតចាកព្រះឱសថទាំងនោះ ដោយប្រការដូច្នេះ ។ បទថា **នេគមេ** "**អ្នកនិគម**" សេចក្តីថា ព្រះរាជាទ្រង់បៀតបៀន គឺ ទ្រង់បៀតបៀនដល់ពួកកុដុម្ពិកៈដែលនៅក្នុងនិគម ។ បទថា **យេ យុត្តា** "**អ្នកប្រកប**" សេចក្តីថា មួយទៀត ទ្រង់បៀតបៀនពួកឈ្មួញផ្លូវគោក និងពួកឈ្មួញផ្លូវទឹក ដែលប្រកបការជួញដូរ បំណងឆ្ពោះទៅកាន់សេចក្តីចម្រើន ។ បទថា **ឱជទានពលីការេ** "**អ្នកធ្វើការថ្វាយឱជៈ និងពលីកម្ម**" សេចក្តីថា អ្នកធ្វើការថ្វាយឱជៈដោយអំណាចការនាំនូវកណ្ហៈមក និងការថ្វាយនូវសួយអំពីជនបទនោះ និងធ្វើពលីកម្មមានប្រភេទផ្សេងៗ ជាដើម គឺ បែងជា ៦ ចំណែក និង ១០ ចំណែក ។

បទថា **ស ពោសេន** "ព្រះរាជាអង្គនោះ... ចាកចំណែកព្រះរាជ-ទ្រព្យ" សេចក្ដីថា ព្រះរាជាអង្គនោះទ្រង់បៀតបៀនប្រជាជនទាំងនោះហើយ ជាព្រះរាជាមិនតាំងនៅក្នុងធម៌ ឈ្មោះថា រមែងវិនាសចាកទ្រព្យ និងធញ្ញាហារ ឃ្លាតចាកចំណែកនៃព្រះរាជទ្រព្យ ។ បទថា **បហារវរេ ត្ត ញ្ញូ** "ព្រោនអ្នកដ៏ឯកខ្ពង់ខ្ពស់នៃការប្រហារយ៉ាងល្អ" គឺ នាយខ្នាន់ធ្នូអ្នកដ៏ឯកខ្ពង់ខ្ពស់នៃការប្រហារយ៉ាងល្អ គឺ យ៉ាងនេះថា គួរនឹងបាញ់ទៅក្នុងទីត្រង់នេះ ។ បទថា **សង្គ្រាមេ កតនិស្សរេ** "ទ-ហានអ្នកពេញចិត្តក្នុងសង្គ្រាម" បានដល់ នាយទាហានថ្នាក់ធំទាំងឡាយដែលសម្រេចអំពីការច្បាំងក្នុងយុទ្ធភូមិ ។ បទថា **ខ្ញ្ជ្ជ្ជ្ជ** "អាមាត្យដែលរុងរឿង" បានដល់ មហាមាត្យដ៏ប្រសើរ គឺ មានកេរ្តិ៍ឈ្មោះល្បីល្បាញ ។ បទថា **ហ៊ីសយ** "ទ្រង់បៀតបៀន" បានដល់ ទ្រង់បៀតបៀនខ្លួនឯងក្ដី ប្រើឲ្យអ្នកដទៃបៀតបៀនក្ដី ដល់បុគ្គលទាំងឡាយបែបនេះ ។ បទថា **ពលេន** "ចាកពលនិកាយ" បាន

ដល់ ពួកកងកម្លាំង ។ ពិតហើយ ពួកទាហានសូម្បីដ៏សេសក៏រមែងលះបង់ព្រះរាជាដែលទ្រង់ប្រព្រឹត្តយ៉ាងនោះ ដោយគិតថា "ព្រះរាជាអង្គនេះទ្រង់បៀតបៀនសូម្បីទាំងបុគ្គលអ្នកប្រគល់រាជ្យសម្បត្តិឲ្យដល់ព្រះអង្គ ដែលជាអ្នកមានឧបការៈច្រើន ហេតុអ្វីទើបទ្រង់បៀតបៀនពួកយើងហ្ន៎" ។ ព្រះរាជាអង្គនោះឈ្មោះថា រមែងឃ្លាតចាកពួកពលដោយប្រការដូច្នេះ ។ បទថា **តថេវ ឥសយោ ហិ សំ** "**មួយទៀត... បៀតបៀនបព្វជិតអ្នកស្វែងរកនូវគុណ**" សេចក្ដីថា ព្រះរាជាទ្រង់មិនប្រព្រឹត្តធម៌ ទ្រង់បៀតបៀនបព្វជិតអ្នកស្វែងរកនូវគុណ ដោយការជេរ និងវាយជាដើម ដូចទ្រង់បៀតបៀនអ្នកស្រុកជាដើម កាលកាយបែកធ្លាយទៅ រមែងចូលដល់អបាយដោយពិត មិនអាចទៅកើតក្នុងសួគ៌បាន ដូច្នោះ ព្រះរាជាអង្គនោះទើបឈ្មោះថា រមែងឃ្លាតចាកសួគ៌ ដោយប្រការដូច្នេះ ។ បទថា **ករិយំ ហន្តិ អទូសកំ** "**សម្លាប់ព្រះជាយាដែលមិនប្រទូស្តតប**" សេចក្ដី

ថា ព្រះរាជាទ្រង់ជឿពាក្យរបស់ពួកចោរដែលជាមិត្តប្លម ហើយឲ្យ
សម្លាប់ព្រះជាយាអ្នកមានសីល អ្នកចម្រើនព្រមដោយបុត្ត និងធីតា
ដែលចម្រើនហើយក្នុងរង្វង់ដៃរបស់ខ្លួន ។ បទថា **លុទ្ធំ ឋសវតេ
ឋានំ**[1] **"រមែងបានប្រសព្វក្នុងឋានៈដ៏អាក្រក់"** សេចក្តីថា ព្រះរាជា
អង្គនោះរមែងប្រសព្វ គឺ រមែងសម្រេចនូវផលដែលចូលដល់នរក
ដោយខ្លួនឯង ។ បទថា **បុត្តេហិ ច "និង... ចាកព្រះរាជបុត្តទាំង
ឡាយ"** បានដល់ ព្រះរាជាអង្គនោះរមែងខុសជាមួយព្រះឱរសទាំង
ឡាយរបស់ព្រះអង្គក្នុងអត្តភាពនេះឯង ។

ព្រះមហាសត្ត្ব ពោលដល់រឿងដែលព្រះរាជាអង្គនោះទ្រង់ជឿ
ពាក្យរបស់ជនទាំង ៥ នាក់នោះ ហើយឲ្យសម្លាប់ព្រះទេវី និង
ពោលដល់រឿងព្រះអង្គនោះ ទ្រង់ខុសព្រះទ័យជាមួយព្រះឱរសទាំង
ឡាយ ដូចចាប់ចោរត្រង់សក់ក្នុងទីចំពោះមុខដូច្នោះ ។ ពិតហើយ

ឋិដក. ១. លុទ្ធំ ឋសវតេ ឋានំ ។

ព្រះមហាសត្វប្រាប្ដានឹងញ៉ាំញ៉ីដល់ពួកអាមាត្យទាំងនោះ បំណងនឹងសម្ដែងធម៌ និងបំណងបើកបង្ហាញរឿងដែលព្រះទេវីត្រូវពួកអា-មាត្យទាំងនោះសម្ងាប់ ទើបបាននាំយកពាក្យដែលបានឱ្យកាសពោលជាសេចក្ដីនេះទុកដោយលំដាប់ ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់ព្រះមហាសត្វហើយ ក៏ទ្រង់ជ្រាបច្បាស់ដល់កំហុសរបស់ព្រះអង្គ ។ លំដាប់នោះ ព្រះមហាសត្វទើបបានទូលព្រះរាជាឲ្យទ្រង់ជ្រាបថា "មហាបពិត្រ តាំងអំពីថ្ងៃនេះទៅ ទ្រង់កុំជឿពាក្យរបស់ពួកមនុស្ស អាក្រក់នេះ ហើយធ្វើយ៉ាងនេះទៀតឡើយ" កាលនឹងពោលទូន្មានព្រះរាជា ទើបពោលគាថាជាដើមថា **គប្ប៊ីប្រព្រឹត្ដធម៌** ។

បណ្ដាបទទាំងនោះ បទថា **ធម្មំ ចរ** "**គប្ប៊ីប្រព្រឹត្ដធម៌**" សេចក្ដីថា មហាបពិត្រ ធម្មតាថា ព្រះរាជាមិនគួរបៀតបៀនអ្នកជនបទ មិនគួរធ្វើម្ចាស់ទ្រព្យ ឲ្យក្លាយជាអ្នកមិនមែនម្ចាស់ទ្រព្យ តែគប្ប៊ីប្រព្រឹត្ដធម៌ក្នុងអ្នកស្រុកទាំងឡាយ មិនគួរលំបាកក្នុងទីដែល

មិនមែនជាហានៈ តែគប្បីប្រព្រឹត្តធម៌ក្នុងពួកពលទាំងឡាយ គួរវៀរ
ចាកការសម្ងាប់ ការចាប់ចង ការជេរ និងការវាយដំ និងឲ្យបច្ច័យ
ដល់បព្វជិតទាំងនោះ មិនគួរបៀតបៀនបព្វជិតអ្នកស្វែងរកនូវគុណ
គួរស្ថាបនាព្រះធីតាទុកក្នុងតំណែងដែលសមគួរ ឲ្យព្រះឱរសសិក្សា
រៀនសូត្រសព្វសិល្ប: ទ្រង់ឧបត្ថម្ភចិញ្ចឹមដោយធម៌ ទ្រង់អនុគ្រោះ
ព្រះជាយាដោយទ្រង់ប្រគល់ភាពជាធំ ប្រគល់ឲ្យនូវគ្រឿងប្រដាប់
តាក់តែង និងទ្រង់លើកសរសើរជាដើម គប្បីប្រព្រឹត្តស្មើទាំងក្នុង
ព្រះឱរស និងព្រះជាយា ។ បទថា **ស តាទិសោ** "ព្រះរាជា...
ជ្ជុ**ន្ធោ**" សេចក្ដីថា ព្រះរាជាជ្ជុន្ធោ រមែងមិនទម្លាយព្រះរាជប្រពៃណី
សោយរាជ្យសម្បត្តិដោយធម៌ រមែងធ្វើឲ្យប្រទេសជិតខាងឲ្យញាប់
ញ័រ ឲ្យកំយ្ងាច ឲ្យតក់ស្លុតដោយព្រះរាជអាជ្ញា និងព្រះតេជានុ-
ភាពរបស់ព្រះអង្គ ។ បទថា **ឥន្ទ្រោ** "**ដូចជាព្រះឥន្ទ្រ**" នេះ ជា
ការពោលទុកដើម្បីឧបមា ។ អធិប្បាយថា ព្រះរាជាអង្គនោះរមែង

ធ្វើប្រជាជនដែលនៅជិតឲ្យញាប់ញ័រ ដូចព្រះឥន្ទ្រអ្នកដល់នូវការ
ភាប់ថា ជាម្ចាស់នៃអសុរ តាំងពីវេលាដែលទ្រង់ច្បាំងឈ្នះហើយ
ក៏គ្របសង្កត់ពួកអសុរ ធ្វើពួកអសុរដែលជាសត្រូវរបស់ព្រះអង្គឲ្យ
ញាប់ញ័រ ដូច្នោះ ។

ព្រះមហាសត្ត គ្រាសម្ដែងធម៌ដល់ព្រះរាជាយ៉ាងនោះហើយ
ទើបឲ្យទៅទូលយាងព្រះកុមារទាំង ៤ ព្រះអង្គមកទ្ទ្ធាន ហើយក៏
ប្រកាសដល់កម្មដែលធ្វើហើយចំពោះព្រះរាជា ឲ្យព្រះរាជាទ្រង់លើក
ទោសឲ្យ បានថ្វាយឱ្យ៉ាទដល់ជនទាំងអស់ថា "មហាបពិត្រ តាំង
អំពីនេះទៅ ព្រះអង្គមិនទាន់ពិចារណាជាមុន ទ្រង់កុំបានកាន់យក
ពាក្យរបស់ពួកបុគ្គលអ្នកបំណងបំផ្លាញ ហើយធ្វើកម្មដោយរហ័ស
ដ៏ដ្ឋ-ដ្ឋ-ដ្ឋ-

ព្រះទេវី អាស្រ័យអាមាត្យទាំងនេះ រវល់តែជឿពាក្យរបស់ពួកវា ទើបបានធ្វើបាបកម្មដូច្នេះ ខ្ញុំនឹងសម្លាប់អាមាត្យទាំង ៥ នាក់នេះ ចេញ" ។ ព្រះមហាសត្វថ្វាយបង្គាញថា "មហាបពិត្រ ព្រះអង្គកុំ បានធ្វើយ៉ាងនោះទៅ" ព្រះរាជាត្រាស់ថា "បើដូច្នោះ ខ្ញុំនឹងឲ្យ កាត់ដៃកាត់ជើងពួកវា" ។ ព្រះមហាសត្វទូលថា "សូម្បីកម្មដូច្នេះ ក៏មិនគួរធ្វើ" ។ ព្រះរាជាទ្រង់ទទួលថា "ល្អហើយ លោកដ៏ចម្រើន" ហើយទ្រង់ក៏ត្រាស់ឲ្យរឹបអូសទ្រព្យសម្បត្តិរបស់អាមាត្យទាំងនោះ ទាំងអស់ ហើយទ្រង់ឲ្យការសក់ទុក ៥ កញ្ចុំ ចងដោយតង្ហៀប និងលាបដោយគោម័យ ហើយឲ្យបណ្តេញអំពីដែន ។ សូម្បីព្រះ មហាសត្វស្នាក់នៅក្នុងទីនោះ ២-៣ ថ្ងៃហើយ ថ្វាយឱវាទចំពោះ ព្រះរាជាថា "សូមព្រះអង្គចូរជាអ្នកមិនប្រមាទចុះ" ហើយក៏ត្រឡប់ ទៅកាន់ហិមវន្តដូចដើម ធ្វើឈាន និងអភិញ្ញាឲ្យកើត ចម្រើនព្រ-ហ្មវិហារធម៌ អស់ជីវិត លុះអស់ជីវិតក៏ចូលដល់ព្រហ្មលោក ។

ព្រះសាស្តាគ្រាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់គ្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងវេលានេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ជាអ្នកមានបញ្ញា ញ្ចាំញ្ចីនូវពាក្យរបស់អ្នកដទៃចេញបានដូចគ្នា" ហើយទ្រង់ប្រជុំជាតកថា "អាមាត្យទាំង ៥ នាក់ក្នុងគ្រានោះ បានមកជា បូរណកស្សប: ១ មក្ខលិ-គោសាល ១ បកុធកច្ចាន: ១ អជិតកេសកម្ពល ១ និងនិគ្រន្ត-នាដបុត្ត ១ ក្នុងកាលឥឡូវនេះ, សុនទ១ណ៌ លៀងក្នុងគ្រានោះ បានមកជាព្រះអានន្ទ, ចំណែកមហាពោធិបរិព្វាជកក្នុងគ្រានោះ ក៏គឺ **តថាគត** នេះឯង" ។

ចប់អដ្ឋកថា មហាពោធិជាតកទី ៣

ចប់អដ្ឋកថាបញ្ញាសនិចាត

ដែលប្រជាប់ដោយជាតក ៣ រឿង

១. ឆទ្ទិនិកាជាតក ២. ឧម្មាទន្តីជាតក

៣. មហាពោធិជាតក

រាយនាមសប្បុរសជន
ចូលរួមកសាងគម្ពីរអដ្ឋកថា

-លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស	.....	$ 2.000 USA
-ឧចាសក សោម រតន: ព្រមទាំងភរិយា បុត្ត និងចៅ	.....	$ 500 USA
-ឧចាសក តាំង សុជល ឧចាសិកា ឆ្ងួន កេន ព្រមទាំងបុត្ត និងចៅ	.....	$ 200 USA
-កញ្ញា តាំង សុមាវ៉ាតី	.....	$ 50 USA
-ចៅស្រី ង៉ាន់ ឧត្តរា, ង៉ាន់ ង៉ានីឆ្នា, ង៉ាន់ សាហ្ស៊ីយ៉ា	.....	$ 50 USA